- សូមឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិឃុំដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋនៅក្នុងឃុំ។



Draft

រូបភាព៦.១៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់នៅសាលាខេត្តសៀមរាប

៦.៤.៥ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប

លោក នួន គ្រីស្នា ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប បានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៤ នៅម៉ោង៣:២០ ដល់៤:២០ល្ងាច។ ការជួបសម្ភាសន៍នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

សំណួរទី១៖ តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងដែរឬទេ?
ចម្លើយទី១៖ បាទ, ខ្ញុំបានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង

សំណួរទី២៖ តើលោកធ្លាប់ដឹងថាតំបន់គម្រោងពីមុនជាតំបន់ដែលមានលក្ខណៈដូចម្តេចដែរ? សម្បូរដោយផ្លូវទឹក ស្ទឹង បឹង និងប្រព័ន្ធធារាសាស្ត្រឬដែរទេ? តើមានឈ្មោះអ្វីខ្លះ?
ចម្លើយទី២៖ តំបន់គម្រោងពីមុនជាតំបន់ដែលមានផ្លូវទឹកតែមួយគត់គឺស្ទឹងជីក្រែង។

សំណួរទី៣៖ តើបច្ចុប្បន្ន ប្រព័ន្ធផ្លូវទឹកនេះមានការប្រែប្រួលដូចម្តេចខ្លះ? ចូររៀបរាប់។
ចម្លើយទី៣៖ ស្ទឹងនោះមានលក្ខណៈតូច បាក់ច្រាំង និងគោករាក់នៅក្នុងរដូវប្រាំង។

សំណួរទី៤៖ តើលោកដឹងថាប្រជាជនប្រើប្រាស់ទឹកពីប្រភពណា? តើបរិមាណទឹកនេះគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ឬទេ? តើគុណភាពទឹកដូចម្តេចដែរ?
ចម្លើយទី៤៖ ទឹកនេះមានប្រភពមកពីខេត្តព្រះវិហារ និងប៉ែកខាងកើតនៃភ្នំដងរ៉ែក។

សំណួរទី៥៖ តើសកម្មភាពធ្វើអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែង មានផលប៉ះពាល់ជាអវិជ្ជមានអ្វីខ្លះដល់ស្ថានភាពបរិស្ថាន និងសង្គម?
ចម្លើយទី៥៖ ជាទូទៅការអភិវឌ្ឍតែងតែផ្តល់នូវហេតុប៉ះពាល់ដល់ស្ថានភាពបរិស្ថានដែលនៅជុំវិញតំបន់គម្រោង។ ប្រសិនបើក្រុមហ៊ុនមិនបានអនុវត្តទៅតាមបច្ចេកទេស រឺផែនការមេក្នុងការធ្វើអាជីវកម្មឲ្យបានត្រឹមត្រូវទេ វាអាចធ្វើឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ។

សំណួរទី៦៖ តើលោកមានចំណាប់អារម្មណ៍ ឬការព្រួយបារម្ភយ៉ាងដូចម្តេចខ្លះចំពោះគម្រោងធ្វើអាជីវកម្មនេះ?
ចម្លើយទី៦៖ ខ្ញុំមិនជំទាស់នឹងការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយខ្ញុំនៅតែមានការព្រួយបារម្ភមួយចំនួនដូចជា៖

- ការលេចជ្រាបសមាសធាតុរ៉ែដែលបានស្តុកទុកចូលទៅក្នុងដី និងក្នុងប្រភពទឹក
- ផលប៉ះពាល់សុខភាពកម្មករ និងប្រជាជនដែលរស់នៅក្បែរតំបន់គម្រោង
- គុណភាពដីកសិកម្ម និងទិន្នផលកសិកម្មនឹងអាចមានការថយចុះ
- គុណភាពទឹកប្រើប្រាស់ក្នុងតំបន់

សំណួរទី៧៖ តើលោកគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដែរឬទេ? តើលោកចង់ឱ្យមានការវិនិយោគបែបនេះនៅក្នុងតំបន់ផ្សេងៗទៀតដែរឬទេ?
ចម្លើយទី៧៖ ខ្ញុំគាំទ្រឱ្យមានការអភិវឌ្ឍបើក្រុមហ៊ុនវិនិយោគមានលក្ខណៈបច្ចេកទេសគ្រប់គ្រាន់ និងមានការគាំទ្រពីរាជរដ្ឋាភិបាល។

សំណួរទី៨៖ តើលោកមានសំណូមពរ និងអនុសាសន៍យ៉ាងដូចម្តេចខ្លះ?
ចម្លើយទី៨៖ ខ្ញុំមានសំណូមពរសូមឱ្យមានការអភិវឌ្ឍចំគោលដៅ និងគោរពទៅលើគោលនយោបាយរបស់រដ្ឋាភិបាល។

រូបភាព៦.២៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយមន្ទីរធនធានទឹក និងឧតុនិយម

៦.៤.៦ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលព្រៃឈើខេត្តសៀមរាប

លោក ធា គឹមសុទ្ធ នាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តសៀមរាប បានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) បានជួបសម្ភាសន៍នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង៤:០០ ដល់៥:០០ល្ងាច។ ការជួបសម្ភាសន៍នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

សំណួរទី១៖ តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងដែរឬទេ?
ចម្លើយទី១៖ បាទ, ខ្ញុំធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង។

សំណួរទី២៖ តើលោកដឹងពីស្ថានភាពភូមិសាស្ត្រ និងគម្របព្រៃឈើនៅស្រុកជីក្រែងដែរឬទេ?
ចម្លើយទី២៖ ស្ថានភាពភូមិសាស្ត្រ និងគម្របព្រៃឈើនៅស្រុកជីក្រែងនេះជាប្រភេទព្រៃរបោះ និងព្រៃពាក់កណ្តាលស្រោង

សំណួរទី៣៖ មុនគម្រោងអាជីវកម្មរ៉ែទង់ដែង តើមានព្រៃឈើតំបន់នោះជាប្រភេទព្រៃអ្វីខ្លះ? ប៉ុន្មានភាគរយ? សូមបញ្ជាក់ឆ្នាំ។
ចម្លើយទី៣៖ មុនគម្រោងអាជីវកម្មរ៉ែទង់ដែង ព្រៃឈើនៅក្នុងតំបន់នោះជាប្រភេទព្រៃរបោះ និងព្រៃពាក់កណ្តាលស្រោង។

សំណួរទី៤៖ តើតំបន់គម្រោងធ្វើអាជីវកម្មប៉ះពាល់ព្រៃឈើប៉ុន្មានហិកតា?
ចម្លើយទី៤៖ ខ្ញុំមិនអាចប៉ាន់ស្មានបានទេពីទំហំនៃផលប៉ះពាល់ ពីព្រោះក្រុមហ៊ុនមិនទាន់បានធ្វើផែនទីចុងក្រោយជាក់ស្តែងឱ្យរដ្ឋបាលព្រៃឈើ

សំណួរទី៥៖ តើតំបន់គម្រោងមានប្រភេទឈើប្រណិតដែរឬទេ? បើមាន តើមាប្រភេទឈើអ្វីខ្លះ?
ចម្លើយទី៥៖ នៅក្នុងតំបន់គម្រោងនេះមានទាំងប្រភេទឈើលេខ១ និងលេខ២។ ចំពោះព្រៃរបោះអាចមានឈើប្រណិតមួយចំនួនដូចជា ឈើបេង ឈើធ្នង់ ឈើនាងនួន ឈើចង្រ្កង់ និងឈើផ្សេងៗទៀត។ ចំណែកព្រៃពាក់កណ្តាលស្រោង អាចមានឈើដូចជា ឈើឧស្សាហាកម្មជាដើម។

សំណួរទី៦៖ តើមានវត្តមានសត្វព្រៃតំបន់គម្រោងបច្ចុប្បន្នដែរឬទេ? តើមានប្រភេទសត្វកម្រដែរឬទេ?
ចម្លើយទី៦៖ វត្តមានសត្វព្រៃពិតជាមាននៅក្នុងតំបន់គម្រោង ដោយសារតំបន់នេះមានទីតាំងនៅជាប់ដែនជំរកសត្វព្រៃ **បឹងពែរ។**

សំណួរទី៧៖ ដោយសារតែការធ្វើអាជីវកម្មរ៉ែនៅស្រុកជីក្រែង តើលោកគិតថាប្រភេទសត្វ និងរុក្ខជាតិមានផលប៉ះពាល់យ៉ាងដូចម្តេចដែរ?
ចម្លើយទី៧៖ គម្រោងអាជីវកម្មរ៉ែនេះអាចធ្វើឲ្យមានផលប៉ះពាល់ដល់សត្វ និងព្រៃឈើដូចជា៖
- បាត់បង់ជំរកសត្វព្រៃដោយសារអស់ព្រៃឈើ
- ការរំខានដោយសូរសម្លេងពីគ្រឿងចក្រនៅក្នុងតំបន់គម្រោង និងមនុស្ស

សំណួរទី៨៖ តើលោកគិតថាគួរមានវិធានការ និងវិធីសាស្ត្របែបណាដើម្បីកាត់បន្ថយនូវហេតុប៉ះពាល់ទាំងអស់នេះ?

ចម្លើយទី៨៖ ចំពោះសត្វព្រៃ ខ័ណរដ្ឋបាលព្រៃឈើត្រូវការសហការណ៍ជាមួយក្រុមអភិរក្សសត្វព្រៃ ពីព្រោះក្រុមអភិរក្សដឹងច្បាស់ពីលក្ខណៈជីវសាស្ត្ររបស់សត្វព្រៃ ភាពបន្សាំ និងភាពរំខានក្នុងការរស់នៅរបស់វា។

សំណួរទី៩៖ ចំពោះប្រជាជននៅឃុំខ្វាវ មុនពេលមានគម្រោងអភិវឌ្ឍន៍ តើពួកគាត់ធ្លាប់ទៅស្វែងរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោងដែរឬទេ?

ចម្លើយទី៩៖ មុនពេលមានគម្រោងអភិវឌ្ឍន៍ ប្រជាជនក្នុងតំបន់មួយចំនួនពឹងពាក់អនុផលព្រៃឈើ និងធ្វើចំការពនេចរ។

សំណួរទី១០៖ តើលោកគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងនៅជីក្រែងដែរឬទេ? តើអ្នកចង់ឱ្យមានការអភិវឌ្ឍបែបនេះនៅក្នុងតំបន់របស់អ្នកទៀតដែរឬទេ?

ចម្លើយទី១០៖ ខ្ញុំគាំទ្រឱ្យមានការធ្វើអាជីវកម្មរ៉ែទង់ដែងក្នុងស្រុកជីក្រែង ដើម្បីផលប្រយោជន៍ប្រទេសជាតិ

សំណួរទី១១៖ តើលោកមានសំណូមពរ និងអនុសាសន៍យ៉ាងដូចម្ដេចខ្លះ?

ចម្លើយទី១១៖ ខ្ញុំមានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖

- លុបរណ្តៅរ៉ែ និងស្តារគម្របព្រៃឱ្យបានស្អាត នៅពេលបញ្ចប់គម្រោងអាជីវកម្មរ៉ែ។

រូបភាព៦.៣៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយខណ្ឌរដ្ឋបាលព្រៃឈើខេត្ត

៦.៨.៧ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ខេត្តសៀមរាប

លោក ម៉ៅ ចំរើន អនុប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ខេត្តសៀមរាបបានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង១០:០០ ដល់១១:០០ព្រឹក។ ការសម្ភាសនេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

សំណួរទី១៖ តើលោកបានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែង ខេត្តសៀមរាបដែរឬទេ?
ចម្លើយទី១៖ បាទ, ខ្ញុំបានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែង។

សំណួរទី២៖ តើក្រុមហ៊ុនវិនិយោគបានសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មរ៉ែ នៅស្រុកជីក្រែង ខេត្តសៀមរាបពីមន្ទីរបស់លោកដែរឬទេ?
ចម្លើយទី២៖ ក្រុមហ៊ុនមិនមានសុំច្បាប់អនុញ្ញាតអាជីវកម្មពីមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាបនៅឡើយទេ ពីព្រោះគម្រោងធ្វើអាជីវកម្មរ៉ែនេះមានទំហំធំដូចនេះសិទ្ធក្នុងការសំរេចចិត្តស្ថិតនៅលើក្រសួង។

សំណួរទី៣៖ តើមន្ទីររបស់លោក បានចុះត្រួតពិនិត្យនៅការដ្ឋានគម្រោងអាជីវកម្មរ៉ែស្រុកជីក្រែងដោយផ្ទាល់ដែរឬទេ?
ចម្លើយទី៣៖ បាទ, ខ្ញុំធ្លាប់ទទួលលិខិតអញ្ជើញចូលរួមពិនិត្យមើលការដ្ឋានដោយផ្ទាល់

សំណួរទី៤៖ តើលោកមានយោបល់ ឬសំណូមពរបែបណាចំពោះក្រុមហ៊ុនអាជីវកម្មរ៉ែទង់ដែង? តើអ្នកគាំទ្រចំពោះការធ្វើអាជីវកម្មនេះដែរឬទេ?
ចម្លើយទី៤៖ ខ្ញុំគាំទ្រចំពោះការអភិវឌ្ឍ ដែលមិនប៉ះពាល់ដល់ប្រជាពលរដ្ឋ ឬបរិស្ថាន។
ចំពោះសំណូមពរគឺ៖

- ក្រុមហ៊ុនត្រូវអនុវត្តន៍ទៅតាមនិតិវិធីច្បាប់
- ក្រុមហ៊ុនគួរតែមានទំនាក់ទំនងជាមួយស្ថាប័នថ្នាក់ក្រោម
- គួរតែចុះបញ្ជីដីធ្លីមុនការដ្ឋានដំណើរការ ដើម្បីជៀសវាងបាតុភាពកើតឡើង
- ប្រសិនបើមានការប៉ះពាល់ ក្រុមហ៊ុនត្រូវអនុវត្តន៍តាមសារាចរណ៍លេខ ០១។

Draft



រូបភាព៦.៩៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

Draft

៦.៤.៨ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរទេសចរណ៍ ខេត្តសៀមរាប

លោក ឌូ៉ង សេងភាក់ ប្រធានមន្ទីរទេសចរណ៍ ខេត្តសៀមរាបបានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្ក្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង ១០:០០ ដល់១១:០០ព្រឹក។ ការជួបសម្ភាសន៍នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

<u>**សំណួរទី១៖**</u> តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងខេត្តសៀមរាបដែរឬទេ?
<u>**ចម្លើយទី១៖**</u> ខ្ញុំមិនធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងទេ។

<u>**សំណួរទី២៖**</u> តើការធ្វើអាជីវកម្មរ៉ែទង់ដែងនោះ អាចប៉ះពាល់ដល់បរិមាណភ្ញៀវទេសចរណ៍ដែលចូលមកទស្សនានៅក្នុងតំបន់ដែរឬទេ? ហេតុអ្វី?
<u>**ចម្លើយទី២៖**</u> ការធ្វើអាជីវកម្មរ៉ែទង់ដែងនេះ មិនបានធ្វើឲ្យមានផលប៉ះពាល់ដល់បរិមាណភ្ញៀវទេសចរណ៍ដែលចូលមកទស្សនានៅក្នុងតំបន់ទេ។
<u>**សំណួរទី៣៖**</u> តើលោកមានការគាំទ្រ មានចំណាប់អារម្មណ៍ ឬការព្រួយបារម្ភយ៉ាងណាដែរចំពោះគម្រោងអាជីវកម្មរ៉ែនេះ?

<u>ចម្លើយទី៣៖</u> បាទ, ខ្ញុំគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែនេះពីព្រោះវាអាចផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់។ម្យ៉ាងវិញទៀតខ្ញុំក៏មានការព្រួយបារម្ភមួយចំនួនផងដែរ ជាពិសេសគឺផលប៉ះពាល់ទៅលើដីរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោង ព្រោះបញ្ហាវិវាទ ដីធ្លីជាបញ្ហាចំបង។

<u>សំណួរទី៤៖</u> តើលោកមានមតិយោបល់ ឬអនុសាសន៍បែបណាដែរចំពោះការធ្វើអាជីវកម្មនេះ?
<u>ចម្លើយទី៤៖</u> ខ្ញុំមានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖

- ក្រុមហ៊ុនត្រូវតែសិក្សាឱ្យជាក់លាក់ និងល្អិតល្អន់ដើម្បីជៀសវាងផលប៉ះពាល់នៅមូលដ្ឋាន
- ក្រុមហ៊ុនគួរតែមានវេទិកាពិភាក្សា មុននឹងធ្វើអាជីវកម្ម
- រាល់គម្រោងត្រូវឆ្លងកាត់ក្រុមប្រឹក្សាខេត្ត
- រាល់លិខិតបទដ្ឋានគួរតែមានពីក្រោមឡើងលើ ទើបមានប្រសិទ្ធភាព
- តាមទស្សនៈរបស់ខ្ញុំគាំទ្រ តែគួរផ្តល់ប្រយោជន៍ដល់សហគមន៍ផង។

រូបភាព៦.៥៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយមន្ទីរទេសចរណ៍ខេត្តសៀមរាប

៦.៨.៩ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប

លោក នឹម សុន អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាបបានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) បានជួបសម្ភាសន៍នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង៣:០០ ដល់៤:០០ល្ងាច។ ការជួបសម្ភាសន៍នេះបានភ្ជាប់ជាមួយនូវកម្រងសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

សំណួរទី១៖ តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង ខេត្តសៀមរាបដែរឬទេ?

ចម្លើយទី១៖ ខ្ញុំមិនធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនេះទេ ហើយក៏មិនធ្លាប់បានទទួលព័ត៌មានអ្វីដែលមានការទាក់ទងទៅនឹងគម្រោងធ្វើអាជីវកម្មនេះដែរ។

សំណួរទី២៖ តាមស្ថានភាពភូមិសាស្រ្ត តំបន់គម្រោងអាជីវកម្មរ៉ែទង់ដែងនេះ មានបេតិកភ័ណ្ឌដែរ ឬទេ?

ចម្លើយទី២៖ នៅតំបន់គម្រោងអាជីវកម្មរ៉ែទង់ដែងនេះ ក៏មានទីកន្លែងសក្ការៈបូជាមួយចំនួនដូចជាស្ពាន និងប្រាសាទមួយចំនួនដូចជា ប្រាសាទប្រាំ ប្រាសាទល្បើក ប្រាសាទភ្នំដុប ដែលប្រាសាទទាំង៣ខាងលើនេះ បានចុះបញ្ជីក្នុងសៀវភៅវិចិត្រសិល្បៈនៅឆ្នាំ២០០៥ និងគម្រោងកម្មវិធីបញ្ជីសារពើភ័ណ្ឌរបស់ក្រសួងវប្បធម៌។ ចំពោះស្ពានបុរាណមានដូចជា៖ ស្ពានខ្វាវ ស្ពានតាអុង ស្ពានខ្វាវ ស្ពានតូច ស្ពានភូមិអូរ ស្ពានក្មេង និងស្ពានថ្ម។

សំណួរទី៣៖ តើមានទីកន្លែងសក្ការៈបូជាដែរ រឺទេ? ចូររៀបរាប់?

ចម្លើយទី៣៖ នៅក្នុងតំបន់ក៏មានជាថ្មដាក់តាមដើមពោធិ៍ (ខ្មោមអ្នកតា) សម្រាប់ការគោរពបូជារបស់ប្រជាជននៅក្នុងតំបន់ផងដែរ ពីព្រោះប្រជាជនមានជំនឿគោរពបូជាតាមលក្ខណៈប្រពៃណីទំនៀមទំលាប់ ជាយូរណាស់មកហើយ។

សំណួរទី៤៖ តើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ មានផលប៉ះពាល់ដល់សម្បត្តិវប្បធម៌ ប្រជាជន និងជនជាតិភាគតិចដែលរស់នៅក្នុងតំបន់ដែរឬទេ? បើមាន តើមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ?

ចម្លើយទី៤៖ តាមយោបល់របស់ខ្ញុំ គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ ក៏បានផ្តល់នូវផលប៉ះពាល់មួយចំនួនផងដែរដែលមានដូចជា៖

- ទីសក្ការៈ (ខ្មោមអ្នកតា) អាចមានផលប៉ះពាល់លើប្រពៃណីទំនៀមទំលាប់ប្រសិនបើមានការបាត់បង់
- វត្ថុបុរាណផ្សេងៗ ដែលមានកប់ និងសេសសល់នៅក្នុងដី

Draft

- អាចធ្វើឲ្យបាត់បង់ព្រៃឈើ និងសត្វព្រៃមួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់អត្តសញ្ញាណ និងវប្បធម៌របស់យើង។

<u>សំណួរទី៥៖</u> តើលោកមានយោបល់ ឬសំណូមពរបែបណាចំពោះក្រុមហ៊ុនអាជីវកម្មរ៉ែទង់ដែង? តើលោកគាំទ្រចំពោះការធ្វើអាជីវកម្មនេះដែរឬទេ?

<u>ចម្លើយទី៥៖</u> ខ្ញុំគាំទ្រចំពោះការធ្វើអាជីវកម្មនេះតាមគោលការណ៍រដ្ឋាភិបាលដែលបានកំណត់ដើម្បីជួយឲ្យមានការអភិវឌ្ឍប្រទេសជាតិយើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានសំណូមពរមួយចំនួនចំពោះក្រុមហ៊ុនធ្វើអាជីវកម្មដូចជា៖

- ប្រសិនបើក្រុមហ៊ុន ប្រទះឃើញសម្បត្តិបេតិវប្បធម៌ផ្សេងៗនៅពេលដែលកំពុងធ្វើការវិនិយោគ សូមជួយថែរក្សាការពារទុកជាកេរ្តិ៍មរតកសម្រាប់ជាតិយើង។
- កំណត់បរិវេណការពារលេខ ០១ របស់ក្រសួងវប្បធម៌
- សូមវិនិយោគក្នុងលក្ខណៈអភិរក្ស នោះទើបកេរ្តិ៍តំណែលនឹងមិនមានការបាត់បង់
- ពេលមានការប៉ះពាល់ដល់ប្រជាជនមូលដ្ឋាន ព្រមទាំងប្រពៃណីវប្បធម៌ សេដ្ឋកិច្ច និងសង្គមត្រូវដោះស្រាយកុំឱ្យមានទំនាស់។

រូបភាព៦.៦៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយមន្ទីរទេសចរណ៍ខេត្តសៀមរាប

Draft

៦.៨.១០ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយនាយកដ្ឋានភូគព្ភសាស្ត្រ

លោក សៀន សុថាម មានតួនាទីជាប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ បានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍ជាមួយ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៨ នៅម៉ោង៤:០០ ដល់៥:០០ល្ងាច។ ការជួបសម្ភាសន៍នេះបានភ្ជាប់ជាមួយនូវកម្រងសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

<u>សំណួរទី១៖</u> តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង ខេត្តសៀមរាបដែរឬទេ?

<u>ចម្លើយទី១៖</u> បាទ, ខ្ញុំធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង។ បច្ចុប្បន្នក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណរុករករ៉ែក្នុងរយៈពេលពីរឆ្នាំដំបូង។ បន្ទាប់ពីរយៈពេលនេះ ក្រុមហ៊ុនត្រូវបញ្ចប់ការរុករក ការជីករករ៉ែ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដោយសារ ភូគព្ភសាស្ត្រ បានដឹងព័ត៌មានមិនច្បាស់លាស់ពីការសិក្សាបឋម ទើបជំរុញឱ្យក្រុមហ៊ុននេះធ្វើការរុករកបន្ថែមទៀតនៅក្នុងគោលបំណងដើម្បីទទួលបានទទួលបានព័ត៌មានលម្អិតបន្ថែមទៀត។

<u>សំណួរទី២៖</u> តើលោកធ្លាប់ចុះត្រួតពិនិត្យការដ្ឋាន និងតំបន់គម្រោងអាជីវកម្មដោយផ្ទាល់ឬទេ?

<u>ចម្លើយទី២៖</u> ខ្ញុំមិនធ្លាប់បានចុះទៅដោយផ្ទាល់នោះទេ ប៉ុន្តែខ្ញុំបានបញ្ជូនបុគ្គលិកទៅអគ្គនាយកដ្ឋានធនធានរ៉ែដើម្បីចូលរួមក្រុម ស៊ើបអង្កេតទៅលើការអភិវឌ្ឍអណ្តូងរ៉ែដែលក្រុមហ៊ុនត្រូវតែបំពេញក្នុងអំឡុងពេលពីរឆ្នាំនៃអាជ្ញាប័ណ្ណរុករករ៉ែ កាលពីប៉ុន្មានខែមុននេះ ហើយគាត់ក៏បានរាយការណ៍មកថាការអភិវឌ្ឍអណ្តូងរ៉ែនោះពុំទាន់មានការរីកចម្រើនគួរឲ្យកត់សម្គាល់ទេ។

<u>សំណួរទី៣៖</u> តើលោកបានដឹងពីស្ថានភាពភូគព្ភសាស្ត្រដី នៅក្នុងតំបន់គម្រោងដែរឬទេ?

<u>ចម្លើយទី៣៖</u> តំបន់ទីតាំងអាជីវកម្មរ៉ែនេះ មានទីតាំងស្ថិតនៅក្នុងឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ តំបន់គម្រោងជាតំបន់ខ្ពង់រាបជាមួយតំបន់ភ្នំដែលមានកម្ពស់ទាប។ រយៈកម្ពស់ នេះបានថយចុះទៅដល់ទិសដៅនៃបឹងទន្លេសាប។ តំបន់នេះត្រូវបានគ្របដណ្តប់ដោយព្រៃឈើបៃតង និងជាតំបន់មានទឹកជំនន់ទាប ហើយគ្របដណ្តប់វាលស្រែ។

<u>សំណួរទី៤៖</u> តើតំបន់គម្រោងអាជីវកម្មរ៉ែមានលក្ខណៈសណ្ឋានដី ថ្ម និងរ៉ែ ដូចម្តេច?

<u>ចម្លើយទី៤៖</u> ដោយផ្អែកលើរបាយការណ៍របស់ក្រុមហ៊ុនធ្វើអាជីវកម្ម និងផែនទីភូមិសាស្ត្រដែលមានស្រាប់បានអោយដឹងថា តំបន់នេះគ្របដណ្តប់ដោយ eluvium និង alluvium ហើយមានល្បាប់ស្តើងមានភក់ ដីខ្សាច់គ្របដណ្តប់ធម្មតា។ សណ្ឋានស្រទាប់ក្រោមដីបានផ្សំពីសិលា និងសមាសធាតុដែលផ្សំពី ម៉ាក់ម៉ា និងថ្មភ្នំភ្លើងជាដើម។ ស្រទាប់នេះប្រែប្រួលតាម សណ្ឋានដីចាប់ពី ៥ ទៅ ៧ម៉ែត្រ។ រ៉ែទង់ដែងនេះត្រូវបានរកឃើញនៅក្នុងតំបន់គោល ២០ ប៉ែកនិរតី (Zone NE 20 SW)។

សំណួរទី៥៖ តើដីតំបន់នោះមានលក្ខណៈពិសេសខុសពីតំបន់ដទៃដែរឬទេ? បើមាន តើវាជាប្រភេទដីអ្វីខ្លះអ្វី?
ចម្លើយទី៥៖ សណ្ឋានដីខាងក្រោមជាថ្មភ្នំភ្លើងដែលបានជំនួសវិញដោយថ្មភក់ Mesozoic។ ចំណែកផ្នែកខាងលិចនៃសណ្ឋានដីខាងក្រោម ត្រូវបានរងផលប៉ះពាល់ពីការជ្រៀតចូលរបស់ថ្មក្រានីត ខណៈពេលដែលនៅប៉ែកខាងកើតមានតែល្បាប់ និងថ្មភក់ដែលត្រូវបានរកឃើញ។

សំណួរទី៦៖ តើការធ្វើអាជីវកម្មរ៉ែនេះ មានផលប៉ះពាល់ជាអវិជ្ជមានអ្វីខ្លះដល់ដីនៅតំបន់នោះ?
ចម្លើយទី៦៖ អណ្តូងរ៉ែទាំងនេះគឺស្ថិតនៅក្នុងតំបន់ដែលគ្មានមនុស្សរស់នៅឡើយ។ ប្រសិនបើមានការបើកចំហរណ្តៅរុករករ៉ែត្រូវបានអនុវត្តន៍សម្រាប់អណ្តូងរ៉ែ នោះដីព្រៃ និងព្រៃក្នុងតំបន់នេះនឹងត្រូវឈូសឆាយចេញ។

សំណួរទី៧៖ តើការធ្វើអាជីវកម្មរ៉ែទង់ដែងនេះ អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់តំបន់ជិតខាងឬទេ?
ចម្លើយទី៧៖ ដោយផ្អែកលើសណ្ឋានដីនៃតំបន់រុករករ៉ែនេះ គឺមិនប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនក្នុងតំបន់ទំនាបភាគខាងលិច និងភាគនិរតី បានលុះត្រាតែក្រុមហ៊ុនមានវិធានការការពារសុវត្ថិភាពបានត្រឹមត្រូវ។ ចំណែកផលប៉ះពាល់ដែលអាចមានដូចជា ការលេចធ្លាយទឹកអាស៊ីត ទឹកល្វ ចេញពីអណ្តូងរ៉ែ និងកន្លែងស្តុកសំណល់ទុកជាដើម។ លើសពីនេះ ក្រុមហ៊ុនត្រូវសាងសង់កន្លែងស្តុកទុកកាកសំណល់រ៉ែឱ្យមានត្រឹមត្រូវ និងមានរបៀបរៀបរយល្អដើម្បីការពារការចម្លងមេរោគពីអាស៊ីត។

សំណួរទី៨៖ តើលោកមានចំណាប់អារម្មណ៍ ឬការព្រួយបារម្ភយ៉ាងណាចំពោះគម្រោងអាជីវកម្មរ៉ែនេះ?
ចម្លើយទី៨៖ ខ្ញុំមិនអាចផ្តល់យោបល់ណាមួយឲ្យបានស៊ីជំរៅបានទេចំពោះគម្រោងអាជីវកម្មរ៉ែនេះ ដោយសារតែខ្ញុំគ្មានផែនការរុករកអោយបានច្បាស់លាស់របស់ក្រុមហ៊ុននេះ។

សំណួរទី៩៖ តើលោកគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដែរឬទេ? តើលោកចង់ឱ្យមានការអភិវឌ្ឍបែបនេះនៅក្នុងតំបន់របស់លោកផ្សេងទៀតឬទេ?
ចម្លើយទី៩៖ ខ្ញុំគាំទ្រចំពោះការអភិវឌ្ឍអណ្តូងរ៉ែទាំងអស់នៅក្នុងប្រទេសកម្ពុជាពីព្រោះវាអាចនឹងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិយើង។ ទោះជាយ៉ាងណា អាជ្ញាប័ណ្ណរុករករ៉ែត្រូវបានចេញសម្រាប់តែអណ្តូងរ៉ែដែលបានរកឃើញថាមានតម្លៃសេដ្ឋកិច្ចខ្ពស់ជាមួយនឹងផែនការគ្រប់គ្រងបរិស្ថានល្អ និងអាចទទួលយកបានតែប៉ុណ្ណោះ។

Draft

សំណួរទី១០៖ តើលោកមានសំណូមពរ និងអនុសាសន៍យ៉ាងដូចម្តេចខ្លះចំពោះគម្រោងអាជីវកម្មរ៉ែនេះ?

ចម្លើយទី១០៖ តាមយោបល់របស់ខ្ញុំ ខ្ញុំគិតថាគម្រោងអាជីវកម្មរ៉ែទង់ដែងនេះមិនគួរត្រូវបានធ្វើឡើងទេ ពីព្រោះរបាយការណ៍របស់ក្រុមហ៊ុនរ៉ែស្តីពីការគ្រប់គ្រងធនធាន និងផែនការរុករករ៉ែមិនច្បាស់លាស់ និងមិនទាន់គ្រប់គ្រាន់នៅឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំអាចទទួលយកបានចំពោះគម្រោងធ្វើអាជីវកម្មនេះក្នុងករណីដែលគម្រោងនេះផ្តល់នូវអត្ថប្រយោជន៍ខ្ពស់ដល់សេដ្ឋកិច្ចរបស់ប្រទេស និងមិនគ្មានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន នៅពេលដែលបញ្ចប់គម្រោង។

រូបភាព៦.៧៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយនាយកដ្ឋានភូគព្ភសាស្ត្ររាជធានីភ្នំពេញ

៦.៥ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន នៅសាលាឃុំខ្នាវ

៦.៥.១ មតិយោបល់លោកមេឃុំខ្នាវ

លោក គុញ ហ៊ីត មេឃុំខ្នាវ អាយុ៦៨ឆ្នាំ បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដូចខាងក្រោម៖

- សូមឲ្យក្រុមហ៊ុន MENG XIN HONG FA គួរតែធ្វើឱ្យមានប្រព័ន្ធគ្រប់គ្រងបច្ចេកទេសច្បាស់លាស់ ដើម្បីកុំឱ្យប៉ះពាល់សុខភាពប្រជាជនក្នុងតំបន់
- សូមឱ្យរដ្ឋាភិបាលជួយផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី ជូនប្រជាពលរដ្ឋក្នុងឃុំ
- សូមឱ្យរដ្ឋាភិបាលបញ្ជាឲ្យក្រុមហ៊ុនអាជីវកម្មរ៉ែទុកដាក់ និងគ្រប់គ្រងសាធាតុពុលឱ្យច្បាស់លាស់។

៦.៥.២ មតិយោបល់លោកប្រធានភូមិខ្នាវ

លោក ហេង តី មេភូមិខ្នាវ អាយុ ៧៦ឆ្នាំ បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដូចខាងក្រោម៖

- ខ្ញុំគាំទ្រចំពោះការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន MENG XIN HONG FA
- ខ្ញុំក៏មានការព្រួយបារម្ភមួយចំនួនផងដែរដូចជា គ្រោះធម្មជាតិនឹងអាចកើតមានឡើងក្រោយគម្រោងអនុវត្តន៍ត្រូវបានបញ្ចប់
- ខ្ញុំសំណូមពរក្រុមហ៊ុនជួយសាងសង់ផ្លូវ ២ខ្សែគឺ (១) ផ្លូវពីបឹងឈ្នួនទៅភូមិថ្មី ដែលមានប្រវែង១គ.ម និង (២) ផ្លូវពីភូមិជ្រៃមកភូមិខ្នាវ ដែលមានប្រវែង១គ.ម ដូចគ្នា។

៦.៥.៣ មតិយោបល់លោកប្រធានភូមិចុងស្ពាន

លោក មុត ឆៃ មេភូមិចុងស្ពាន បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដូចខាងក្រោម៖

- ខ្ញុំគាំទ្រចំពោះការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន MENG XIN HONG FA
- ខ្ញុំក៏មានសំណូមពរ ឱ្យក្រុមហ៊ុនមេត្តាផ្តល់ការងារដល់ប្រជាជនក្នុងតំបន់ផង (ជាកម្មកររបស់ក្រុមហ៊ុន)
- ខ្ញុំសង្ឃឹមថាក្រុមហ៊ុនមេត្តាយោគយល់ដល់ប្រជាជន

Draft

៦.៥.៤ មតិយោបល់លោកប្រធានភូមិរវៀង

លោក ធីវ ធឿន មេភូមិរវៀង អាយុ ៦៥ឆ្នាំ បានចូលរួមផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែងដូចខាងក្រោម៖

- ខ្ញុំយល់ឃើញថា គម្រោងនេះអាចនាំមកនូវផលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជន និងសម្បត្តិធម្មជាតិ
- តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែគាំទ្រគម្រោងអាជីវកម្មនេះ ព្រោះវាអាចផ្តល់ប្រយោជន៍ដល់រដ្ឋមួយចំណែកផងដែរ
- ខ្ញុំក៏សំណូមពរដល់រដ្ឋាភិបាល មេត្តាជួយដោះស្រាយវិវាទដីធ្លីរវាងក្រុមហ៊ុន និងប្រជាជន កុំឱ្យមានទំនាស់ដី ដូចការអភិវឌ្ឍកន្លងមក។



Draft

រូបភាព៦.៨៖ ការជួបសម្ភាសន៍ និងពិភាក្សាយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន

៦.៦ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយ ប្រជាពលរដ្ឋកំពុងរស់នៅក្បែរតំបន់អាជីវកម្មរ៉ែទង់ដែង ស្ថិតក្នុង ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប

កាលពីថ្ងៃទី៩-១០ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ៧:០០ព្រឹកដល់ម៉ោង ៥:០០ល្ងាច ក្រុមការងារគ្រីអេធីវ ហ្គ្រីន ឌីហ្សាញ បានជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាជនមូលដ្ឋានទាំង ៣ ភូមិនៃឃុំខ្វាវដែលនៅក្បែរតំបន់គម្រោងអាជីវកម្មរ៉ែទង់ដែង គឺភូមិខ្វាវ ភូមិរវៀង និងភូមិចុងស្ពាន។

ការផ្សព្វផ្សាយ និងពិភាក្សាជាសាធារណៈនេះ មានគោលបំណងជម្រាបដល់ប្រជាជនក្បែរតំបន់គម្រោងអាជីវកម្មបានដឹងលឺពីគម្រោង និងដើម្បីធ្វើការស្ទាបស្ទង់ពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះគម្រោងនេះ ថាតើប្រជាពលរដ្ឋមានការគាំទ្រចំពោះគម្រោងនេះ ឬមានសំណូមពរបែបណាខ្លះចំពោះអាជីវកម្មនេះរបស់ក្រុមហ៊ុននៅក្នុងតំបន់គម្រោង។

៦.៦.១ ការគាំទ្រចំពោះអាជីវកម្មរ៉ែ

តាមលទ្ធផលនៃការសម្ភាសប្រជាជនក្នុងភូមិទាំងបីនៅក្នុងឃុំខ្វាវ ប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងដែលមានចំនួន៩២គ្រួសារ បានបង្ហាញថាប្រជាជននៅក្នុងឃុំភាគច្រើនមានការគាំទ្រទៅលើគម្រោងធ្វើអាជីវកម្ម។ ជាក់ស្តែងប្រជាជនចំនួន៩៤.៩១%នៅក្នុងភូមិខ្វាវមានការគាំទ្រទៅលើគម្រោងនៅខណៈដែលប្រជាជនត្រឹមតែ១.៨៤%ដែលមិនគាំទ្រ និង ៣.២៣%ដែលគ្មានយោបល់។ លើសពីនេះ ប្រជាជននៅក្នុងភូមិចុងស្ពានចំនួន៧៥% បានគាំទ្រគម្រោង ហើយមានប្រជាជនត្រឹមតែ២៥%ដែលមិនគាំទ្រចំពោះគម្រោង។ លើសពីនេះទៅទៀត ប្រជាជនចំនួន ៨៣.៣៣% នៅក្នុងភូមិរវៀងក៏មានការគាំទ្រ នៅខណៈដែលអ្នកមិនគាំទ្រចំពោះគម្រោងនេះមានចំនួនត្រឹមតែ១៦.៦៧%ប៉ុណ្ណោះ។ មូលហេតុដែលប្រជាជនធ្វើការគាំទ្រគម្រោងធ្វើអាជីវកម្មរ៉ែនេះ ពីព្រោះពួកគាត់គិតថាការអភិវឌ្ឍអាចផ្តល់ការងារ មានការអភិវឌ្ឍក្នុងតំបន់ និងមានការរីកចំរើនហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ជាពិសេសផ្លូវថ្នល់ អណ្តូងទឹក និងសាលារៀនសម្រាប់ក្មេងៗជំនាន់ក្រោយ។ ចំពោះប្រជាជនដែលមិនគាំទ្រចំពោះគម្រោងនេះ ដោយសារតែពួកគាត់គិតថាគម្រោងអភិវឌ្ឍធ្វើអាជីវកម្មរ៉ែនេះអាចនឹងពង្រីកសក្តានុពលរបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់ដីស្រែ ចំការ រ៉ែភ្នំ ព្រៃឈើ សត្វព្រៃ និងជីវចម្រុះក្នុងទឹក (ត្រូវទទួលរងនូវការបំពុល)។ ជាពិសេស ពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យចូលទៅប្រកបរបរកសិកម្ម លើដីស្រែ ចំការ របស់ពួកគាត់ដូចមុនទៀតឡើយ។



ក្រាហ្វិក៦.១៖ ភាគរយរបស់ប្រជាជនដែលគាំទ្រទៅលើគម្រោងអាជីវកម្មរ៉ែ

៦.៦.២ ទស្សនៈរបស់ប្រជាជនចំពោះអាជីវកម្មរ៉ែ

តាមរយៈការសង្កេតដោយផ្ទាល់ និងការវិភាគទិន្នន័យដែលទទួលបានពីការសម្ភាសប្រជាជន ៩២គ្រួសារបានបង្ហាញថាប្រជាជននៅក្នុងឃុំខ្វារមានមតិយល់ស្របចំពោះការធ្វើអាជីវកម្មរ៉ែទង់ដែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពួកគាត់សំណូមពរឱ្យអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែ មេត្តាជួយស្ថាបនាផ្លូវថ្នល់ ជាពិសេសផ្លូវក្រាលកៅស៊ូ សាលារៀន ប្រព័ន្ធទឹកស្អាត អណ្តូងទឹក ទុកតំបន់សម្រាប់គង្វៀលសត្វពាហនៈដូចជាគោក្របី ផ្លូវទៅចំការ និងជាពិសេសសូមជួយបញ្ចៀសផលប៉ះពាល់នានាដូចជា ការបំពុលដោយសារធាតុគីមី សំណល់រាវ និងសំណល់រឹងពីតំបន់អាជីវកម្មរ៉ែមកលើបរិស្ថាននៅក្នុងតំបន់ជុំវិញគម្រោង។

៦.៨ សង្ខេបលទ្ធផលនៃការពិគ្រោះយោបល់លើកទី១

យោងតាមលទ្ធផលនៃការជួបពិគ្រោះ និងពិភាក្សាជាមួយមន្ទីរពាក់ព័ន្ធនៅក្នុងខេត្តសៀមរាប អាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងបានបង្ហាញថាគម្រោង **ធ្វើអាជីវកម្មរ៉ែទង់ដែង**នៅក្នុងស្រុកជីក្រែងមានការគាំទ្រពីប្រជាជននៅក្នុងភូមិទាំងបី ដោយមានចំនួនភាគរយខ្ពស់។ តាមក្រាហ្វិក៥.១ បានបង្ហាញថា ប្រជាជននៅក្នុងភូមិខ្វារមានរហូតដល់ ៩១,៩៤% ប្រជាជននៅក្នុងភូមិចុងស្ពានមាន ៧៥% និងប្រជាជននៅក្នុងភូមិរវៀងមាន ៨៣,៣៣% បានគាំទ្រលើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ។ នៅខណៈដែលប្រជាជនដែលមិនគាំទ្រចំពោះគម្រោងនេះមានត្រឹមតែ៤,៨៤% នៅក្នុងភូមិខ្វារ ២៥%នៅភូមិចុងស្ពាន និង

១៦,៦៧%នៅភូមិរវៀង។ តាមតារាង៥.២ ក៏បានបង្ហាញពីការគាំទ្ររបស់មន្ទីរដែលពាក់ព័ន្ធទាំងអស់នៅក្នុងខេត្តសៀមរាប និងអាជ្ញាធរភូមិឃុំទាំងអស់ទៅលើគម្រោងធ្វើអាជីវកម្មរ៉ែនេះផងដែរ។ មូលហេតុដែលធ្វើឲ្យពួកគាត់មានការគាំទ្រចំពោះគម្រោងនេះ ដោយសារតែពួកគាត់គិតថាក្រុមហ៊ុននឹងជួយសម្រួលដល់ជីវភាពគ្រួសាររបស់ប្រជាជនឲ្យកាន់តែមានភាពប្រសើរឡើងជាងមុន តាមរយៈការផ្តល់ឱកាសការងារ និងការអភិវឌ្ឍន៍ដល់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងភូមិឃុំឲ្យមានភាពប្រសើរជាងមុន។ ទន្ទឹមនឹងការគាំទ្រពួកគាត់ក៏មាននូវសំណូមពរមួយចំនួនផងដែរ ជាពិសេសទាក់ទងទៅនឹងបញ្ហាការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ ដែលចេញពីការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន និងសូមឲ្យក្រុមហ៊ុនអនុវត្តន៍ទៅតាមបច្ចេកទេសត្រឹមត្រូវ ស្របតាមគោលនយោបាយដែលបានកំណត់ដោយរដ្ឋាភិបាល ជាពិសេសក្រុមហ៊ុនផ្តល់ប្រឹក្សា។ តែទោះជាយ៉ាងណា ក៏មានមតិមិនពេញចិត្តមួយចំនួនផងដែរទៅលើគម្រោងធ្វើអាជីវកម្មនេះ។ មូលហេតុដែលធ្វើឲ្យមានការមិនពេញចិត្ត ដោយសារតែពួកគាត់គិតថាគម្រោងអាជីវកម្មនេះអាចធ្វើឲ្យមានការប៉ះពាល់ដីស្រែនិងដីចំការរបស់ពួកគាត់។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៦.៣៖ សេចក្ដីសង្ខេបនៃយោបល់ និងសំណូមពររបស់អាជ្ញាធរ

ល.រ	គោត្តនាម+ នាម	តួនាទី	គាំទ្រការអភិវឌ្ឍ	មិនគាំទ្រការអភិវឌ្ឍ	យោបល់/សំណូមពរ
១	ឯកឧត្តម គឹម ឆៃហៀង	អភិបាលរង ខេត្តសៀមរាប	✓		គាត់មានអនុសាសន៍ចុងក្រោយ៖ ▪ សូមក្រុមហ៊ុនផ្ញើរបាយការណ៍រៀងរាល់ត្រីមាស ឬឆមាស និងរបាយការវិសមញ្ញ ▪ សូមឱ្យក្រុមហ៊ុនយកចិត្តទុកដាក់ពីបញ្ហាសង្គម កុំឱ្យប៉ះពាល់ប្រជាជន ▪ សូមឱ្យក្រុមហ៊ុនយកចិត្តទុកដាក់ពីបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ការពារការហុយធូលីដី ជាពិសេស បញ្ហាបរិស្ថានដោយបញ្ចៀសឱ្យបាននូវផលប៉ះពាល់អតិប្បរមា ▪ សូមក្រុមហ៊ុន មេត្តាកុំកេងប្រវ័ញ្ចទៅលើកម្លាំងពលកម្មកម្មករ ▪ សូមឱ្យក្រុមហ៊ុនគោរព ច្បាប់ការងារ ស្តង់ដារតាមបច្ចេកទេស និងសៀវភៅបន្ទុកដែលជាកិច្ចសន្យារវាង CDC ▪ ក្រោយបញ្ចប់គម្រោង ក្រុមហ៊ុនត្រូវលប់ដីវិញដាំដើមឈើ ដាំដើមឈើឡើងវិញ ▪ គាត់គាំទ្រពេញទំហឹងចំពោះការអភិវឌ្ឍដែលស្របច្បាប់ និងលើកទឹកចិត្តចំពោះការអភិវឌ្ឍបែបនេះ។
២	លោក ភួង លីណា	ប្រធានមន្ទីរបរិស្ថាន ខេត្តសៀមរាប	✓		គាត់មានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖ ▪ សូមស្នើរឱ្យរាល់គម្រោងវិនិយោគ គួរតែមានការពាក់ព័ន្ធចូលរួមទាំងអស់ និងមានភាពស្និទស្នាល ដើម្បីធ្វើការងាយស្រួល និងរលូន ▪ គួរធ្វើឱ្យផលប៉ះពាល់ស្ថិតក្នុងកំរិតទាប ▪ កាត់បន្ថយ កែសម្រួល និងនិយាយឱ្យច្បាស់ថាតើផលប៉ះពាល់កំរិតណា និងដោះស្រាយបានកំរិតតិចបំផុត។

Draft

ល.រ	គោត្តនាម+ នាម	តួនាទី	គាំទ្រ ការអភិវឌ្ឍ	មិនគាំទ្រ ការអភិវឌ្ឍ	យោបល់/សំណូមពរ
៣	លោក នួន គ្រីស្នា	ប្រធានមន្ទីរធនធានទឹក និងឧត្តុនិយម ខេត្តសៀមរាប	✓		គាត់មិនជំទាស់នឹងការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនឡើយ ប៉ុន្តែគាត់មានការព្រួយបារម្ភមួយចំនួនដូចជា៖ ▪ ការលេចជ្រាបសមាសធាតុរ៉ែដែលបានស្តុកទុក ▪ ផលប៉ះពាល់សុខភាពកម្មករ និងប្រជាជន ▪ គុណភាពដីកសិកម្ម និងទិន្នផលកសិកម្ម ▪ គុណភាពទឹកប្រើប្រាស់ក្នុងតំបន់ គាត់គាំទ្រឱ្យមានការអភិវឌ្ឍ បើក្រុមហ៊ុនវិនិយោគមានលក្ខណៈបច្ចេកទេសគ្រប់គ្រាន់ ព្រមទាំងមានការគាំទ្រពីរដ្ឋាភិបាល។
៤	លោក ទា គឹមសុទ្ធ	នាយខ័ណរដ្ឋបាលព្រៃឈើ ខេត្តសៀមរាប	✓		គាត់មានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖ ▪ លុបរណ្តៅរ៉ែ និងស្តារគម្របព្រៃ នៅពេលបញ្ចប់គម្រោងអាជីវកម្មរ៉ែ
៥	លោក មាស ជូវ៉ានី	ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប	✓		គាត់មានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖ ▪ សូមឱ្យក្រុមហ៊ុនសហការណ៍ជាមួយមន្ទីរពាក់ព័ន្ធឱ្យបានជិតស្និទ និងគ្រាប់គ្រាន់តាមប្រព័ន្ធបច្ចេកវិទ្យា ▪ សូមក្រុមហ៊ុនគោរពតាមអាជ្ញាប័ណ្ណដែលបានទទួល ▪ សូមក្រុមហ៊ុនផ្តល់របាយការណ៍សមញ្ញ និងវិសមញ្ញដល់មន្ទីរពាក់ព័ន្ធ ▪ សូមឲ្យមានអ្នកតំណាងក្រុមហ៊ុន ដើម្បីងាយស្រួលក្នុងការធ្វើទំនាក់ទំនង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ល.រ	គោត្តនាម+ នាម	តួនាទី	គាំទ្រ ការអភិវឌ្ឍ	មិនគាំទ្រ ការអភិវឌ្ឍ	យោបល់/សំណូមពរ
៦	លោក មៅ ចំរើន	អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តសៀមរាប	✓		គាត់គាំទ្រចំពោះការអភិវឌ្ឍ ដែលមិនប៉ះពាល់ដល់ប្រជាពលរដ្ឋ ឬបរិស្ថាន។ ចំពោះសំណូមពរគឺះ ▪ ក្រុមហ៊ុនត្រូវអនុវត្តន៍ទៅតាមនិតិវិធីច្បាប់ ▪ ក្រុមហ៊ុនគួរតែមានទំនាក់ទំនងជាមួយស្ថាប័នថ្នាក់ក្រោម ▪ គួរតែចុះបញ្ជីដីធ្លីមុនការដ្ឋានដំណើរការ ដើម្បីជៀសវាងបាតុភាពកើតឡើង ▪ ប្រសិនបើមានការប៉ះពាល់ ក្រុមហ៊ុនត្រូវអនុវត្តន៍តាមសារាចរណ៍ ០១។
៨	លោក ង៉ូវ សេងកាក់	ប្រធានមន្ទីរទេសចរណ៍ ខេត្តសៀមរាប	✓		គាត់មានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជាះ ▪ ក្រុមហ៊ុនត្រូវតែសិក្សាឱ្យជាក់លាក់ និងល្អិតល្អន់ដើម្បីជៀសវាងផលប៉ះពាល់នៅមូលដ្ឋាន ▪ ក្រុមហ៊ុនគួរតែមានវេទិកាពិភាក្សា មុននឹងធ្វើអាជីវកម្ម ▪ រាល់គម្រោងត្រូវឆ្លងកាត់ក្រុមប្រឹក្សាខេត្ត ▪ រាល់លិខិតបទដ្ឋានគួរតែមានពីថ្នាក់ក្រោមជាតិ ទៅថ្នាក់ជាតិ ទើបមានប្រសិទ្ធភាព ▪ តាមទស្សនៈរបស់ខ្ញុំគាំទ្រ តែគួរផ្តល់ប្រយោជន៍ដល់សហគមន៍ផង។
៩	លោក នឹម សុន	ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប	✓		គាត់គាំទ្រតាមគោលការណ៍រដ្ឋាភិបាល តែខ្ញុំមានសំណូមពរះ ▪ ពេលក្រុមហ៊ុនធ្វើការវិនិយោគទៅប្រទះឃើញបេតិវប្បធម៌ សូមថែរក្សាការពារទុកជាកេរ្តិ៍មរតក ▪ កំណត់បរិវេណការពារលេខ ០១ របស់វប្បធម៌ ▪ សូមវិនិយោគក្នុងលក្ខណៈអភិរក្សនោះកេរ្តិ៍តំណែលនឹងមិនបាត់បង់ឡើយ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ល.រ	គោត្តនាម+ នាម	តួនាទី	គាំទ្រ ការអភិវឌ្ឍ	មិនគាំទ្រ ការអភិវឌ្ឍ	យោបល់/សំណូមពរ
					▪ ត្រូវវិធានការដោះស្រាយរាល់ពេលមានការប៉ះពាល់ប្រជាជនមូលដ្ឋានព្រមទាំងប្រពៃណី វប្បធម៌ និងសេដ្ឋកិច្ច សង្គម ត្រូវដោះស្រាយកុំឱ្យមានទំនាស់។
១០	លោក សៀន សុថាម	ប្រធាននាយកដ្ឋាន ភូគព្ភសាស្ត្ររាជធានីភ្នំពេញ	✓		គាត់មានយោបល់ថា គម្រោងអាជីវកម្មរ៉ែទង់ដែងនេះមិនគួរត្រូវបានធ្វើឡើង ព្រោះរបាយការណ៍របស់ក្រុមហ៊ុនរ៉ែស្តីពីការគ្រប់គ្រងធនធាន និងផែនការរុករករ៉ែមិនច្បាស់លាស់នៅឡើយ។ ចំពោះផែនការរុករករ៉ែដែលអាចទទួលយកបាន ជាផែនការដែលផ្តល់នូវអត្ថប្រយោជន៍ខ្ពស់ដល់សេដ្ឋកិច្ចរបស់ប្រទេសនោះ និងបរិស្ថានដែលអាចស្តារឡើងវិញបាន បន្ទាប់ពីការបិទអណ្តូងអាជីវកម្មរ៉ែ ។
១១		ប្រធានអាជ្ញាធរអប្សរា ខេត្តសៀមរាប			
១២	លោក គុញ ហ៊ត	ប្រធានឃុំខ្វាវ	✓		គាត់ក៏មានមតិយោបល់ និងសំណូមពរដូចខាងក្រោម៖ ▪ ក្រុមហ៊ុន MENG XIN HONG FA គួរតែធ្វើឱ្យមានប្រព័ន្ធគ្រប់គ្រងបច្ចេកទេសច្បាស់លាស់ ដើម្បីកុំឱ្យប៉ះពាល់សុខភាពប្រជាជនក្នុងតំបន់ ▪ សុំឱ្យរដ្ឋាភិបាលជួយផ្តល់ប័ណ្ណដីកម្មសិទ្ធ ជូនប្រជាពលរដ្ឋក្នុងឃុំ ▪ សុំឲ្យរដ្ឋាភិបាលបញ្ជាឲ្យក្រុមហ៊ុនអាជីវកម្មរ៉ែ ទុកដាក់ និងគ្រប់គ្រងសាធាតុពុលឲ្យច្បាស់លាស់
១៣	លោក ហេង ភី	មេភូមិខ្វាវ	✓		គាត់ក៏មានមតិយោបល់ និងសំណូមពរដូចខាងក្រោម៖ ▪ គាត់គាំទ្រចំពោះការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន MENG XIN HONG FA

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ល.រ	គោត្តនាម+ នាម	តួនាទី	គាំទ្រការអភិវឌ្ឍ	មិនគាំទ្រការអភិវឌ្ឍ	យោបល់/សំណូមពរ
					▪ គាត់ក៏មានការព្រួយបារម្ភមួយចំនួនផងដែរដូចជា គ្រោះធម្មជាតិកើតឡើងក្រោយពេលគម្រោងត្រូវបានបញ្ចប់ ▪ គាត់សំណូមពរក្រុមហ៊ុនជួយសាងសង់ផ្លូវ ២ខ្សែគឺ (១) ផ្លូវពីបឹងឈ្នួនទៅភូមិថ្មី ដែលមានប្រវែង១គ.ម និង (២) ផ្លូវពីភូមិជ្រៃមកភូមិខ្វារ ដែលមានប្រវែង១គ.ម ដូចគ្នា
១៤	លោក មុត ផៃ	មេភូមិចុងស្ពាន	✓		គាត់ក៏មានមតិយោបល់ និងសំណូមពរដូចខាងក្រោម៖ ▪ គាត់គាំទ្រចំពោះការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន MENG XIN HONG FA ▪ គាត់ក៏មានសំណូមពរ ឱ្យក្រុមហ៊ុនមេត្តាផ្តល់ការងារដល់ប្រជាជនក្នុងតំបន់ផង (ជាកម្មកររបស់ក្រុមហ៊ុន MENG XIN HONG FA ▪ គាត់សង្ឃឹមថាក្រុមហ៊ុនមេត្តាយោគយល់ និងដោះស្រាយដីធ្លីនៅក្នុងគម្រោងធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់ដីប្រជាជន
១៥	លោក ធីវ ធឿន	មេភូមិរវៀង	✓		▪ គាត់យល់ឃើញថា គម្រោងនេះនាំមកនូវផលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជន និងសម្បត្តិធម្មជាតិ ▪ តែទោះបីយ៉ាង គាត់នៅតែគាំទ្រគម្រោងអាជីវកម្មនេះ ព្រោះវាអាចផ្តល់ប្រយោជន៍ដល់រដ្ឋមួយចំណែកសំខាន់ដែរ ▪ គាត់ក៏សំណូមពរដល់រដ្ឋាភិបាល មេត្តាជួយដោះស្រាយវិវាទដីធ្លីរវាងក្រុមហ៊ុន និងប្រជាជន កុំឲ្យមានទំនាស់ ដូចការអភិវឌ្ឍកន្លងមក។

Draft

៦.៩ ការពិគ្រោះយោបល់ជាមួយសាលាខេត្តសៀមរាប និងមន្ទីរដែលពាក់ព័ន្ធលើកទី២

ការពិគ្រោះយោបល់លើកទី២ត្រូវបានធ្វើឡើងដោយការប្រជុំពិភាក្សា ដែលមានការចូលរួមពីមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធជាច្រើន។ ការប្រជុំនេះត្រូវបានធ្វើនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ០៨:០០ព្រឹក នៅសាលាខេត្តសៀមរាប ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ស៊ិន រុន** អភិបាលរងខេត្តសៀមរាប និងមាន **លោក ទូស សារឿន** ប្រធានក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** ជាអ្នកធ្វើបទបង្ហាញស្ដីពីលទ្ធផល នៃរបាយការណ៍សិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញនៃគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ។ ការប្រជុំពិភាក្សានេះមានមតិយោបល់ និងអនុសាសន៍ដូចមានរៀបរាប់ខាងក្រោម៖

រូបភាព៦.៩៖ កិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ក្រោមអធិបតីភាព ឯកឧត្តមស៊ិន រុន

៦.៩.១ ការបញ្ចេញមតិយោបល់របស់អភិបាលរងខេត្តសៀមរាប

ឯកឧត្តម ស៊ិន រុន អភិបាលខេត្តរងខេត្តសៀមរាប ដែលជាគណៈអធិបតីនៃការប្រជុំពិភាក្សានេះ មានប្រសាសន៍ និងមតិចូលរួមដូចខាងក្រោម៖

- ការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញមានភាពជាក់លាក់ ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយដែលអាចទទួលយកជាការបាន។ តែទោះជាយ៉ាងណា នៅក្នុងឯកសារនេះ ត្រូវតែកំណត់ឲ្យបានច្បាស់ពីទំហំផ្ទៃដីដែលមានការប៉ះពាល់ដោយសារមីន និងគ្រប់មិនទាន់ផ្ទុះ។ លើសពីនោះទៅទៀត ចំពោះការគ្រប់គ្រងសំណល់រឹង- រាវ គួរតែមានផែនការរៀបចំ និងគ្រប់គ្រងឲ្យបានល្អប្រសើរ បើពុំដូច្នោះទេ សំណល់រាវ នឹងអាចហូរចូលប្រភពទឹកផ្សេងៗដែលនៅជុំវិញតំបន់គម្រោង។

- គម្រោងធ្វើអាជីវកម្មនេះ មិនមែនប៉ះពាល់តែប្រជាជនដែលរស់នៅក្នុងឃុំខ្វាវទេ វាអាចប៉ះពាល់ដល់ប្រជាជនដែលរស់នៅតាមដងស្ទឹង និងដងទន្លេសាបប្រសិនបើក្រុមហ៊ុនមិនបានគ្រប់គ្រងសំណល់របស់ខ្លួនឲ្យបានត្រឹមត្រូវ។ ជុំវិញនៃបញ្ហានេះដែរ ប្រភពទឹកចំបងរបស់ប្រជាពលរដ្ឋក្នុងភូមិខ្វាវគឺបឹងធ្នួន ដែលជាការព្រួយបារម្ភមួយផងដែរ។

- បញ្ហាបេតិកភ័ណ្ឌប្រវត្តិសាស្ត្រ ឃើញមានវត្តមានក្នុង និងក្បែរតំបន់គម្រោងហេតុដូចនេះ សូមឲ្យក្រុមហ៊ុនមានផែនការថែរក្សា ដោយមានបង្ហាញនៅលើផែនទី និងគម្រោងប្លង់ទាំងមូល។

- តំបន់នេះជាតំបន់ព្រៃ ដែលកាលពីដើមឡើយប្រជាពលរដ្ឋបានអាស្រ័យផលតែលើអនុផលព្រៃឈើនេះតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នប្រហែលជាមានការផ្លាស់ប្តូរទំនៀមទំលាប់នៃការរស់នៅ និងមុខរបររបស់គាត់ ដែលអាចនិយាយបានថាគម្រោងមិនបានធ្វើឲ្យមានការប៉ះពាល់ដល់មុខរបររបស់គាត់។

- ឃើញថាក្រុមហ៊ុនបានជួយអភិវឌ្ឍន៍ភូមិឃុំបានច្រើនដូចជា សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនទៀត។ តែទោះជាយ៉ាងណាក៏សូមឲ្យក្រុមហ៊ុនបន្តនៃការជួយអភិវឌ្ឍន៍ភូមិឃុំនេះបន្តទៀត និងគិតគូរទៅលើសុខភាព និងសុខុមាលភាពរបស់ប្រជាជនបន្ថែមទៀត។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

រូបភាព៦.១០៖ ឯកឧត្តមស៊ិន រុន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២

Draft

៦.៩.២ ការបញ្ចេញមតិយោបល់របស់ប្រធានមន្ទីរបរិស្ថាន

លោក តួច លីណា ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប បានមានមតិយោបល់ ជុំវិញបញ្ហានៃរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅៈ

- ចំពោះការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនកុងស៊ុលតង់ ឃើញមានការចាប់អារម្មណ៍ជាខ្លាំងទៅលើចំណុចផ្សេងៗជាច្រើន។ ចំណុចដែលគួរចាប់អារម្មណ៍ជាងគេគឺ វិធានការណ៍នៃការគ្រប់គ្រងសំណល់រឹង-រាវ ការបំពុលដោយសូរសំលេង និងរំញ័រ និងបញ្ហាគុណភាពខ្យល់។ តំណាងឲ្យមន្ទីរបរិស្ថានខេត្តសូមស្នើរសុំឲ្យក្រុមហ៊ុនធ្វើការវិភាគ និងវាយតម្លៃឲ្យបានលំអិត និងច្បាស់លាស់អំពីបញ្ហានេះ។

- ម៉្យាងទៀត លោកបានស្នើរសុំឲ្យក្រុមហ៊ុនកុងស៊ុលតង់បញ្ជាក់ឲ្យបានច្បាស់ពីលំហូរនៃខ្សែទឹក ពីព្រោះប្រជាជនភាគច្រើន នៅក្នុងភូមិប្រើប្រាស់ប្រភពទឹកបឹង ដែលនៅផ្នែកខាងក្រោមនៃតំបន់គម្រោង ដើម្បីបំពេញតម្រូវការនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។

- ចំពោះគម្រោងធ្វើអាជីវកម្មរ៉ែ លោកមិនទាន់បានចុះទៅត្រួតពិនិត្យដល់ការដ្ឋានដោយផ្ទាល់នៅឡើយទេ រាល់ពត៌មានដែលបានដឹង គឺទទួលបានតាមរយៈការចុះមកសម្ភាសន៍របស់ក្រុមហ៊ុនប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក៏ដោយ លោកមានមតិយោបល់មួយចំនួនផងដែរទៅលើវិធានការគ្រប់គ្រងការបំពុលបរិស្ថាន ឲ្យបានល្អប្រសើរបំផុតទាំងមុនពេលគម្រោងមានដំណើរការ នៅពេលគម្រោងកំពុងដំណើរការ និងនៅពេលដែលបញ្ចប់គម្រោង។ ជាពិសេស បញ្ហានៃការគ្រប់គ្រងសំណល់រឹង-រាវ បញ្ហាគុណភាពខ្យល់ គុណភាពសំលេង និងរំញ័រ។

- ចំណែកឯសំណល់រឹង ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែទង់ដែង គួរតែមានការបែងចែកជាពីរប្រភេទគឺ សំណល់រឹងដែលចេញពីសកម្មភាពប្រចាំថ្ងៃរបស់បុគ្គលិក និងកម្មករ និងសំណល់រឹងដែលចេញពីសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែ។

- ចំពោះបញ្ហាការបំពុលខ្យល់ ត្រូវចាត់វិធានការណ៍គ្រប់គ្រងឲ្យបានត្រឹមត្រូវពីព្រោះការបំពុលខ្យល់មិនត្រឹមតែបំពុលនៅក្នុងតំបន់គម្រោងអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចបំពុលទៅដល់តំបន់ផ្សេងៗទៀតតាមរយៈការសាយភាយផងដែរ។ ម៉្យាងវិញទៀត ចំពោះការប្រើប្រាស់ទឹករបស់ប្រជាជន ដែលរស់នៅជុំវិញតំបន់គម្រោងក៏អាចទទួលរងនូវផលប៉ះពាល់ពីការហូរច្រោះ នៃសំណល់រាវចេញពីតំបន់គម្រោងចូលក្នុងប្រភពទឹកដែលពួកគាត់ប្រើប្រាស់ប្រចាំថ្ងៃផងដែរ។

- ទោះជាយ៉ាងណាក៏ដោយ លោកនៅតែមានការព្រួយបារម្ភណ៍ជាខ្លាំងទៅលើបច្ចេកទេស នៃការរៀបចំទុកដាក់សំណល់ទាំងនេះអោយបានត្រឹមត្រូវទៅតាមបច្ចេកទេសនៃការគ្រប់គ្រងសំណល់រឹង-រាវ និងសំណល់រ៉ែនេះផងដែរ។ លើសពីនេះទៅទៀត គម្រោងអាជីវកម្មរ៉ែនេះ ជាប្រភេទអាជីវកម្មរ៉ែដែលមានលក្ខណៈបើកចំហរ ទាំងការជីក ការដឹកជញ្ជូន និងការបំបែកថ្មរ៉ែ ដែលងាយធ្វើឲ្យមានការបំពុលបរិស្ថាន។ លើសពីនេះ នៅជុំវិញតំបន់គម្រោងមានធនធានសង្គម ធនធានព្រៃឈើ ស្ពាន និងប្រាសាទបុរាណ និងប្រភពទឹកស្ទឹងសំខាន់ៗដែលនឹងអាចទទួលរងនូវផលប៉ះពាល់ពីតំបន់គម្រោង។

- ចំពោះការវិភាគសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លោកបានមានយោបល់ថា ហាក់បីដូចជាគ្មានតុល្យភាពរវាងថវិការចំណេញដែលក្រុមហ៊ុនបានទទួលរហូតដល់ ១៩០លានដុល្លា/ឆ្នាំ

និងថវិការមូលនិធិបរិស្ថាន ដែលសងសម្រាប់ការខូចខាតដល់បរិស្ថានមានត្រឹមតែ៦ម៉ឺនដុល្លា/ឆ្នាំប៉ុណ្ណោះ។ លោកគិតថាថវិការនេះមានភាពតិចតួចបើធៀបទៅនឹងធនធានបរិស្ថានដ៏ច្រើនសន្ធឹកសន្ធាប់ និងធនធានសង្គម-សេដ្ឋកិច្ចនៅជុំវិញតំបន់គម្រោង។

រូបភាព៦.១១៖ លោក ភួង ឌីណា ប្រធានមន្ទីរបរិស្ថាន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២

៦.៩.៣ ការបញ្ចេញមតិយោបល់របស់ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប

លោក មាស ផូរ៉ានី ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប បានមានមតិយោបល់ជុំវិញបញ្ហា លើរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គម្រោងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅ៖

- សូមឲ្យក្រុមហ៊ុនកុងស៊ុលតង់ បង្ហាញរូបផែនទីទីតាំងប្រាសាទ អូរ ទីតាំងមីន ទីតាំងព្រៃអភិរក្ស និងតំបន់ដែនជំរកសត្វព្រៃបឹងពែរ និងកំណត់អោយបានច្បាស់ពីទីតាំងដែលត្រូវជីកយករ៉ែ និងទីតាំងដែលត្រូវរក្សាទុកមិនឲ្យមានការប៉ះពាល់។

- ចំពោះទីតាំងនៃគម្រោងជីកយករ៉ែ ជាប្រភេទអណ្តូងរ៉ែបើក ដូច្នេះ ព្រៃឈើទាំងអស់នៅក្នុងតំបន់គម្រោង ត្រូវតែកាប់ដើម្បីយកទីតាំងសំរាប់ការធ្វើអាជីវកម្មរ៉ែ។ លោកចង់ឲ្យមានការបំភ្លឺឲ្យបានច្បាស់ពីបែបបទនៃការជីកយករ៉ែនេះ ថាជាការជីកដោយបើកចំហ ឬដោយរូង ។
- ចំពោះការសិក្សាស្រាវជ្រាវពីតំបន់ដែលត្រូវធ្វើអាជីវកម្ម គួរតែជៀសវាងទីតាំងដែលមានប្រាសាទបុរាណនានា ពីព្រោះនៅក្នុងតំបន់គម្រោងមានទីតាំងប្រាសាទបុរាណ។
- ចំពោះសារធាតុគីមីដែលប្រើប្រាស់ក្នុងការដកហូតយកសារធាតុរ៉ែទង់ដែង គឺក្រុមហ៊ុនធ្វើអាជីវកម្មប្រើប្រាស់ កំបោរស និងអំបិល។ ប៉ុន្តែ ក្រុមហ៊ុនមិនបានបញ្ជាក់ឲ្យបានច្បាស់ពីប្រភេទនៃកំបោរសដែលត្រូវបានប្រើនៅក្នុងការដកហូតនេះទេ ហើយក៏មិនមានព័ត៌មានណាមួយដែលបញ្ជាក់ឲ្យបានច្បាស់ថា បន្ទាប់ពីការដកហូតសារធាតុរ៉ែរួចហើយ តើសារធាតុកំបោរស និងអំបិល នឹងអាចមានអុកស៊ីតកម្ម រឺប្រតិកម្មជាមួយសារធាតុដទៃទៀតដែររឺអត់នោះទេ។
- លោកមានសំណូមពរមួយចំនួនដែលពាក់ព័ន្ធទៅលើ ការរក្សាទុកនូវព្រៃឈើនៅក្នុងតំបន់គម្រោង។ លោកមានការព្រួយបារម្ភចំពោះការបើកឲ្យមានដំណើរការជីករុករករ៉ែដែលអាចធ្វើឲ្យមានការកាប់បំផ្លាញព្រៃឈើ។ លើសពីនេះ ចំពោះការស្រាវជ្រាវរុករករ៉ែ លោកបានសំណូមពរឲ្យក្រុមហ៊ុនរក្សាទុកតំបន់មួយចំនួនដែលមានប្រាសាទបុរាណ។

រូបភាព៦.១២៖ លោកមាស ផូវ៉ានី ប្រធានមន្ទីររ៉ែ និងថាមពល ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២

៦.៩.៤ ការបញ្ចេញមតិយោបល់របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប

លោក ម៉ូ ជុំសម្បត្តិ អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប បានមានមតិយោបល់ ជុំវិញបញ្ហានៃរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅ៖

- លោកបានស្នើរសុំឲ្យក្រុមហ៊ុនអនុវត្តន៍ទៅតាមផែនការមេ ដោយធ្វើការជីកយករ៉ែនៅឆ្ងាយពីតំបន់ដែលមានប្រជាជនរស់នៅ និងឆ្ងាយពីប្រាសាទបុរាណ។ លើសពីនេះលោកក៏បានស្នើរសុំឲ្យគ្រប់ហ៊ុនកុងស៊ុលតង់ សិក្សាឲ្យបានច្បាស់លាស់ទៅលើស្ថានភាពជីវភាពរបស់ប្រជាជននៅជុំវិញតំបន់គម្រោង។ម្យ៉ាងទៀត លោកក៏បានស្នើរសុំឲ្យមានរបាយការណ៍ស្តីពី សារធាតុពាក់កណ្តាលសំរេចរបស់ធាតុទង់ដែង ថាសារធាតុនេះមានផ្ទុកសារធាតុរ៉ែប៉ុន្មានភាគរយ។ ម៉្យាងវិញទៀត លោកបានមានយោបល់ថា ប្រសិនបើក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែទង់ដែងអាចជីករ៉ែដោយប្រើវិធីសាស្ត្រជីករូង វាប្រសើរជាងការជីកដោយវិធីសាស្ត្របើកចំហរ ហើយក្រុមហ៊ុនត្រូវបញ្ជាក់ឲ្យបានច្បាស់ពីមធ្យោបាយនៃការចំពោះសារធាតុបំពុល និងសំណល់រាងចុងក្រោយ។
- ក្រុមហ៊ុនមិនបានបញ្ជាក់ពីទំហំដីស្រែចំការ របស់ប្រជាជន និងតំបន់ដែលមានប្រាសាទបុរាណនៅជុំវិញតំបន់គម្រោងដែលទទួលផលប៉ះពាល់ដោយគម្រោង ហើយត្រូវដកចេញនៃទំហំផ្ទៃដីទាំងអស់នោះយ៉ាងណាទេ។ ប៉ុន្តែលោកបានស្នើរឲ្យកាត់ដីដែលប៉ះពាល់ទាំងអស់នោះចេញ ដើម្បីជៀសវាង មានបញ្ហាទៅថ្ងៃក្រោយរវាងប្រជាជន អាជ្ញាធរ និងម្ចាស់គម្រោងអាជីវកម្ម។
- ប្រសិនបើ នៅក្នុងតំបន់គម្រោងមានប៉ះពាល់ដីស្រែ ចម្ការ រឹកសិកម្មពនេតចរ របស់ប្រជាជននៅជុំវិញតំបន់គម្រោង តើក្រុមហ៊ុនមានដំណោះស្រាយយ៉ាងណាបញ្ហានេះ។ ហើយប្រសិនបើមានបញ្ហាដូចខាងលើនេះ មិនមែនមានតែក្រុមហ៊ុនអាជីវកម្មពិបាកប៉ុណ្ណោះទេ វានឹងអាចមានផលវិបាកដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស អាជ្ញាធរខេត្ត។
- លោកមានចំងល់ខ្លះៗទៅលើវិធីសាស្ត្រ នៃការជីកយករ៉ែតាមលក្ខណៈអណ្តូងបើកចំហ និងអណ្តូងរូង ថាតើក្រុមហ៊ុនអាចអនុវត្តន៍តាមវិធីសាស្ត្រជីកអណ្តូងរូងដូចនៅប្រទេសផ្សេងៗបានដែររឺទេ ប្រសិនបើអាចអនុវត្តន៍បានដូចប្រទេសដទៃ នោះផលប៉ះពាល់ទៅលើបរិស្ថាន នឹងមានកម្រិតតិចជាងវិធីសាស្ត្របើកចំហរ។

Draft



រូបភាព៦.១៣៖ លោកបូ ជុំ សម្បត្តិ អនុប្រធានមន្ទីរ រៀបចំដែនដីនគរូនីយកម្ម និងសំណង់ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២

៦.៩.៤ ការបញ្ចេញមតិយោបល់របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប

លោក រី អញ្ញលី អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប បានមានមតិយោបល់ ជុំវិញបញ្ហានៃរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាប កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅ៖

- លោកធ្លាប់បានឃើញប្រាសាទនៅក្នុងផែនទីរបស់ឯកសារបារាំង។ ប៉ុន្តែលោកមិនទាន់ច្បាស់ពីដំណឹងរបស់ប្រាសាទនៅក្នុងតំបន់គម្រោងនៅឡើយទេ ពីព្រោះ ប្រាសាទមួយចំនួនមានត្រឹមតែឈ្មោះនៅក្នុងផែនទី ប៉ុន្តែជាក់ស្តែងប្រាសាទខ្លះអាចកប់ចូលក្នុងដីដែលមិនអាចមើលឃើញ។ រីឯប្រាសាទមួយចំនួនទៀត មានឈ្មោះច្រើនទៅតាមការហៅឈ្មោះរបស់អ្នកភូមិ ហេតុដូចនេះ ចំពោះការពាន់ព័ន្ធ ទៅនឹងប្រាសាទបុរាណក្នុងតំបន់គម្រោង លោកនឹងស្រាវជ្រាវឯកសារបន្ថែមទៀត។

- តាមច្បាប់ប្រសិនបើក្នុងតំបន់គម្រោងមានប្រសាទ ឬទីទួលបុរាណ គឺក្រុមហ៊ុនមិនអាចប៉ះពាល់បានទេ។ ហេតុដូចនេះ ស្នើរក្រុមហ៊ុនសូមឲ្យរក្សាទុកតំបន់ប្រាសាទដោយហាមមិនឲ្យមានការប៉ះពាល់។

រូបភាព៦.១៨៖ លោក រី អញ្ញលី អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈក្នុងកិច្ចប្រជុំលើកទី២

Draft

៦.៩.៦ ការបញ្ចេញមតិយោបល់របស់អភិបាលស្រុកជីក្រែង

លោក ពៅ ប៊ុនធឿន អភិបាលស្រុកជីក្រែង បានមានមតិយោបល់ លើរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របស់គម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកមានការព្រួយបារម្ភណ៍ចំពោះដីស្រែចម្ការរបស់ប្រជាជន និងការធ្វើកសិកម្មពនេតចររបស់ពួកគាត់នៅជុំវិញតំបន់គម្រោង ព្រមទាំងខ្លាចមានការតវ៉ាពីពួកគាត់ផងដែរ។ ម្យ៉ាងវិញទៀត លោកពុំទាន់បានទទួលទិន្នន័យស្តីពី ទំហំដីប៉ះពាល់ ឬមានដីប៉ះពាល់នៅក្នុងតំបន់គម្រោងនេះនៅឡើយទេ។

- បឹងឈ្នួន ដែលជាប្រភពទឹកមួយដ៏សំខាន់នៅក្នុងភូមិក្បែរតំបន់គម្រោងសម្រាប់បំរើដល់សកម្មភាពប្រចាំថ្ងៃរបស់ប្រជាជន។ ដូច្នេះ ប្រសិនបើមានបញ្ហា ការហូរច្រោះសារធាតុបំពុលចេញពីតំបន់ធ្វើអាជីវកម្មរ៉ែទង់ដែង ចូលទៅក្នុងប្រភពទឹកដ៏សំខាន់នោះ ប្រជាជននៅក្នុងភូមិប្រាកដជាគ្មានប្រភពទឹកសំរាប់ប្រើប្រាស់ប្រចាំថ្ងៃឡើយ។
- ចំពោះក្តីបារម្ភណ៍ទីបី គឺការប៉ះពាល់ទៅលើមុខរបររបស់ប្រជាជន ដូចជា ការធ្វើកសិកម្ម ពនេតចរ និងការរកអនុផលព្រៃឈើ។
- ផ្ទុយទៅវិញ ការអនុវត្តគម្រោងអាជីវកម្មរ៉ែនេះ ក៏មានផលល្អផងដែរ ជាពិសេស អាចទប់ស្កាត់ចំពោះការកាប់បំផ្លាញព្រៃខុសច្បាប់ពីប្រជាជន និងឈ្មួញទុចរិតមួយចំនួន។ លើសពីនេះ ប្រសិនបើគម្រោងធ្វើអាជីវកម្មនេះមានដំណើរការល្អ នោះនឹងអាចផ្តល់ឱកាសការងារដល់ លើកស្ទួយកម្រិតជីវភាពប្រជាជននៅក្នុងភូមិ និងមានចំណូលចូលរដ្ឋ។

រូបភាព៦.១៥៖ លោក ពៅ ប៊ុនធឿន អភិបាលស្រុកជីក្រែងក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២

៦.៩.៧ ការបញ្ចេញមតិយោបល់របស់មន្ទីរធនធានទឹក

លោក យូ ចំរើន ប្រធានការិយាល័យនៃមន្ទីរធនធានទឹក បានមានមតិយោបល់ ជុំវិញបញ្ហានៃរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅៈ

- បទបង្ហាញរបស់ក្រុមហ៊ុនកុងស៊ុលតង់ ដែលបានធ្វើឡើងមានភាពល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ដោយសារក្រុមហ៊ុនបានសិក្សាលំអិតទៅលើគុណភាពទឹក គុណភាពខ្យល់ គុណភាពសំលេង និងរំញ័រ និងវិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹង-រាវ និងសំណល់អាចម៍រ៉ែ។
- តែទោះជាយ៉ាងណាក៏ដោយ មន្ទីររបស់លោកមានភារៈកិច្ចគ្រប់គ្រងទាំងទឹកលើដី និងទឹកក្រោមដី ដូច្នេះលោកចង់ដឹងឲ្យបានច្បាស់ពីរយៈពេលនៃការបញ្ចេញសំណល់រាវរបស់ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែទង់ដែង ថាតើនៅក្នុងរយៈពេលប៉ុន្មានដែលទឹកសំណល់ទាំងនោះអាចហូរចូលទៅក្នុងប្រភពទឹកដែលប្រជាជនកំពុងប្រើប្រាស់ ពីព្រោះលោកមានក្តីបារម្ភណ៍ចំពោះសុខភាពរបស់ប្រជាជនដែលរស់នៅជុំវិញតំបន់គម្រោង។
- ចំពោះការជីកយករ៉ែនេះ នឹងអាចប៉ះពាល់ដល់ប្រភពទឹក ស្ទឹង បឹង និងអូរដែលនៅជិតៗតំបន់គម្រោង។

រូបភាព៦.១៦៖ លោក យូ ចំរើនប្រធានការិយាល័យនៃមន្ទីរធនធានទឹកក្នុងកិច្ចប្រជុំលើកទី២

៦.៩.៨ ការបញ្ចេញមតិយោបល់របស់មន្ទីរទេសចរណ៍

លោក សោ វិសិទ្ធ អនុប្រធានមន្ទីរទេសចរណ៍ បានមានមតិយោបល់ លើរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របស់គម្រោងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅ៖

- នៅក្នុងតំបន់ធ្វើអាជីវកម្មរ៉ែទង់ដែងមានភ្នំ ព្រៃព្រឹក្សា ស្ពានបុរាណ និងប្រាសាទបុរាណ។ ដូច្នេះ មន្ទីរទេសចរណ៍ក៏មានគោលការពង្រីកទស្សនៈវិស័យរបស់ខ្លួនទៅដល់តំបន់នោះផងដែរ ពីព្រោះ ទាំងក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍តែងតែមានផែនការពង្រីកតំបន់ទាក់ទាញភ្ញៀវទេសចរណ៍របស់ខ្លួននៅគ្រប់តំបន់ដែលមាន ព្រៃឈើ ធម្មជាតិ ស្រស់បំព្រង និងសំណង់ប្រវត្តិសាស្ត្រ។
- លោកមានសំណូមពរចំពោះក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែទង់ដែង ឲ្យធ្វើយ៉ាងណា បញ្ចៀសផលប៉ះពាល់ទៅលើធនធានដ៏មានតម្លៃសំរាប់វិស័យទេសចរណ៍ ដូចជា ភ្នំ ព្រៃប្រឹក្សា ស្ពានបុរាណ ប្រាសាទបុរាណ និងសំណង់ប្រវត្តិសាស្ត្រដ៏ទៃទៀតនៅក្នុងតំបន់គម្រោង ពីព្រោះនៅប្រទេសកម្ពុជា ជាតំបន់ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ។

រូបភាព៦.១៧៖ លោក សោ វិសិទ្ធ អនុប្រធានមន្ទីរទេសចរណ៍ក្នុងកិច្ចប្រជុំលើកទី២

៦.៩.៩ ការបញ្ចេញមតិយោបល់របស់ខណ្ឌរដ្ឋបាលព្រៃឈើ

លោក សូ ផល្លា នាយកផ្នែកខណ្ឌរដ្ឋបាលព្រៃឈើ បានមានមតិយោបល់ លើរបាយការណ៍តំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សំរាប់គម្រោងធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន **ម៉េង ស៊ីន ហុងហ្វា** ក្នុងកិច្ចប្រជុំនៅសាលាខេត្តសៀមរាបកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥មានដូចតទៅ៖

- លោកសំណូមពរសុំឲ្យក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែទង់ដែង ធ្វើសារពើភ័ណ្ឌព្រៃឈើឲ្យបានច្បាស់លាស់ ដើម្បីឲ្យដឹងពីប្រភេទព្រៃឈើលេខ១ លេខ២ និងលេខ៣ ឲ្យបានច្បាស់សម្រាប់បង់ព័ន្ធជូនរដ្ឋ។
- ក្រុមហ៊ុនធ្វើអាជីវកម្ម ជីករ៉ែដោយប្រើប្រាស់វិធីសាស្ត្ររណ្ដៅបើក ដូចនេះ វាធ្វើឲ្យមានការប៉ះពាល់ទៅដល់ព្រៃឈើខ្លាំងជាងការជីកដោយរណ្ដៅរូង ប៉ុន្តែប្រសិនបើ ចាំបាច់ត្រូវជីករ៉ែតាមវិធីសាស្ត្ររណ្ដៅបើកនោះ ក្រុមហ៊ុនត្រូវតែសហការជាមួយអ្នកជំនាញរដ្ឋបាលព្រៃឈើ ដើម្បីចុះពិនិត្យ និងធ្វើសារពើភ័ណ្ឌ។

រូបភាព៦.១៨៖ លោក សូ ផល្លា ប្រធានផ្នែកខណ្ឌរដ្ឋបាលព្រៃឈើក្នុងកិច្ចប្រជុំលើកទី២

Draft

តារាង៦.៤៖ សង្ខេបការពិគ្រោះយោបល់លើកទី២ នៅសាលាខេត្តសៀមរាប

លរ	នាម+គោត្តនាម	តួនាទី	រូបភាព	យោបល់ និងអនុសាសន៍
១	ឯកឧត្តម ស៊ិន រុន	អភិបាលរង ខេត្តសៀមរាប		- ការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញបានល្អ - ត្រូវកំណត់ពីផ្ទៃដីដែលមានមីន និងគ្រប់មិនទាន់ផ្ទុះ - សំណល់រឹង-រាវត្រូវមានផែនការគ្រប់គ្រងឲ្យបានល្អ - គម្រោងនេះ អាចមានការប៉ះពាល់ប្រជាជនឃុំខ្វាវ និងប្រជាជនដែលរស់នៅតាមដងស្ទឹង - បេតិកភ័ណ្ឌប្រវត្តិសាស្ត្រ សូមឲ្យថែរក្សា - តំបន់នេះជាតំបន់ព្រៃកាលពីដើមឡើយប្រជាពលរដ្ឋបានអាស្រ័យផលតែលើអនុផលព្រៃឈើតែបច្ចុប្បន្នមានការផ្លាស់ប្តូរ ទៅលើមុខរបររបស់គាត់ - ក្រុមហ៊ុនបានជួយអភិវឌ្ឍន៍ភូមិឃុំបានច្រើនដូចជាសាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនទៀត - សូមឲ្យក្រុមហ៊ុនបន្ត ការអភិវឌ្ឍភូមិឃុំនេះបន្តទៀត។

២	លោក ភួង លីណា	ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប		- ក្រុមហ៊ុនធ្វើការត្រូវវិភាគលំអិត ពីវិធានការណ៍គ្រប់គ្រងសំណល់រឹង-រាវ ការបំពុលដោយសូរសំលេង និងរំញ័រ និងបញ្ហាគុណភាពខ្យល់ជាដើម - ស្នើរសុំឲ្យក្រុមហ៊ុនកុងស៊ុលតង់បញ្ជាក់ឲ្យបានច្បាស់ពីលំហូរនៃខ្សែទឹកព្រោះប្រជាជនភាគច្រើនប្រើទឹកបឹង - សំណល់រឹង ក្រុមហ៊ុនគួរតែមានការបែងចែករវាងសំណល់រឹងចេញពីបុគ្គលិក និងសំណល់រឹងដែលចេញពីសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែ - ការបំពុលខ្យល់ ត្រូវគ្រប់គ្រងឲ្យបានត្រឹមត្រូវ - នៅជុំវិញតំបន់គម្រោងមានធនធានសង្គម ធនធានព្រៃឈើ ស្ពាន និងប្រាសាទបុរាណ និងប្រភពទឹកស្ទឹងសំខាន់ៗ ដែលនឹងអាចទទួលរងនូវផលប៉ះពាល់ពីតំបន់គម្រោង - ការវិភាគសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូចជាគ្មានតុល្យភាពរវាងថវិការចំណេញ និងថវិការមូលនិធិបរិស្ថាន ដែលថវិការនេះតិចតួចបើធៀបទៅនឹងធនធានបរិស្ថានដ៏ច្រើនសន្ធឹកសន្ធាប់ និងធនធានសង្គម-សេដ្ឋកិច្ចនៅជុំវិញតំបន់គម្រោង។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៣	លោក មាស ផូវ៉ានី	ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប		- សូមឲ្យក្រុមហ៊ុនកុងស៊ុលតង់ បង្ហាញរូបផែនទីទីតាំងប្រាសាទ អូរ ទីតាំងមីន ទីតាំងព្រៃអភិរក្ស និងតំបន់ដែនជំរកសត្វព្រៃបឹងពែរ និងកំណាត់អោយបានច្បាស់ពីទីតាំងដែលត្រូវជីកយករ៉ែ និងទីតាំងដែលត្រូវរក្សាទុកមិនឲ្យមានការប៉ះពាល់។ - ការជីកយករ៉ែ ជាប្រភេទអណ្តូងរ៉ែបើក ដូចច្នេះ ព្រៃឈើទាំងអស់នៅក្នុងតំបន់គម្រោង ត្រូវតែកាប់ដើម្បីយកទីតាំងសំរាប់ការធ្វើអាជីវកម្មរ៉ែ។ - ការសិក្សាស្រាវជ្រាវពីតំបន់ដែលត្រូវធ្វើអាជីវកម្ម គួរតែជៀសវាងទីតាំងដែលមានប្រាសាទបុរាណ - សារធាតុគីមីប្រើប្រាស់ក្នុងការដកហូតយកសារធាតុរ៉ែទង់ដែង គឺកំបោរស និងអំបិលដូចនេះសូមឲ្យក្រុមហ៊ុនបញ្ជាក់ប្រភេទកំបោរស និងអំបិល - លោកមានការព្រួយបារម្ភចំពោះ ការជីករុករករ៉ែ ដែលអាចធ្វើឲ្យមានការកាប់បំផ្លាញព្រៃឈើ។ - ស្នើរឲ្យក្រុមហ៊ុនរក្សាទុកតំបន់មួយចំនួនដែលមានប្រាសាទបុរាណ។

៤	លោក ប៊ូ ជុំសម្បត្តិ	អនុប្រធាន មន្ទីររៀបចំដែនដី នគរូនីយកម្ម និងសំណង់ ខេត្តសៀម		- សូមស្នើរសុំឲ្យក្រុមហ៊ុនអនុវត្តន៍ទៅតាមផែនការមេ - ក្រុមហ៊ុនកុងស៊ុលតង់ សិក្សាឲ្យបានច្បាស់ទៅលើស្ថានភាពជីវភាពប្រជាជននៅជុំវិញតំបន់គម្រោង - បញ្ជាក់ពីទំហំដីស្រែចំការ និងតំបន់ដែលមានប្រាសាទដែលទទួលផលប៉ះពាល់ដោយគម្រោង - ស្នើរឲ្យកាត់ដី ដែលប៉ះពាល់ពីតំបន់គម្រោងចេញ ដើម្បីជៀសវាង មានបញ្ហាទៅថ្ងៃក្រោយរវាងប្រជាជនអាជ្ញាធរ និងម្ចាស់គម្រោងអាជីវកម្ម - បញ្ជាក់ឲ្យបានច្បាស់វិធីសាស្ត្រនៃការជីកយករ៉ែតាមលក្ខណៈរណ្ដៅបើក ឬរណ្ដៅរូង
៥	លោក រី អញ្ញលី	អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប		- លោកធ្លាប់បានឃើញប្រាសាទនៅក្នុងផែនទីរបស់ឯកសារបារាំង - លោកមិនទាន់ច្បាស់ពីដំណឹងរបស់ប្រាសាទនៅក្នុងតំបន់គម្រោងនៅឡើយទេ - ប្រាសាទមួយចំនួនមានត្រឹមតែឈ្មោះនៅក្នុងផែន ប៉ុន្តែវាអាចកប់ចូលក្នុងដី - ប្រាសាទមួយចំនួនទៀត មានឈ្មោះច្រើនទៅតាមការហៅឈ្មោះរបស់អ្នកភូមិ ខុសពីឈ្មោះក្នុងផែនទី

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៦	លោក ពៅ ប៊ុនធឿន	អភិបាលស្រុកជីក្រែង		- ដីស្រែចម្ការ និងការធ្វើកសិកម្មពនេតចររបស់ប្រជាជននៅជុំវិញតំបន់គម្រោងជាបញ្ហាដែលគួរឲ្យព្រួយបារម្ភ - អាជ្ញាធរស្រុកមិនទាន់បានទទួលទិន្នន័យពី ទំហំដីប៉ះពាល់នៅក្នុងតំបន់គម្រោងនៅឡើយទេ - អាចមានបញ្ហាចំពោះការប្រើប្រាស់ទឹករបស់ប្រជាជន - អាចប៉ះពាល់ទៅលើមុខរបររបស់ប្រជាជន - គម្រោងនេះអាចទប់ស្កាត់ចំពោះការកាប់បំផ្លាញព្រៃខុសច្បាប់ពីប្រជាជន និងឈ្មួញទុច្ចរិតមួយចំនួន - អាចផ្តល់ឱកាសការងារ និងលើកស្ទួយកម្រិតជីវភាពប្រជាជននៅក្នុងភូមិ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ
៧	លោក យូ ចំរើន	ប្រធានការិយាល័យនៃមន្ទីរធនធានទឹក		- បទបង្ហាញមានភាពល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ - ឃើញបានសិក្សាលំអិតទៅលើគុណភាពទឹក គុណភាពខ្យល់ គុណភាពសំលេង និងរំញ័រ និងវិធីសាស្ត្រនៃការគ្រប់គ្រងសំណល់រឹង-រាវ និងអាចម៍រ៉ែ។ - លោកមានក្តីបារម្ភចំពោះសុខភាពរបស់ប្រជាជនដែលរស់នៅជុំវិញតំបន់គម្រោង។ - ចំពោះការជីកយករ៉ែនេះ នឹងអាចប៉ះពាល់ដល់ប្រភពទឹក ស្ទឹង បឹង និងអូរដែលនៅជិតៗតំបន់គម្រោង

៨	លោក សោ វិសិទ្ធ	អនុប្រធានមន្ទីរទេសចរណ៍		- ក្រសួង និងមន្ទីរទេសចរណ៍តែងតែមានផែនការពង្រីកតំបន់ទាក់ទាញភ្ញៀវទេសចរណ៍របស់ខ្លួននៅគ្រប់តំបន់ដែលមាន ព្រៃឈើ ធម្មជាតិស្រស់បំព្រង និងសំណង់ប្រវត្តិសាស្ត្រ - ក្រុមហ៊ុន គួរធ្វើយ៉ាងណា ដើម្បីបញ្ចៀសផលប៉ះពាល់ទៅលើធនធាននៅជុំវិញតំបន់គម្រោង។
៩	លោក សូ ផល្លា	នាយកផ្នែកខណ្ឌរដ្ឋបាលព្រៃឈើ		- ក្រុមហ៊ុនអាជីវកម្មរ៉ែទង់ដែងធ្វើសារពើភ័ណ្ឌព្រៃឈើឲ្យបានច្បាស់លាស់ - កំណត់ប្រភេទព្រៃឈើលេខ១ លេខ២ និងលេខ៣ ឲ្យបានច្បាស់សម្រាប់បង់ពន្ធជូនរដ្ឋ - ក្រុមហ៊ុនធ្វើអាជីវកម្ម គួរតែប្រើប្រាស់វិធីសាស្ត្ររណ្តៅបើក ដើម្បីកាត់បន្ថយនូវហេតុប៉ះពាល់ - បើគ្មានជំរើសក្រៅពីវិធីសាស្ត្ររណ្តៅបើក ក្រុមហ៊ុនត្រូវតែសហការជាមួយអ្នកជំនាញរដ្ឋបាលព្រៃឈើ ដើម្បីចុះពិនិត្យ និងធ្វើសារពើភ័ណ្ឌ។

៦.១០ សង្ខេបលទ្ធផលនៃការប្រជុំពិភាក្សាពិគ្រោះយោបល់លើកទី២

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅសាលាខេត្តសៀមរាប ដែលមាន**ឯកឧត្តម ស៊ិន រុន** អភិបាលរងខេត្តសៀមរាប ជាគណៈអធិបតី និងមានក្រុមហ៊ុនទីប្រឹក្សា គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ ជាអ្នកធ្វើបទបង្ហាញ ព្រមទាំងមានមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធជាច្រើនបានមកផ្តល់យោបល់ និងអនុសាសន៍ផ្សេងៗដែលទាក់ទងនឹងគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងរបស់ក្រុមហ៊ុនម៉េង ស៊ិន ហ្វា បានបង្ហាញឲ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែក៏មានចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញបន្ថែមដូចជា៖

- ក្រុមហ៊ុនទីប្រឹក្សាត្រូវបង្ហាញពីទីតាំងមីន ទីតាំងប្រាសាទបុរាណ និងទីតាំងស្ពានបុរាណនៅលើផែនទី។ ប្រសិនបើមានបេតិកភ័ណ្ឌប្រវត្តិសាស្ត្រនៅក្នុងទីតាំងគម្រោង ម្ចាស់គម្រោងត្រូវមានផែនការគ្រប់គ្រងថែរក្សា ដោយធ្វើការកាត់ចេញមិនឲ្យមានការប៉ះពាល់។
- ចំពោះផែនការនៃការគ្រប់គ្រងសំណល់រឹង-រាវ ត្រូវកំណត់ឲ្យបានច្បាស់លាស់ ដើម្បីជៀសវៀងរាល់ការបំពុលនានាទៅលើបរិស្ថាន និងប្រជាពលរដ្ឋដែលនៅក្នុង និងក្បែរតំបន់គម្រោង។
- ការធ្វើអាជីវកម្មរ៉ែដោយប្រើប្រាស់វិធីសាស្ត្របើកចំហរនេះ អាចធ្វើឲ្យមានការប៉ះពាល់ដល់ព្រៃឈើ និងសត្វព្រៃក្នុងតំបន់គម្រោង ហេតុដូចនេះក្រុមហ៊ុនត្រូវសហការណ៍ជាមួយរដ្ឋបាលព្រៃឈើដើម្បីធ្វើសារពើភ័ណ្ឌព្រៃឈើបង់ពន្ធជូនរដ្ឋ។
- នៅក្នុងទីតាំងគម្រោងមិនមានដីប៉ះពាល់ ឬពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ តែទោះជាយ៉ាងណាក៏ធ្លាប់មានដីស្រែចំការពនេតចររបស់ប្រជាជនមួយចំនួនខ្លះដែរ ហេតុដូចនេះក្រុមហ៊ុនត្រូវមានវិធានការដោះស្រាយដើម្បីកុំឲ្យមានបញ្ហាទៅថ្ងៃក្រោយ។
- ឃើញថាក្រុមហ៊ុនបានជួយអភិវឌ្ឍន៍ភូមិឃុំបានច្រើនដូចជា សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនទៀត។ គម្រោងនេះក៏បានជួយកាត់បន្ថយរាល់បទល្មើសកាប់បំផ្លាញព្រៃឈើបានមួយចំនួនផងដែរ។
- ចុងក្រោយអាជ្ញាធរខេត្តសៀមរាប សូមធ្វើការគាំទ្រ និងជួយជំរុញការអភិវឌ្ឍន៍លើគម្រោងធ្វើអាជីវកម្មរ៉ែនេះ ឲ្យដំណើរការបានរហ័ស។

ជំពូកទី៧៖
ហេតុប៉ះពាល់បរិស្ថាន និង
វិធានការកាត់បន្ថយ

Draft

ជំពូកទី៧៖ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

៧.១- សេចក្តីផ្តើម

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមពេញលេញនេះ គឺជាការសិក្សាពេញលេញលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមដែលកើតមានឡើងដោយសារសកម្មភាពគម្រោងនៅក្នុងដំណាក់កាលនីមួយៗ ដូចជាដំណាក់កាលរចនាគម្រោង ដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិគម្រោង។ រាល់ហេតុប៉ះពាល់អវិជ្ជមានត្រូវរិះរកវិធានការកាត់បន្ថយយ៉ាងណាឲ្យដល់កម្រិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលទាំងនោះដោយមានការអនុវត្តពីម្ចាស់គម្រោង ព្រមទាំងកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញដែលពាក់ព័ន្ធក្នុងមូលដ្ឋាន និងមានការត្រួតពិនិត្យតាមរយៈខ្សែបណ្តោយពីក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

ក្នុងការវាយតំលៃនេះ ក្រុមហ៊ុនផ្តល់ប្រឹក្សាបានជ្រើសរើសយកតារាងបញ្ជីផ្ទៀងផ្ទាត់ (Checklist) និងតារាងម៉ាទ្រីក (Matrix) ដើម្បីកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលមានកម្រិតតិច មធ្យម និងខ្លាំងមកធ្វើការវិភាគ ព្រមទាំងរៀបចំវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនោះឲ្យ បានត្រឹមត្រូវទៅនឹងទំហំនៃហេតុប៉ះពាល់ជាអវិជ្ជមាន។

៧.២- វិធីសាស្ត្រ

វិធីសាស្ត្រសម្រាប់ប្រើប្រាស់នៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម គឺអាចប្រែប្រួលទៅតាមប្រភេទគម្រោងនីមួយៗ និងផ្អែកទៅលើបទពិសោធន៍ ឬទៅលើឯកសារដែលមានស្រាប់ (Existing literatures or past experiences) ចំពោះគម្រោងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។

វិធីសាស្ត្រដែលគេធ្លាប់ប្រើជាញឹកញាប់ រួមមានដូចខាងក្រោម៖

៧.២.១- វិធីសាស្ត្រតាមបញ្ជីផ្ទៀងផ្ទាត់ (Checklist)

វិធីសាស្ត្រនេះគឺជាបញ្ជីស្តង់ដារនៃប្រភេទហេតុប៉ះពាល់ ដែលទាក់ទងទៅនឹងប្រភេទនៃគម្រោងមួយជាក់លាក់ (Impact associated with a particular type of project)។ វិធីសាស្ត្រដោយប្រើបញ្ជីផ្ទៀងផ្ទាត់នេះ គេប្រើវាជាចំបងសម្រាប់រៀបចំព័ត៌មាន(Organizing information) ឬក៏ធានាឲ្យបានថាមិនមានហេតុប៉ះពាល់ណាមួយដែលអាចកើតមានឡើងត្រូវបានមើលរំលង ឬធ្វេសប្រហែសឡើយ (No potential impact is overlooked)។ ចំពោះបញ្ជីផ្ទៀងផ្ទាត់នេះគេក៏អាចប្រើបញ្ជីផ្ទៀងផ្ទាត់ដែលមានលក្ខណៈសាមញ្ញ (Simple Checklist) ដែលជាបញ្ជីកំណត់នូវប៉ារ៉ាម៉ែត្របរិស្ថានដោយមិនទាមទារឲ្យមានការប្រើគោលការណ៍ណែនាំ (Guideline) ថាតើប៉ារ៉ាម៉ែត្រទាំងនោះត្រូវបានវាស់យ៉ាងដូចម្តេចឡើយ។

៧.២.២- វិធីសាស្ត្រម៉ាទ្រីក (Matrix Methods)

នេះគឺជាម៉ាទ្រីកសម្រាប់កំណត់ភាពប្រទាក់គ្នា រវាងសកម្មភាពនានារបស់គម្រោងទៅនឹងហេតុប៉ះពាល់នៃសមាសធាតុបរិស្ថានដែលអាចកើតមានឡើង។ ម៉ាទ្រីកដែលមានភាពងាយស្រួលហើយគេនិយមប្រើជាងគេគឺម៉ាទ្រីក Phoenic Pulp Mill or Leopold Matrix ដោយបង្ហាញអំពីភាពប្រទាក់គ្នារវាងសមាសភាគបរិស្ថាន (Environmental components) ជាមួយនឹងសកម្មភាពនានារបស់គម្រោង។

៧.២.៣- វិធីសាស្ត្រប្រើប្រាស់គោលការណ៍ណែនាំតាមវិស័យដែលមានស្រាប់ (Sectorial guideline)

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវផ្អែកទៅលើឯកសារ ឬគោលការណ៍ណែនាំដែលមានស្រាប់ ពីព្រោះវាជួយបង្កើនល្បឿននៃការសិក្សាដោយផ្អែកលើបទពិសោធន៍ និងមេរៀនដែលទទួលបានចំពោះគម្រោងដែលមានលក្ខណៈស្រដៀងគ្នា ឧទាហរណ៍ដូចជាគោលការណ៍ណែនាំទូទៅសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញដែលបានប្រកាសឲ្យប្រើដោយក្រសួងបរិស្ថាននៅឆ្នាំ២០០៩។

៧.៣- ការកំណត់អត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថាន

ស្ថានភាពជាក់ស្តែងនៅក្នុងតំបន់គម្រោង និងសកម្មភាពរបស់គម្រោង បានបង្ហាញពីអត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានទៅលើគម្រោងតាមដំណាក់កាលនីមួយៗ ដែលមានឥទ្ធិពលជាវិជ្ជមាន ជាអវិជ្ជមាន និងគ្មានឥទ្ធិពលទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។

តារាង៧.១៖ តារាងកំណត់អត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោង

			ហេតុប៉ះពាល់អវិជ្ជមាន																				ហេតុប៉ះពាល់វិជ្ជមាន							
				ដំណាក់កាលមុនប្រតិបត្តិ					ដំណាក់កាលប្រតិបត្តិ												ដំណាក់កាលបញ្ចប់គម្រោង		ដំណាក់កាលមុនប្រតិបត្តិ			ដំណាក់កាលប្រតិបត្តិ			ដំណាក់កាលបញ្ចប់	
			ចំណាត់ថ្នាក់ទូទៅ	ការឈូសឆាយក្នុងតំបន់គម្រោង	ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ	ការហូរចូលនៃកម្មករសំណង់ និងសង់ទីលំនៅ	ការដឹកជញ្ជូនសម្ភារៈ និងចល័តគ្រឿងចក្រ	ដំណើរការបកអាចម៍ដី និងដឹកពន្លាយអាចម៍ដី	ការដឹកជញ្ជូនល្បាយអាចម៍រ៉ែ	ការស្តុកទុកអាចម៍រ៉ែមុនចំរាញ់	ដំណើរការបំបែកល្បាយអាចម៍រ៉ែឲ្យទៅជាម្សៅ	ការដកហូតយករ៉ែទង់ដែង	ការផ្គត់ផ្គង់ទឹក	ការផ្គត់ផ្គង់អគ្គិសនី	ការទុកដាក់សំណល់អាចម៍ដី	ការទុកដាក់សំណល់អាចម៍រ៉ែ	ការបញ្ចេញ និងស្តុកទុកសំណល់រាវ	ការបោះចោលសំណល់រឹងពីកម្មករ	ការដឹកជញ្ជូនសម្ភារៈចេញពីតំបន់គម្រោង	លំហូរចេញនៃកម្មករ (ការផ្លាស់ទី)	ការហូរចូលកម្មករសំណង់ (កំលាំងពលកម្ម)	ការសាងសង់ផ្លូវនៅតំបន់គម្រោង	ភាពប្រសើរឡើងនៃជីវភាពប្រជាជន	កាត់បន្ថយការធ្វើចំណាកស្រុកទៅក្រៅប្រទេស	បង្កើនសេដ្ឋកិច្ចមូលដ្ឋាន (ការលក់ដូររបស់ប្រជាជន)	កំណើនសេដ្ឋកិច្ចជាតិតាមរយៈការបង់ពន្ធរបស់ក្រុមហ៊ុន	ភាពប្រសើរឡើងនៃគុណភាពបរិស្ថាននាពេលអនាគត	ភាពប្រក្រតីនៃប្រជាជនរស់នៅតំបន់គម្រោង
ធនធានរូបសាស្ត្រ	1	សណ្ឋានដី	B-	B-	C	D	D	A-		C					C	B-												
	2	ការហូរច្រោះដី	C	C	C	D	D	B-		C					D	C	B-											
	3	គុណភាពដី	C	C	C	D	D	B-		C		C			D	B-	B-	D										
	4	គុណភាពទឹក	C	C	C	C	D	C		B-	B-	C	C		C	B-	B-	C										

	5	សំលេង / រំញ័រ	C	C	C	D	B-	B-	C	D	C	D		C		D			D									
	6	គុណភាពខ្យល់	C	C	C	C	B-	B-	C	B-	B-	C			C	D	C	C	D									
	7	ជលវិទ្យា	D	C	D	D		D		D						C												
ធនធានជីវសាស្ត្រ	1	ព្រៃឈើ	B-	B-	C	D		B-																				
	2	សត្វព្រៃ	B-	B-	C	C	C	B-																				
	3	ប្រព័ន្ធអេកូឡូស៊ីក្នុងទឹកទន្លេ	C	C		D		C				D					B-											
ធនធានសេដ្ឋកិច្ច និងសង្គម	1	ការតាំងទីលំនៅ	D	D		D	D	D	C											C								
	2	មុខរបរ និងប្រាក់ចំណូល	B-		B-		B-	B-											C	C	A+	A+		B+		A+		
	3	ការប្រើប្រាស់ដី	D	C		C		D																B+				
	4	ការប្រើប្រាស់ទឹក	D	D		D		D						B-					C	C								
	5	ការប្រើប្រាស់ថាមពល	D	D		D		D																				
	6	ហេដ្ឋារចនាសម្ព័ន្ធ	D	D		C	C	C														A+						
	7	ការអប់រំ	D	D		D	C	D														B+	B+					
	8	សុខភាពសាធារណៈ	C	C		C	C	C		C	C	D			C	C	B-	D				B+	B+			A+		
	9	វប្បធម៌/ប្រពៃណី	D	D		D		C	C				B-				C					B+						
	11	ជនជាតិដើមភាគតិច	D	D		D		D																				
	12	គ្រោះធម្មជាតិ និងប្រែប្រួលអាកាសធាតុ						C	C	C	C																	
ផ្សេងៗ	1	គ្រោះថ្នាក់ដោយការធ្លាក់ចូលក្នុងអណ្តូងរ៉ែ	C	D				C				C																

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ចំណាត់ថ្នាក់ (កម្រិត)៖

A-: ហេតុប៉ះពាល់អវិជ្ជមានខ្លាំង (ហេតុប៉ះពាល់បរិស្ថានតម្រូវឲ្យមានការត្រួតពិនិត្យក្នុងការកាត់បន្ថយហេតុប៉ះពាល់ឲ្យបានកំរិតអតិបរិមា)

B-: ហេតុប៉ះពាល់អវិជ្ជមានមធ្យម (ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានអាចកាត់បន្ថយបាន)

C: ហេតុប៉ះពាល់អវិជ្ជមានតិចតួច ឬហេតុប៉ះពាល់អវិជ្ជមានមិនប្រាកដប្រជា

D: គ្មានហេតុប៉ះពាល់បរិស្ថាន ឬ មិនតម្រូវឲ្យធ្វើការសិក្សាបន្ថែម

A+: ហេតុប៉ះពាល់ជាវិជ្ជមានខ្លាំង

B+: ហេតុប៉ះពាល់វិជ្ជមានគួរឲ្យកត់សំគាល់

៧.៤- ការពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន

គម្រោងអាជីវកម្មរ៉ែទង់ដែងរបស់ក្រុមហ៊ុន MENG XIN HONG FA (CAMBODIA) RESOURCES INVESTMENT CO.,LTD (**ម៉េង ស៊ីន ហុង ហ្វា (ខេមបូឌា) រីសស៍ អ៊ិនវេសមេន**) បានធ្វើអាជីវកម្មរ៉ែទង់ដែងលើទំហំផ្ទៃដីសរុប **៣៦០០ហិកតា** ។ ចំពោះផែនការប្រើប្រាស់ដីធ្លីរបស់ក្រុមហ៊ុនក្នុងតំបន់គម្រោងអាជីវកម្ម រួមមាន "**តំបន់ប្រើប្រាស់រួម**" (ការិយាល័យ ផ្ទះសម្រាប់កម្មករស្នាក់នៅ ម៉ាស៊ីនចម្រាញ់យករ៉ែ តំបន់សម្រាប់ផ្ទុកសំណល់អាចម៍ដី និងតំបន់សម្រាប់ផ្ទុកសំណល់អាចម៍រ៉ែ) និង **ការដ្ឋានជីករ៉ែទង់ដែង**។ ផ្អែកទៅលើទំហំ និងសកម្មភាពរបស់គម្រោងអាជីវកម្មរ៉ែ ដោយការប្រើតារាងបញ្ជីផ្ទៀងផ្ទាត់ (Checklist) អាចឲ្យយើងកំណត់បាននូវហេតុប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដែលអាចកើតមានឡើងនៅក្នុងដំណាក់កាលមុនប្រតិបត្តិ ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោងដូចបង្ហាញជូននៅក្នុងតារាងមាទ្រីក ៧.១ ខាងលើ។

៧.៤.១- ដំណាក់កាលរចនាគម្រោង (Project Design Phase)

ក. ការប៉ះពាល់ដីស្រែ-ចំការរបស់ប្រជាពលរដ្ឋឃុំខ្វាវ

គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ អាចមានការប៉ះពាល់ដីស្រែចំការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំខ្វាវ ព្រោះនៅភាគខាងលិចទីតាំងភ្នំរ៉ែនៃតំបន់គម្រោងនេះ មានវត្តមានដីស្រែចំការប្រជាជនដែលធ្លាប់អាស្រ័យផលជារៀងរាល់ឆ្នាំ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនមានផែនការជីកអណ្តូងរ៉ែនៅក្នុងទំហំ១គីឡូម៉ែត្រក្រឡា ក្នុងជំហានដំបូង មិនមានវត្តមានដីស្រែចំការនោះទេ។
- ក្រុមហ៊ុនអនុញ្ញាតឲ្យប្រជាជនអាចធ្វើស្រែចំការបានធម្មតា ដោយមិនមានការហាមឃាត់។
- នៅពេលក្រុមហ៊ុនជីករណ្តៅរ៉ែដល់ទីតាំងដីស្រែចំការប្រជាជន ក្រុមហ៊ុននឹងផ្តល់សំណងជូនប្រជាជនតាមជាក់ស្តែង។

ខ. ការប៉ះពាល់ធនធានព្រៃឈើ

ការត្រួសត្រាយរៀបចំផែនការមេសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ អាចឲ្យមានការប៉ះពាល់ការកាប់ដើមឈើ ជាពិសេសការសាងសង់អគារផ្សេងៗ។

Draft

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនមានផែនការជ្រើសរើសទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៅតាមសណ្ឋានដី ដើម្បីកាត់បន្ថយការឈូសឆាយដី និងកាប់ព្រៃ។
- រៀបចំប្លង់សាងសង់អគាររដ្ឋបាល និងផ្ទះកម្មករ ដោយជ្រើសរើសទីតាំងដែលមិនសូវសំបូរឈើ និងទីវាលរាប ដើម្បីកាត់បន្ថយការកាប់ដើមឈើ។
- ក្រុមហ៊ុនមិនកាប់ឈើក្នុងតំបន់គម្រោង ដើម្បីសាងសង់អគារផ្សេងៗក្នុងតំបន់គម្រោងទេ។

គ. ការប៉ះពាល់ទីតាំងប្រាសាទបុរាណ

នៅក្នុងតំបន់គម្រោងមានវត្តមានប្រសាទមួយដែលមានឈ្មោះថា ប្រសាទល្បើក ដែលជាប្រាសាទបាក់បែកនៅសល់តែតួប្រសាទ។ ចំណែកនៅតំបន់ក្បែរតំបន់គម្រោងក៏មានប្រសាទបាក់បែកមួយចំនួនទៀតដូចជា ប្រសាទភ្នំដុប ប្រសាទតាឥន្ទ និងប្រសាទប្រាំ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ចំពោះប្រសាទដែលនៅក្បែរតំបន់គម្រោង គឺមិនមានការប៉ះពាល់ទេព្រោះនៅក្រៅតំបន់គម្រោង។ ✓
- ចំពោះប្រសាទល្បើកដែលមានទីតាំងក្នុងតំបន់គម្រោង ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរ ដើម្បីធ្វើការអភិរក្ស និងថែរក្សា នឹងទុកគម្លាត ១៥០ម៉ែត្រ ជុំវិញប្រសាទមិនឲ្យមានការឈូសឆាយ និងប៉ះពាល់។
- អប់រំដល់បុគ្គលិក និងកម្មករមិនឲ្យមានការប៉ះពាល់ឬការបំផ្លាញដល់ប្រសាទ។

ឃ. ការប៉ះពាល់ដល់ការធ្វើអាជីវកម្មថ្មបាយក្រៀម

នៅលើផ្ទៃដីធ្វើអាជីវកម្មរ៉ែទង់ដែង ក្នុងទំហំផ្ទៃដី ៣៦គីឡូម៉ែត្រក្រឡានេះ មានក្រុមហ៊ុន២ផ្សេងទៀតដែលកំពុងធ្វើអាជីវកម្មជីកថ្មបាយក្រៀម។ ក្រុមហ៊ុនធ្វើអាជីវកម្មទាំង២នេះ មានឈ្មោះថា **មាស ណារិទ្ធិ** និង **ជា ណារី**។ ហេតុដូចនេះ ការធ្វើអាជីវកម្មរ៉ែទង់ដែងនេះអាចមានការប៉ះពាល់ដល់ការធ្វើអាជីវកម្ម ថ្មបាយក្រៀមនៃក្រុមហ៊ុនទាំងពីរ។ ដើម្បីដោះស្រាយបញ្ហាការប៉ះពាល់នេះ ក្រុមហ៊ុនមានវិធានការដូចខាងក្រោម៖

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- សហការជាមួយមន្ទីររ៉ែ និងថាមពល ដើម្បីកំណត់ព្រំរបស់ក្រុមហ៊ុន ដែលបានទទួលអាជ្ញាប័ណ្ណជីកថ្មបាយក្រៀម។

Draft

- អនុញ្ញាតឲ្យក្រុមហ៊ុនធ្វើអាជីវកម្ម ថ្មបាយក្រៀមបានធម្មតា ព្រោះថ្មបាយក្រៀមធ្វើអាជីវកម្មតែផ្នែកស្រទាប់ដីខាងលើ ចំណែករ៉ែធ្វើអាជីវកម្មក្នុងផ្នែកខាងក្រោម។

ង. អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

តាមការផ្តល់ពត៌មានរបស់នាយទាហានជើងចាស់នៅក្នុងភូមិខ្វាវបានឲ្យដឹងថា នៅក្នុងតំបន់គម្រោងមានបន្សល់នូវអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលអាចមានការប៉ះពាល់ដល់បុគ្គលិក-កម្មករនៅពេលប្រតិបត្តិការការងារ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននឹងសហការជាមួយ មជ្ឈមណ្ឌលកំចាត់មីននៅកម្ពុជា (CMAC) ដើម្បីសិក្សាស្រាវជ្រាវស្វែងរកទីតាំងមីនពិតប្រាកដ និងធ្វើការសំអាតមីន។
- ដាក់ស្លាកសញ្ញាសំគាល់ទីតាំងមីន ឲ្យបានច្បាស់ និងដាក់បំរាមហាមបុគ្គលិក និងកម្មករចូលក្នុងតំបន់ហាមឃាត់។
- អប់រំដល់បុគ្គលិក និងកម្មករយល់ដឹងពីការគ្រោះថ្នាក់ដោយសារមីន និងត្រូវមានបំរុងប្រយ័ត្នក្នុងពេលបំពេញការងារ។

៧.៤.២- ដំណាក់កាលសាងសង់គម្រោង (Project Construction Phase)

ក្នុងដំណាក់កាលនេះ សកម្មភាពមួយចំនួននៃការរៀបចំគម្រោងអាជីវកម្មរ៉ែ ដូចជាសកម្មភាពសាងសង់សំណង់ស្នាក់ការ កន្លែងស្នាក់នៅរបស់កម្មករអណ្តូងរ៉ែ ប្រព័ន្ធផ្លូវ ព្រមទាំងការឈូសឆាយដី ការជីកអណ្តូងរ៉ែសាកល្បង និងការដឹកជញ្ជូនសម្ភារៈជាដើមអាចបង្កហេតុប៉ះពាល់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមមួយចំនួនដូចខាងក្រោម៖

៧.៤.២.១ ធនធានរូបសាស្ត្រ

ក. សណ្ឋានដី

សកម្មភាពឈូសឆាយដីព្រៃ និងពង្រាបដីនៅក្នុងតំបន់ព្រៃល្បោះ ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវ ទីកន្លែងស្នាក់នៅរបស់កម្មករ ការដ្ឋានក្នុងតំបន់គម្រោង បានធ្វើឲ្យសណ្ឋានដីមានការប្រែប្រួលទ្រង់ទ្រាយរូបសណ្ឋានតិចតួច ដោយសារទីតាំងនោះមានលក្ខណៈរាបស្មើរ និងគ្មានប្រភេទឈើមានតំលៃ។

Draft

<u>វិធានការកាត់បន្ថយ</u> (Mitigation Measures)

- សណ្ឋានដីក្នុងតំបន់គម្រោងមានសណ្ឋានជាតំបន់ភ្នំទៅតាមកន្លែង ដូច្នេះក្រុមហ៊ុន ត្រូវអនុវត្តការឈូសឆាយទៅតាមបច្ចេកទេសប្លង់មេ និងទៅតាមតំបន់ដែលបានកំនត់ មិនឲ្យមានការប៉ះពាល់ខ្លាំងដល់សណ្ឋានដីក្នុងតំបន់គម្រោង។
- ក្រុមហ៊ុនបានសិក្សាពីប្លង់គម្រោងលំអិតឲ្យបានរួចរាល់ មុននឹងធ្វើការឈូសឆាយដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។
- សម្រាប់ទីតាំងដែលមិនអាចធ្វើការអាជីវកម្មបាន ក្រុមហ៊ុនត្រូវរក្សាទុកនូវទ្រង់ទ្រាយដើម ដោយមិនធ្វើការឈូសឆាយ ក្នុងគោលបំណងរក្សាគុណភាពបរិស្ថាន។

ខ. ការហូរច្រោះដី /ការខូចគុណភាពដី

យោងទៅតាមភូគព្ភសាស្ត្រនៃតំបន់គម្រោង គឺជាប្រភេទដីខ្ពង់រាបមានភ្នំនៅអបសងខាង ទីតាំងជីក និងម៉ាស៊ីនចំរាញ់។ សកម្មភាពឈូសឆាយដី ពង្រាបដី អាចធ្វើឱ្យមានការហូរច្រោះដី នៅរដូវវស្សា។

តាមរយៈការប្រើប្រាស់គ្រឿងចក្រ ការស្តុកទុកប្រេង (បំរុងប្រើប្រាស់ និងប្រើប្រាស់រួច) ការអនុវត្តលើការទុកដាក់/ចោលសំណល់រឹង/រាវរបស់បុគ្គលិក-កម្មករ នឹងអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពដី ប្រសិនបើមានការលេចជ្រាប កំពប់ និងបោះចោលគ្មានសណ្តាប់ធ្នាប់។ ដូច្នេះ ទាមទារឲ្យក្រុមហ៊ុនធ្វើការគ្រប់គ្រងឲ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស។

<u>វិធានការកាត់បន្ថយ</u> (Mitigation Measures)

- ក្រុមហ៊ុន ធ្វើការឈូសឆាយដីទៅតាមផែនការមេឲ្យបានហ្មត់ចត់។
- ក្រុមហ៊ុន ធ្វើការបង្ហាប់ដី ដើម្បីកាត់បន្ថយការហូរច្រោះ និងសំណឹកដី នៅតាមកន្លែងនានាដែលក្រុមហ៊ុនបានធ្វើការឈូសឆាយ។
- ក្រុមហ៊ុនគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឲ្យបានល្អប្រសើរ ដោយបង្កើតទីតាំងដាក់សំណល់រឹងរួមមានកំទេចថ្ម ស្បោងប្លាស្ទិក និងសំណល់ផ្ទះបាយជាដើម រួចដឹកសំណល់ទាំងនេះទៅចាក់ចោលទៅតាមទីតាំងកំណត់របស់អាជ្ញាធរមូលដ្ឋាន។ ក្រុមហ៊ុនបានសាងសង់បង្គន់អនាម័យសម្រាប់កម្មករ ដែលមានអាងស្តុកសំណល់រាវត្រឹមត្រូវ។
- ក្រុមហ៊ុនធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនឲ្យមានការបោះចោលសំរាមពាសវាលពាសកាល ឬបង្ហូរសំណល់រាវចូលទៅប្រភពទឹក ឬអូរនៅក្បែរតំបន់គម្រោងអាជីវកម្មឡើយ។

Draft

គ. គុណភាពទឹក

ការឈូសឆាយដី និងការបោះចោលសំណល់នៅក្នុងតំបន់គម្រោង មានការប៉ះពាល់តិចតួចដល់គុណភាពទឹកអូរនៅក្បែរតំបន់គម្រោង ជាពិសេសការឈូសឆាយដីនៅរដូវវស្សា ដែលបណ្តាលមកពីការហូរច្រោះ។ ចំណែកការចោលសំណល់រឹង ដែលមានប្រភពចេញពីសំណល់សម្ភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមកពីការប្រើប្រាស់របស់បុគ្គលិក-កម្មករគម្រោង និងការបង្ហូរសំណល់រាវពីកន្លែងស្នាក់នៅ ឬពីការហៀរកំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្ត ក៏បង្កឲ្យមានការប៉ះពាល់ដល់គុណភាពទឹកផងដែរ។

នៅក្នុងរយៈពេលនេះ អាចនឹងមានសំណល់រឹងជាច្រើនដែលបានមកពីសម្ភារៈសាងសង់ ដូចជាកំណាត់ដែក ជ័របំពង់ទីប ជ័រប្លាស្ទីក កំណាត់ឈើ កំទេចស៊ីម៉ង់ត៍ កំបោរជាដើម ក៏ដូចគ្នានោះដែរ ចំពោះសំណល់ដែលបង្កើតឡើងដោយបុគ្គលិក-កម្មករ (Household/living Waste)។ ជាក់ស្តែងកម្មករនៅក្នុងទីតាំងគម្រោងមានចំនួន **៥០នាក់** (ជនជាតិចិន១៥នាក់ និងខ្មែរ៣៥នាក់) តាមការប៉ាន់ប្រមាណឲ្យដឹងថាកម្មករម្នាក់បង្កើតសំណល់រឹងយ៉ាងតិច **០,៧គ.ក្រ/ថ្ងៃ** នោះសំណល់ដែលត្រូវបញ្ចេញចោលដោយកម្មករស្មើនឹង **៣៥គ.ក្រ/ថ្ងៃ**។

ចំពោះសំណល់រាវរួមមានសំណល់ចេញពីការសាងសង់ សំណល់ប្រេង សំណល់ចេញពីការប្រើប្រាស់ទឹក របស់បុគ្គលិក-កម្មករសំណង់ និងសំណល់ចេញពីបង្គន់អនាម័យ។ យោងតាមស្តង់ដារប៉ាន់ស្មានថ្នាក់ជាតិ និងអន្តរជាតិដោយផ្អែកលើតួលេខជាគោល បរិមាណសំណល់រាវដែលបញ្ចេញចោលពីការដ្ឋានសំណង់ និងការប្រើប្រាស់ផ្សេងៗដូចជាបោកគក់ ងូត និងលាងសម្អាតសំភារៈប្រើប្រាស់សំណង់ គឺ**១៥០លីត្រ/ម្នាក់/ថ្ងៃ**។ ដោយកម្មករបំរើការនៅក្នុងការដ្ឋាននៅក្នុងដំណាក់កាលសាងសង់មានចំនួន **៥០នាក់** ដូចនេះសំណល់រាវដែលបង្កើតដោយកម្មករ-បុគ្គលិកនៅក្នុងដំណាក់សាងសង់នេះ មានប្រមាណជា **៧៥០០លីត្រ/ថ្ងៃ**។ សំណល់ទាំងនេះអាចហូរទៅតាមតំបន់ជម្រាលផ្នែកខាងក្រោម ឬជ្រាបចូលទឹកក្រោមដី។

វិធានការកាត់បន្ថយ (Mitigation Measures)

ទោះបីជាមានហេតុប៉ះពាល់អវិជ្ជមានតិចតួចយ៉ាងណាក៏ដោយ ក្រុមហ៊ុនមានវិធានការការពារ ឬកាត់បន្ថយហេតុប៉ះពាល់ជាយថាហេតុដែលបណ្តាលមកពីសកម្មភាព និងសម្ភារៈសាងសង់ដែលអាចប៉ះពាល់ដល់គុណភាពទឹក។ ក្រុមហ៊ុនមានវិធានការទុកដាក់សំណល់ទាំងអស់នោះ ឲ្យបានត្រឹមត្រូវមួយចំនួនដូចខាងក្រោម៖

- សំណាកទឹកចំនួន **១១កន្លែង** ត្រូវបានជ្រើសរើសតាមបណ្តាអូរ ស្ទឹង រណ្តៅជីករ៉ែ និងអណ្តូងទឹកក្នុងតំបន់គម្រោង ដើម្បីយកទៅពិនិត្យនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។ ប៉ារ៉ាម៉ែត្រគុណភាពទឹក **ចំនួន២២** ត្រូវធ្វើការវិភាគ សម្រាប់សំណាកទឹកពី

Draft

ប្រភពនីមួយៗ ហើយលទ្ធផលនៃការវិភាគនេះមានលក្ខណៈងាយស្រួល សម្រាប់ធ្វើការប្រៀបធៀបពីគុណភាពទឹកនៅក្នុងដំណាក់កាលប្រតិបត្តិគម្រោង។

- ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីន/គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនថ្មីៗ ដោយត្រូវបានត្រួតពិនិត្យជាប្រចាំ និងហ្មត់ចត់មុននឹងប្រតិបត្តិ ដើម្បីធានាមិនឲ្យមានការលេចឬជ្រាបប្រេង។
- ធ្វើការអប់រំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងអំពីអនាម័យនៅក្នុងតំបន់សាងសង់ ដោយត្រូវវេចខ្ចប់រាល់សំណល់ផ្ទះបាយរបស់ខ្លួន និងទុកដាក់នៅកន្លែងកំណត់ឲ្យបានត្រឹមត្រូវ។
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋានសាងសង់ ដោយតម្រូវឲ្យបុគ្គលិក និងកម្មករគោរពយ៉ាងម៉ឺងម៉ាត់ ឬត្រូវទទួលពិន័យយ៉ាងតឹងរ៉ឹង។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីប្រមូលសំរាមយកទៅចាក់ចោលនៅកន្លែងត្រឹមត្រូវ។ អ្នកម៉ៅការនឹងធ្វើការសំអាតនូវរាល់សំណល់រឹងទាំងអស់នេះឲ្យបានទៀងទាត់ជៀសវាងការប៉ះពាល់ដល់បរិស្ថានដែលនៅជុំវិញ ព្រមទាំងសុខភាពរបស់បុគ្គលិក-កម្មករផងដែរ។
- បិទស្លាកបំរាម (Use warning label) សម្រាប់សម្គាល់ចំពោះសម្ភារៈដែលមានជាតិពុល និងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថានដូចជាប្រេងឥន្ធនៈ ឬថ្នាំលាបជាដើម (Poisonous materials such as fuel, paints, etc.)។
- រាល់សំណល់រាវទាំងអស់ដែលចេញមកពីការសាងសង់ រួមទាំងសំណល់រាវដែលបង្កើតឡើងដោយកម្មករ ត្រូវបង្ហូរចូលទៅក្នុងប្រព័ន្ធបង្ហូរសំណល់រាវមួយ ដែលក្រុមហ៊ុនបានរៀបចំ (អាង Septic) ហើយត្រូវនៅឆ្ងាយពីប្រភពទឹក។

ឃ. គុណភាពខ្យល់

ការប្រើប្រាស់ប្រេងឥន្ធនៈ កន្លែងទុកសំណល់រឹង-រាវ និងការឈូសឆាយដី បណ្តាលឲ្យមានការហុយធូលី និងក្លិនស្អុយ សាយភាយចេញទៅបរិយាកាសដែលធ្វើឲ្យគុណភាពខ្យល់ត្រូវរងការបំពុល។ លើសពីនេះទៀត សកម្មភាពរបស់ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន និងគ្រឿងចក្រ ដែលការបញ្ចេះម៉ាស៊ីន និងចល័តគ្រឿងចក្រនេះ អាចបញ្ចេញនូវសារធាតុបំពុលខ្យល់មួយចំនួនចូលក្នុងបរិយាកាស។

<u>**វិធានការកាត់បន្ថយ (Mitigation Measures)**</u>

រាល់ការកាត់បន្ថយឥទ្ធិពលដែលធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពខ្យល់ ក្រុមហ៊ុនបានគិតគូរនូវវិធានការមួយចំនួនដូចខាងក្រោម៖

- អ្នកម៉ៅការនឹងតម្រូវឲ្យអនុវត្តជាប្រចាំចំពោះការត្រួតពិនិត្យមើលម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍នានា ដើម្បីធានាថារបស់របរទាំងនោះដំណើរការបានល្អ។

- គ្រឿងចក្រ និងឧបករណ៍សាងសង់ត្រូវថែរក្សាការពារឲ្យទៀងទាត់ និងអនុវត្តឲ្យបានតឹងរ៉ឹង។
- ក្រុមហ៊ុន បានរៀបចំធុងសំរាមនៅតាមផ្ទះកម្មករ និងសហការជាមួយអជ្ញាធរមូលដ្ឋាន ដើម្បីប្រមូលសំរាមឲ្យបានទៀងទាត់ ដើម្បីជៀសវាងការសាយភាយចេញនូវក្លិនស្អុយរបស់សំរាម ដែលប៉ះពាល់ដល់សុខភាពកម្មករ និងប្រជាជនដែលរស់នៅជុំវិញតំបន់គម្រោងនេះ។
- ក្រុមហ៊ុនត្រូវបាញ់ និងស្រោចទឹកនៅក្នុងតំបន់សាងសង់ និងនៅផ្លូវមេជុំវិញតំបន់គម្រោង។
- ប្រើប្រាស់គ្រឿងចក្រថ្មីៗ ដែលមិនមានការបញ្ចេញផ្សែងពុលទៅលើខ្យល់/បរិយាកាស ជាពិសេសសារធាតុ NOx, SOx និង TSP ព្រមទាំងធ្វើការត្រួតពិនិត្យឲ្យបានទៀងទាត់។ ករណីសារធាតុទាំងនេះមានកម្រិតលើសស្តង់ដារកំណត់របស់ក្រសួងបរិស្ថាន ក្រុមហ៊ុនត្រូវមានវិធានការបន្ទាន់ និងត្រួតពិនិត្យឡើងវិញនូវរាល់សកម្មភាពដែលមានការបំពុល។
- នៅពេលមានការរិះគន់ពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវ ចូលតំបន់គម្រោងពីធូលី និងឧស្ម័ន នោះអ្នកមៅការ និងក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យ និងយកចិត្តទុកដាក់ពីសកម្មភាពដែលមានការបំពុលខ្យល់ ព្រមទាំងកាត់បន្ថយនូវការបំពុលនេះឲ្យដល់កម្រិតអប្បបរមាដែលប្រជាពលរដ្ឋអាចទទួលយកបាន។

ង-ការរំខានដោយសំលេង និងរំញ័រ

ឧបករណ៍ សម្ភារៈសាងសង់ និងគ្រឿងចក្រ ត្រូវបានប្រើប្រាស់នៅពេលសាងសង់សម្រាប់សកម្មភាពមួយចំនួន ដូចជាការឈូសឆាយដី ការបង្ហាប់ដី ព្រមទាំងការប្រើប្រាស់ម៉ាស៊ីនលើកដាក់សម្ភារៈគ្រឿងសំណង់ ម៉ាស៊ីនផ្សារដែក ម៉ាស៊ីនកាត់ដែក និងម៉ាស៊ីនភ្លើង ដែលធ្វើឲ្យមានសំលេង និងរំញ័រ ប៉ះពាល់ដល់ប្រជាជនដែលរស់ជុំវិញតំបន់គម្រោង ជាពិសេសបុគ្គលិក និងកម្មករដែលធ្វើការនៅទីនោះ។

ទន្ទឹមនឹងនោះ ចំពោះអ្នកបញ្ជាគ្រឿងចក្រផ្ទាល់ដែលទាមទារឲ្យមានការការពារត្រឹមត្រូវ ដើម្បីជៀសវាងហេតុប៉ះពាល់ធ្ងន់ធ្ងរដល់សោតវិញ្ញាណ (Noise-induced hearing loss) ប្រសិនបើការប្រឈមទៅនឹងសំលេងលើសពីកម្រិតមធ្យម ៨៥ដេស៊ីបែល (៨៥dB(A)) នៅក្នុងរយៈពេលប្រាំបីម៉ោង។

<u>**វិធានការកាត់បន្ថយ** (Mitigation Measures)</u>

រាល់ការកាត់បន្ថយឥទ្ធិពលដែលធ្វើឲ្យមានការប៉ះពាល់ដល់ ការរំខានដោយសំឡេង និងរំញ័រ ក្រុមហ៊ុនបានគិតគូរនូវវិធានការមួយចំនួនដូចខាងក្រោម៖

- គ្រឿងទប់សំលេងដូចជា ឧបករណ៍កាត់បន្ថយសំលេងត្រូវបំពាក់នៅពេលដែលយល់ថាមានការចាំបាច់ ដើម្បីកាត់បន្ថយការបញ្ចេញសំលេងពីគ្រឿងចក្រ និងឧបករណ៍សាងសង់គ្រប់ប្រភេទ ដែលត្រូវបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។
- រាល់សកម្មភាពសាងសង់ដែលបង្កើតឲ្យមានកម្រិតសំលេងខ្លាំង ក្រុមហ៊ុនត្រូវកំណត់ពេលវេលាឲ្យមានតែនៅពេលថ្ងៃប៉ុណ្ណោះ (០៦:០០ព្រឹក ដល់ ០៦:០០ល្ងាច) ដើម្បីជៀសវាងការរំខានដោយសំលេងទៅដល់ការរស់នៅរបស់បុគ្គលិក និងកម្មករ។
- ចំពោះបុគ្គលិក-កម្មករដែលប្រឈមទៅនឹងសំលេងខ្លាំង និងមានរយៈពេលយូរត្រូវពាក់ឧបករណ៍ទប់សំលេងដែលផ្តល់ឲ្យដោយក្រុមហ៊ុន (Personal hearing devices)។
- ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រ ព្រមទាំងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចេញសំលេងតិច ដែលមិនឲ្យប៉ះពាល់ដល់សុខភាពរបស់បុគ្គលិក-កម្មករ ។
- កម្រិតសំលេងចេញពីប្រភពគ្រឿងចក្រ នៅក្នុងចំងាយ១០០ម៉ែត្រ ទៅកាន់បរិស្ថានដែលនៅជុំវិញ គឺមិនលើសពី ៧៥dB(A)នៅពេលថ្ងៃ។ ក្រុមហ៊ុន ត្រូវតម្រូវឲ្យប្រើប្រាស់ឧបករណ៍ ម៉ាស៊ីន ដែលមានកម្រិតរំញ័រទាបនៅគ្រប់ពេលទាំងអស់គឺជាការចាំបាច់ (តំបន់ប្រជាជនរស់នៅ និងតំបន់ចំរុះ <៦០dB តំបន់ពាណិជ្ជកម្ម<៧០dB និងតំបន់ងាយទទួលរងការប៉ះពាល់ដោយសំលេង <៤៥dB)។

៧.៤.២.២- ធនធានជីវសាស្ត្រ

ក. ព្រៃឈើ ជម្រក និងសត្វព្រៃ

នៅក្នុងដំណាក់កាលសាងសង់ នៃគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ អាចមានការប៉ះពាល់ដល់ធនធានព្រៃឈើ ដោយសារការឈូសឆាយដើម្បីសាងសង់ផ្លូវចូលក្នុងការដ្ឋាន ការរៀបចំសាងសង់ផ្ទះបុគ្គលិក និងកម្មរ ការរៀបចំការដ្ឋានអណ្តូងជីករ៉ែ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ដោយឃើញថាការបាត់បង់ព្រៃឈើ តែងតែកើតមានឡើងគ្រប់ដំណាក់កាលនៃការធ្វើអាជីវកម្មរ៉ែ ដូច្នេះខាងក្រោមជាវិធានការមួយចំនួនក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន៖

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ការឈូសឆាយដីសម្រាប់សាងសង់ត្រូវធ្វើឡើងទៅតាមប្លង់មេ ដើម្បីបញ្ជៀសឲ្យបានកម្រិតអតិប្បមាលើផលប៉ះពាល់ធនធានព្រៃឈើ។
- ដាក់បទបញ្ញត្តិដល់កម្មករ ឬប្រជាពលរដ្ឋមិនឲ្យចូលកាប់ព្រៃឈើខុសច្បាប់ក្នុងតំបន់គម្រោង និងសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីគ្រប់គ្រងព្រៃឈើ។

- ក្រុមហ៊ុនមិនធ្វើការកាប់ឈើ ដើម្បីយកមកសាងសង់អគារផ្សេងៗក្នុងការដ្ឋាន។
- ធ្វើការសាងសង់អគារ ផ្ទះបុគ្គលិក-កម្មករ អគារការិយាល័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ទៅតាមសណ្ឋានដី ដោយធ្វើការសាងសង់នៅតំបន់ដែលមិនមានព្រៃឈើ ឬព្រៃរិករឹល។
- សាងសង់ផ្លូវចូលក្នុងតំបន់គម្រោង នៅលើប្រព័ន្ធផ្លូវចាស់ ដើម្បីជៀសវាងការកាប់ព្រៃឈើ។
- ក្រុមហ៊ុនធ្វើការហាមឃាត់ដាច់ខាតចំពោះបុគ្គលិក កម្មករ លើការលបលួចបរបាញ់ដាក់អន្ទាក់សត្វព្រៃធ្វើជាចំណីអាហារ។

ខ. ជីវចម្រុះក្នុងទឹក

តាមផែនទីប្រព័ន្ធផ្លូវទឹក បានបង្ហាញថានៅក្នុងតំបន់គម្រោងមិនមានវត្តមាន ស្ទឹង បឹង អូរហូរកាត់នោះទេ។ តែទោះជាយ៉ាងណាក៏ដោយនៅជុំវិញតំបន់គម្រោង មានស្ទឹងក្រែង អូរខ្វារ និងបឹងធ្នូន ដែលប្រជាប្រភពទឹកយ៉ាងសំខាន់។ ប្រភពទឹកទាំងនេះ អាចទទួលរងការប៉ះពាល់ ដោយសារសកម្មភាពនៃការឈូសឆាយ និងការបញ្ចេញសំណល់រឹង-រាវ របស់បុគ្គលិក កម្មករ អាចធ្វើឲ្យមានការហូរច្រោះដី ចូលក្នុងប្រភពទឹកទាំងនេះ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ធនធានជីវចម្រុះក្នុងទឹក។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននឹងហាមឃាត់ដាច់ខាត មិនឲ្យកម្មករ បុគ្គលិក លបលួចប្រមាញ់ សត្វព្រៃ ឬមច្ឆាជាតិក្នុងទឹក ធ្វើជាចំណីអាហារ ឬការជួញដូរឡើយ។ ក្រុមហ៊ុននឹងមានវិធានការតាមផ្លូវច្បាប់លើបុគ្គលិក កម្មករទាំងឡាយណាប្រព្រឹត្តិផ្ទុយពីបញ្ញត្តិ។
- ការឈូសឆាយដីសម្រាប់សាងសង់ត្រូវធ្វើឡើងតែនៅរដូវប្រាំងប៉ុណ្ណោះ កុំឲ្យមានការហូរច្រោះ ដោយមិនមានការប៉ះពាល់ដល់មច្ឆាជាតិក្នុងទឹក។
- ចូលរួមថែទាំដល់គុណភាពទឹកស្ទឹង អូរ ព្រែកនៅក្បែរតំបន់គម្រោង ការពារការហូរច្រោះដី ជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិក-កម្មករមិនឲ្យបោះចោល ឬបង្ហូរដោយផ្ទាល់ចូលទៅប្រភពទឹកជាដាច់ខាត។

៧.៤.២.៣- ធនធានសេដ្ឋកិច្ច-សង្គម

ក-ការរស់នៅរបស់ប្រជាសហគមន៍ (ការតាំងទីលំនៅ-ការប្រើប្រាស់ដីធ្លី)

សកម្មភាពក្នុងដំណាក់កាលសាងសង់របស់គម្រោង មិនសូវមានការរំខានដោយសំលេង និងហុយធូលី ទៅលើការរស់នៅរបស់ប្រជាសហគមន៍ ដែលមានទីតាំងនៅក្បែរទីតាំងគម្រោង

ដោយសារតែទីតាំងគម្រោងស្ថិតនៅឆ្ងាយពីតំបន់ប្រជាជនរស់នៅ។ ម៉្យាងទៀតការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ អាចមានការប៉ះពាល់ជាមួយប្រជាពលរដ្ឋដែលមានដីស្រែចំការនៅតំបន់គម្រោង តាមរយៈការឈូសឆាយផ្លូវ ការកំណត់ព្រំ និងការសាងសង់ទីស្នាក់ការរដ្ឋបាល និងផ្ទះកម្មករ-បុគ្គលិកនោះទេ។ តែទោះជាយ៉ាងណា ការហូរចូលនៃបុគ្គលិក និងកម្មករមកក្នុងតំបន់គម្រោងអាចនាំយកមកនូវវប្បធម៌ផ្សេងពីប្រជាជនក្នុងតំបន់ ដែលអាចបង្កឲ្យមានការខ្វែងគំនិតឈានដល់ជម្លោះជាដើម។

<u>វិធានការកាត់បន្ថយ</u> (Mitigation Measures)

- គ្រឿងទប់សំលេងដូចជាឧបករណ៍កាត់បន្ថយសំលេង ត្រូវបំពាក់នៅពេលដែលយល់ថាមានការចាំបាច់ ដើម្បីកាត់បន្ថយការបញ្ចេញសំលេងពីគ្រឿងចក្រ និងឧបករណ៍សាងសង់ធុនធ្ងន់គ្រប់ប្រភេទ ដែលត្រូវបានអនុញ្ញាតកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។
- ក្រុមហ៊ុននឹងដឹកជញ្ជូនសម្ភារៈតែនៅ ពេលថ្ងៃ ដើម្បីកុំឲ្យរំខានដល់ប្រជាជននៅតាមដងផ្លូវ
- នៅតំបន់ប្រជាជនរស់នៅ សំលេង និងរំញ័រត្រូវត្រួតពិនិត្យ ឱ្យបានទៀងទាត់គ្រប់ពេលវេលា។ ប្រសិនបើសំលេងឡើងដល់កម្រិតគួរឱ្យកត់សំគាល់ដូចជា លើសស្តង់ដារបស់ក្រសួង ក្រុមហ៊ុននឹងបំពាក់គ្រឿងកាត់បន្ថយសម្លេង។
- កំណត់ល្បឿនបើកបរជាមធ្យម៣០គ.ម/ម៉ោង
- គ្រប់សម្ភារៈសាងសង់ដែលអាចហុយបានដូចជាខ្សាច់ ស៊ីម៉ង់ត៍ជាដើម នៅលើរថយន្តដឹកជញ្ជូនត្រូវបិទឱ្យបានជិតល្អ (Bags and covers dust generating material for clean transportation)។
- សំណល់សម្ភារៈសាងសង់នៅក្នុងការដ្ឋានត្រូវប្រចកចូលទៅក្នុងការ៉ុង/បាវរួចចងឱ្យជិតមុននឹងធ្វើការដឹកជញ្ជូនយកទៅចោលនៅទីកន្លែងកំណត់មួយ។
- ក្រុមហ៊ុនបាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់ និងនៅផ្លូវមេជុំវិញតំបន់គម្រោង (watering construction sites and main road around the project site)។
- អប់រំ និងណែនាំដល់បុគ្គលិក-កម្មករឱ្យប្រកាន់ភ្ជាប់នូវបទបញ្ជារបស់ក្រុមហ៊ុន ដើម្បីកុំឱ្យរំខានដោយប្រការណាមួយដល់ប្រជាជនដែលរស់នៅជិតខាងតំបន់គម្រោង។
- ក្រុមហ៊ុនត្រូវមានផែនការសំណងតាមស្ថានភាពជាក់ស្តែងទៅដល់ប្រជាពលរដ្ឋ ដែលទទួលរងនូវផលប៉ះពាល់ ដោយធ្វើការចុះអង្កេតផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋាន។
- ក្រុមហ៊ុនត្រូវធ្វើលើសំណងប៉ះប៉ូវ ដោយផ្អែកលើប្រភេទដំណាំ និងទិន្នផលដែលពួកគាត់ទទួលបានក្នុងមួយឆ្នាំៗសម្រាប់ស្រែចំការអចិន្ត្រៃយ៍ និងប៉ះប៉ូវជាថវិកាសម្រាប់កម្លាំងពលកម្មដែលបានកាប់ឆ្ការរួច ចំពោះស្រែចំការពនេចរ។

ខ-សុខភាព និងសុខាមាលភាពសាធារណៈ:

នៅដំណាក់កាលនេះមានបុគ្គលិក-កម្មករសំណង់ប្រមាណ**៥០នាក់**

បញ្ហាសុខភាពដែលអាចនឹងកើតមានឡើងដោយសារធូលីហុយ រួមផ្សំនឹងផ្សែងរថយន្ត និងគ្រឿងចក្រមួយចំនួនរួមមានការរលាកផ្លូវដង្ហើម ជំងឺភ្នែក ជំងឺស្បែកជាដើម ប៉ុន្តែការប៉ះពាល់ដោយសារបំពុលខ្យល់នៅក្នុងដំណាក់កាលនេះមានរយៈពេលខ្លី។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ប្រកាន់យកសុវត្ថិភាពជាចំបងនៅការដ្ឋានសាងសង់ (Safety First)។
- ផ្តត់ផ្គង់ទីកន្លែងស្នាក់នៅសមរម្យ ទឹកស្អាត និងបង្គន់អនាម័យដល់កម្មករៈ ទីកន្លែងស្នាក់នៅសម្រាប់បុគ្គលិក កម្មករត្រូវបានរៀបចំឡើងដោយធ្វើយ៉ាងណាឱ្យមានពន្លឺ និងមានខ្យល់ចេញចូលបានគ្រប់គ្រាន់ និងមានភាពទូលាយសមរម្យ ដើម្បីជៀសវាងការរស់នៅកកកុញនៅក្នុងកន្លែងតែមួយ (បន្ទប់តូចចង្អៀតហួស) ដែលអំណោយផលដល់ការចម្លងជំងឺផ្សេងៗដូចជាជំងឺផ្លូវដង្ហើម។ល។
- តម្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់នៅពេលកំពុងសាងសង់ គឺចាំបាច់ណាស់រួមទាំងទឹកសម្រាប់បរិភោគ និងការលាងសំអាតរាងកាយប្រចាំថ្ងៃ។ គម្រោងបានតម្លើងស៊ីទែនស្តុកទឹកដោយតបណ្តាញពីប្រភពទឹកអណ្តូងក្នុងតំបន់គម្រោងសម្រាប់កម្មករប្រើប្រាស់
- សាងសង់បង្គន់អនាម័យបណ្តោះអាសន្នដោយគោរពទៅតាមស្តង់ដារអនាម័យត្រឹមត្រូវ ដូចជាប្រភេទបង្គន់មានអាងស្តុកលាមកសឹបទិក (Septic Tank) ដល់កម្មករជាដើម។ ប្រការដែលត្រូវប្រយ័ត្នគឺបង្គន់ត្រូវនៅឆ្ងាយពីប្រភពទឹកប្រើប្រាស់ ជាពិសេសប្រភព ទឹកស្ទឹង បឹង អូរជាដើម ដើម្បីជៀសវាងការជ្រាបចូលទៅក្នុងទឹកស្អាតដោយថាហេតុដែលអាចចម្លងមេរោគបាន។
- ធ្វើការអប់រំបុគ្គលិក-កម្មករឱ្យយល់ដឹងអំពីជំងឺកាមរោគ-អេដស៍ និងវិធីការពារជាពិសេសចំពោះបុគ្គលិក-កម្មករដែលឃ្លាតឆ្ងាយពីក្រុមគ្រួសារ ព្រោះពួកគេអាចស្វែងរកសេវាផ្លូវភេទនៅទីកន្លែងកំសាន្តនានា ដែលអាចឱ្យគេប្រឈមទៅនឹងការឆ្លងជំងឺកាមរោគទាំងនោះ។ ដើម្បីកុំឱ្យរាំងស្ទះដល់ដំណើរការសាងសង់របស់គម្រោង ការផ្សព្វផ្សាយអប់រំអាចធ្វើនៅពេលថ្ងៃឈប់សំរាកពីការងាររបស់កម្មករ ហើយការអប់រំសុខភាពនេះអាចមានរយៈពេលជាមធ្យមពី១-២ម៉ោងក្នុងមួយលើក។
- ជ្រើសរើសគ្រូពេទ្យប្រចាំការនៅការដ្ឋាន ដើម្បីធ្វើការពិនិត្យពិគ្រោះព្យាបាលដល់បុគ្គលិក-កម្មករ និងសង្គ្រោះបន្ទាន់ក្នុងករណីដែលមានជំងឺ ឬរបួសធ្ងន់ធ្ងរដោយថាហេតុ។

បន្ថែមពីនេះទៀត គ្រូពេទ្យប្រចាំការត្រូវរាយការណ៍ជាបន្ទាន់ក្នុងករណីសង្ស័យ ឬរកឃើញករណីជំងឺឆ្លងរាតត្បាតណាមួយ។

គ-មុខរបរ និងប្រាក់ចំណូល

ប្រជាពលរដ្ឋអាចបាត់បង់ដីស្រែចំការពនេតចរ និងតំបន់ព្រៃដែលជាទីតាំងរកអនុផលព្រៃឈើ ជាប្រភពបន្ទាប់បន្សំសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ចំពោះដីស្រែចំការពនេតចរដែលប៉ះពាល់ ក្រុមហ៊ុននៅតែបន្តការអនុញ្ញាត្តិឲ្យពួកគាត់បានចូលធ្វើស្រែចំការបានដូចធម្មតា។
- ទីតាំងស្វែងរកអនុផលព្រៃឈើរបស់ប្រជាពលរដ្ឋ ក្រុមហ៊ុនអនុញ្ញាតិឲ្យចូលស្វែងរកតាមធម្មតា ប៉ុន្តែត្រូវសុំការអនុញ្ញាតិពីក្រុមហ៊ុនមុនធ្វើការចេញចូល។

ឃ-ផ្លូវគមនាគមន៍ក្រៅតំបន់គម្រោង (ហេដ្ឋារចនាសម្ព័ន្ធ)

ការដឹកជញ្ជូនសម្ភារៈចូលក្នុងតំបន់គម្រោង និងគ្រឿងចក្រអាចមានផលប៉ះពាល់ ខូចខាតដល់ផ្លូវសារធារណៈដែលបានសាងសង់ និងប្រើប្រាស់ដោយសហគមន៍ក្នុងតំបន់នោះ រួមទាំងអាចបណ្តាលឲ្យមានបញ្ហាចរាចរណ៍កកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនត្រូវចូលរួមសាងសង់ និងជួសជុលផ្លូវលំក្នុងសហគមន៍ ដើម្បីសំរួលដល់ការធ្វើចរាចរណ៍ នៅក្នុងតំបន់
- ក្រុមហ៊ុនត្រូវកំណត់ពីល្បឿនក្នុងការបើកបរ ៣០គ.ម/ម៉ោង រួមទាំងពង្រឹងការបើកបរដោយប្រុងប្រយ័ត្ន ជៀសវៀងការធ្វេសប្រហែស ឬការបើកបរដោយប្រើប្រាស់គ្រឿងស្រវឹងជាដើម។

ង-តំបន់ប្រវត្តិសាស្ត្រ

ការឈូសឆាយដីព្រៃក្នុងតំបន់គម្រោង អាចបង្កឲ្យមានផលប៉ះពាល់ដល់សំណង់ប្រវត្តិសាស្ត្របុរាណ ដូចជាប្រសាទបុរាណ ស្ពានបុរាណ ទីតាំងប្រវត្តិសាស្ត្រផ្សេងៗជាដើម។ ប៉ុន្តែតាមរយៈការចុះសិក្សាផ្ទាល់បង្ហាញឲ្យឃើញថា ក្នុងតំបន់ធ្វើអាជីវកម្ម **៣៦០០ហិកតា** នេះ មានតែប្រសាទល្បើក ដែលមានទំហំ ៥មx៥ម (សល់តែតួប្រាសាទ) និងមានចំងាយប្រមាណ ៤គ.ម ពីភ្នំខ្ញុំ ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនមានការឈូសឆាយទៅតាមផែនការមេ ដោយកំណត់ពីបរិវេណនៃការឈូសឆាយមិនឲ្យមានផលប៉ះពាល់ដល់សំណង់ប្រវត្តិសាស្ត្រ ហើយប្រសិនបើការឈូសឆាយប្រទះឃើញវត្ថុបុរាណ ក្រុមហ៊ុននឹងត្រូវរាយការណ៍ជូនដល់អាជ្ញាធរក្នុងតំបន់ ជាពិសេសមន្ទីរវប្បធម៌ខេត្តសៀមរាប។
- ក្រុមហ៊ុនធ្វើការអប់រំដល់បុគ្គលិក-កម្មករ ក្នុងទីតាំងអាជីវកម្ម ឲ្យបានយល់កាន់តែច្បាស់ពីសំណង់ និងទីតាំងប្រវត្តិសាស្ត្រ។
- ក្រុមហ៊ុនត្រូវសហការណ៍ជាមួយស្ថាប័ន និងជំនាញពាក់ព័ន្ធ ដើម្បីកំណត់នូវទីតាំងប្រាសាទបុរាណ និងទីតាំងដែនការពារយ៉ាងតិច១៥០ម៉ែត្រជុំវិញប្រាសាទ ដែលមានវត្តមានក្នុងតំបន់គម្រោង។

៧.៤.៣- ដំណាក់កាលប្រតិបត្តិគម្រោង (Operational Phase)

សកម្មភាពរបស់ក្រុមហ៊ុនមានលក្ខណៈខ្លាំងខ្លា នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោង ដោយសារដំណើរបើករណ្តៅរ៉ែ ទាញ និងចំរាញ់រ៉ែត្រូវបានអនុវត្ត។ ហេតុនេះហើយ ការអនុវត្តខាងលើ នឹងមានផលប៉ះពាល់ដល់ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមមួយចំនួន មានន័យដូចរៀបរាប់ខាងក្រោម។

៧.៤.៣.១ ធនធានរូបសាស្ត្រ

ក-សណ្ឋានដី និងឋានលេខា

នៅក្នុងដំណាក់នេះ សណ្ឋានដីមានការប្រែប្រួលខ្លាំងដោយសារការឈូសកាយ បើករណ្តៅ និងបកយកអាចម៍ដីមុនជីករ៉ែ និងការជីកយករ៉ែបង្កើតបានជារណ្តៅធំៗ។ តាមស្ថានភាពជាក់ស្តែង ក្នុងតំបន់គម្រោងមានរណ្តៅចាស់ចំនួន ៣កន្លែង ហើយក្រុមហ៊ុនមានផែនការជីករណ្តៅរ៉ែសរុបចំនួន៧កន្លែង ក្នុងទំហំផ្ទៃដីប្រមាណ១គីឡូម៉ែត្រក្រឡា។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុន ធ្វើការឈូសឆាយ និងជីករណ្តៅរ៉ែទៅតាមលក្ខណៈបច្ចេកទេស និងពិនិត្យតាមស្ថានភាពជាក់ស្តែងនៃខ្សែរ៉ែ ទៅតាមស្ថានភាពសណ្ឋានដីក្នុងតំបន់។
- ក្រុមហ៊ុន កំណត់ទីតាំងច្បាស់លាស់សម្រាប់ការស្តុកទុកអាចម៍ដី និងរក្សាទុកសម្រាប់ចាក់បំពេញរណ្តៅរ៉ែវិញ។

- បច្ចេកទេសនៃការលប់រណ្តៅគឺ ស្រទាប់ទី១ ដាក់អាចម៍ដីធម្មតា ស្រទាប់ទី២ដាក់អាចម៍រ៉ែ និងស្រទាប់ទី៣ ដាក់ស្រទាប់ដីដែលបកពីផ្ទៃកខាងលើ។
- ធ្វើការជីកទៅតាមគម្រោងប្លង់មេ ដើម្បីងាយស្រួលគ្រប់គ្រង និងទុកដាក់អាចម៍ដីសម្រាប់ចាក់បំពេញ។
- ធ្វើការដាំដើមឈើឡើងវិញបន្ទាប់ពីការលប់រណ្តៅរួច។

ខ. ការហូរច្រោះដី

ក្នុងដំណាក់កាលនេះ គម្រោងអាចបង្កឲ្យមានការហូរច្រោះនៅតាមតំបន់ឈូសឆាយបកយកដីស្រទាប់លើមុនការទាញយកថ្មរ៉ែ។ ការហូរច្រោះ អាចចាក់ចូលទៅតាមប្រភពទឹកអូរ និងបឹង ដែលស្ថិតនៅជុំវិញ និងក្បែរតំបន់គម្រោង។ លើសពីនេះទៀត ប្រសិនបើការស្តុកទុកថ្មរ៉ែ និងអាចម៍រ៉ែមិនបានត្រឹមត្រូវ នឹងបណ្តាលឲ្យមានការហូរច្រោះសារធាតុរ៉ែមួយចំនួនទៅប្រភពទឹកក្បែរបំផុត។ តាមការពិនិត្យជាក់ស្តែង ប្រព័ន្ធផ្លូវទឹកស្ថិតនៅឆ្ងាយពីទីតាំងជីក និងចម្រាញ់រ៉ែ ដូច្នេះកម្រិតនៃការហូរចូលមានកម្រិតទាប លុះត្រាតែមានគ្រោះធម្មជាតិទឹកជំនន់ជាដើម ទើបបង្កផលប៉ះពាល់គួរឲ្យកត់សម្គាល់ពីគម្រោងអាជីវកម្ម។ ម្យ៉ាងវិញទៀត នៅរដូវវស្សា មានភ្លៀងធ្លាក់ច្រើន អាចបង្កឲ្យមានការដក់ទឹកជាច្រើន នៅក្នុងរណ្តៅជីករ៉ែ ដែលអាចជន់ជោរហូរទឹកចេញពីអណ្តូងរ៉ែ និងអាចបង្កឲ្យមានការហូរច្រោះផងដែរ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនត្រូវធ្វើការឈូសឆាយទៅតាមប្លង់មេ ដោយបញ្ចៀសនូវការឈូសឆាយខុសបច្ចេកទេស មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុននឹងលុបរណ្តៅបន្ទាប់ធ្វើការជីកយករ៉ែរួចរាល់។
- ក្រុមហ៊ុនត្រូវរៀបចំទុកដាក់ថ្មរ៉ែ និងអាចម៍រ៉ែឲ្យបានត្រឹមត្រូវ ដើម្បីការពារការហូរច្រោះចូលទៅក្នុងប្រព័ន្ធផ្លូវទឹក ក៏ដូចជាដីស្រែចំការរបស់ប្រជាពលរដ្ឋរស់នៅក្បែរតំបន់គម្រោង។
- ក្រុមហ៊ុនត្រូវរៀបចំ និងត្រួតពិនិត្យមើលចុងទុយោរបស់ប្រព័ន្ធបង្ហូរភក់ ដើម្បីធានាថាវាគ្មានការលេចធ្លាយ ដែលជាហេតុបង្កឲ្យមានការច្រោះដី។
- ក្រុមហ៊ុនបានបំពាក់ប្រព័ន្ធបូម និងបង្ហូរទឹកឲ្យបានគ្រប់គ្រាន់នៅក្នុងរណ្តៅរ៉ែជីក និងទាញយកទឹកពីរណ្តៅរ៉ែនេះ មកប្រើប្រាស់ក្នុងរោងចក្រចំរាញ់រ៉ែវិញ។

គ. ការបំពុលខ្យល់

នៅក្នុងដំណាក់កាលនេះ គុណភាពខ្យល់នឹងរងការបំពុល ដោយសារសកម្មភាពដូចជាការឈូសឆាយបកយកស្រទាប់អាចម៍ដីផ្ទៃកខាងលើ ការជីកយកថ្មរ៉ែ ការស្តុកទុកថ្មរ៉ែ-អាចម៍រ៉ែ និងដំណើរការប្រព្រឹត្តកម្មសំណល់រាវ ដែលមាននៅក្នុងទីតាំងគម្រោង។ ការដឹកជញ្ជូនអាចម៍ដី

យកទៅស្តុកនៅទីតាំងកំណត់ ការដឹកជញ្ជូនថ្មរ៉ែពីការដ្ឋានជីកមកទីតាំងចំរាញ់រ៉ែ ក៏បានបង្កឲ្យមានការហុយធូលី ប៉ះពាល់ដល់គុណភាពខ្យល់។ លើសពីនេះ ការស្តុកទុកថ្មរ៉ែមិនបានត្រឹមត្រូវ និងអាចបង្កឲ្យមានប្រតិកម្មសារធាតុគីមីក្នុងថ្មរ៉ែជាមួយខ្យល់ ដែលឈានដល់ការបំពុលខ្យល់។ ក្រៅពីនេះ ក្រុមហ៊ុនបានប្រើប្រាស់ម៉ាស៊ីនភ្លើង សម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងការដ្ឋាន ដែលវាបានរួមចំណែកដល់ការបំពុលខ្យល់។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននិងកំណត់ល្បឿនក្នុងការដឹកជញ្ជូនសំណល់អាចម៍ដី ថ្មរ៉ែ ដើម្បីកាត់បន្ថយការហុយ។
- ធ្វើការបាញ់ និងស្រោចទឹកនៅតាមដងផ្លូវនៅរដូវប្រាំងដើម្បីកាត់បន្ថយការហុយ នៅពេលដឹកជញ្ជូន។
- ក្រុមហ៊ុនត្រូវរៀបចំកន្លែងទុកដាក់ម៉ាស៊ីនភ្លើងនៅក្នុងបន្ទប់បិទជិត និងបំពាក់ឧបករណ៍ចម្រោះខ្យល់នៅហ្វឹងម៉ាស៊ីន ឬនៅត្រង់បំពង់ផ្សែងតែម្តង។
- ក្រុមហ៊ុនរៀបចំទីតាំងសម្រាប់ស្តុកទុកថ្មរ៉ែមុនចម្រាញ់ឲ្យបានត្រឹមត្រូវ និងស្របតាមបច្ចេកទេស ដើម្បីកាត់បន្ថយការបំពុលខ្យល់។
- ក្រុមហ៊ុនធ្វើការគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់គម្រោងឲ្យបានប្រសើរ ដោយមិនឲ្យមានការកាប់ព្រៃឈើខុសច្បាប់ ក្នុងគោលបំណងរក្សាព្រៃឈើដើម្បីបន្សុទ្ធខ្យល់ក្នុងតំបន់គម្រោង។
- ក្រុមហ៊ុន ប្រើប្រាស់គ្រឿងចក្រ និងម៉ាស៊ីនទំនើបដើម្បីកាត់បន្ថយការបញ្ចេញផ្សែងពុល។

ឃ-ការរំខានដោយសំលេង និងរំញ័រ

នៅក្នុងដំណាក់កាលនេះ ការរំខានដោយសំលេង និងរំញ័រ មានកម្រិតខ្លាំងជាងដំណាក់កាលសាងសង់ ដោយសារតែសម្លេងនៃការដឹកជញ្ជូនថ្មរ៉ែពីការដ្ឋានជីក ដំណើរការបំបែកថ្មរ៉ែឲ្យតូចល្អិត ដំណើរការចម្រាញ់ទង់ដែង ម៉ាស៊ីនភ្លើង និងចរាចរណ៍របស់យានយន្តជាដើម។ ប៉ុន្តែអ្វីដែលជាការសំខាន់ គឺទីតាំងអាជីវកម្មស្ថិតនៅឆ្ងាយពីភូមិប្រជាពលរដ្ឋ ហេតុនេះផលប៉ះពាល់ស្ថិតនៅកម្រិតទាប លើកលែងតែបុគ្គលិក កម្មកររស់នៅបណ្តោះអាសន្នក្នុងទីតាំងអាជីវកម្មប៉ុណ្ណោះ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននឹងកំណត់ម៉ោងធ្វើការយ៉ាងច្បាស់លាស់ (ម៉ោងចេញ-ម៉ោងចូល)។

- ក្រុមហ៊ុនរៀបចំបន្ទប់សម្រាប់ម៉ាស៊ីនភ្លើង ព្រមទាំងមានការបំពាក់ឧបករណ៍ ដើម្បីជួយកាត់បន្ថយសំលេងយ៉ាងមានប្រសិទ្ធិភាព។
- ក្រុមហ៊ុនបំពាក់ឧបករណ៍កាត់បន្ថយសម្លេង និងកម្រិតរំញ័រ ដើម្បីកម្រិតសម្លេង ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុល និងរំខានដោយសំលេង និងធ្វើការត្រួតពិនិត្យជាប្រចាំលើឧបករណ៍ទាំងនោះ។
- ក្រុមហ៊ុនណែនាំ បុគ្គលិក-កម្មករឲ្យចេះថែរក្សាគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដោយប្តូរប្រេងម៉ាស៊ីន និងប្រេងរំអិលជាប្រចាំ។

ង-គុណភាពទឹក

នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោង ការប្រើប្រាស់ទឹកមានប្រមាណ **២០-៣០ម^{៣}/ថ្ងៃ** ត្រូវបានប្រើប្រាស់ទូទៅក្នុងតំបន់គម្រោង។ ការជីករណ្តៅរ៉ែបើកនេះ នឹងមានការបញ្ចេញសំណល់រាវ ចេញពីអណ្តូងរ៉ែ ដែលមានផ្ទុកសារធាតុរ៉ែមួយចំនួនជាពិសេសពពួកលោហៈធ្ងន់ និងការហូរច្រោះពីប្រព័ន្ធផ្លូវថ្មីៗក្នុងតំបន់គម្រោង ដែលបណ្តាលឲ្យគុណភាពទឹក អូរ និងបឹងជិតតំបន់អាជីវកម្មធ្លាក់ចុះ ប្រសិនបើពុំមានវិធានការគ្រប់គ្រងត្រឹមត្រូវ។ លើសពីនេះ ប្រសិនបើការបង្ហូរសំណល់រាវពុំគោរពតាមបច្ចេកទេសអាចបណ្តាលឲ្យជ្រាបចូលដី ឈានដល់ការប៉ះពាល់ដល់គុណភាពទឹកក្រោមដី។ បន្ថែមពីនេះ ការបញ្ចេញសំណល់/សំរាមពីការប្រើប្រាស់ទូទៅរបស់បុគ្គលិក កម្មករ ក៏បង្កផលប៉ះពាល់ដល់គុណភាពទឹកផងដែរ។ តែទោះជាយ៉ាងណានៅក្នុងតំបន់គម្រោងមិនមានប្រព័ន្ធស្ទឹង បឹង អូរកាត់នោះទេ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនបានបំពាក់ប្រព័ន្ធបូម និងបង្ហូរទឹកឲ្យបានគ្រប់គ្រាន់នៅក្នុងរណ្តៅរ៉ែជីក និងទាញយកទឹកពីរណ្តៅរ៉ែនេះ មកប្រើប្រាស់ក្នុងរោងចក្រចំរាញ់រ៉ែវិញ។
- បង្កើតកន្លែងស្តុកសំរាម ដោយមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវ ធ្វើការបែងចែកសំរាម និងមានការកំណត់ពេលវេលានៃការដឹកជញ្ជូនទៅចាក់តាមទីតាំងកំនត់យ៉ាងច្បាស់លាស់។
- ក្រុមហ៊ុនសាងសង់អាងស្តុកទឹក ដើម្បីប្រើប្រាស់ និងផ្គត់ផ្គង់ក្នុងសង្វាក់ផលិតកម្ម និងការប្រើប្រាស់ក្នុងតំបន់ធ្វើអាជីវកម្ម។
- ក្រុមហ៊ុននឹងប្រើប្រាស់ទឹកឡើងវិញឲ្យអស់សមត្ថភាព ដោយទាញយកទឹកដែលធ្វើប្រព្រឹត្តិកម្មរួចហើយចូលក្នុងវដ្តនៃដំណើរការចម្រាញ់រ៉ែ។
- រាល់សំណង់អគារផ្សេងៗក្នុងតំបន់គម្រោងដូចជា អគារការិយាល័យ ផ្ទះបុគ្គលិក និងកម្មករក្រុមហ៊ុនបានបំពាល់អាងសិបទិក ដើម្បីសំអាតសំណល់រាវ។

- ក្រុមហ៊ុន យកសំណាកទឹកតាមបឹង អូរសំខាន់ៗដែលនៅជុំវិញតំបន់គម្រោងដើម្បីតាមដានគុណភាពទឹក ដូចជាបឹងធ្នូ១ សំណាក អូរខ្វារ១សំណាក និងស្ទឹងជីក្រែង១សំណាក។

៧.៨.៣.២ ធនធានជីវសាស្ត្រ

ក. ព្រៃឈើ ជម្រក និងសត្វព្រៃ

នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោង ធនធានព្រៃឈើមួយចំនួនមានការបាត់បង់ដោយសារការឈូសឆាយបកដីព្រៃចេញ មុននឹងធ្វើការជីកយករ៉ែតាមបច្ចេកទេសរណ្តៅបើក (Open-pit) នៅតាមតំបន់ដែលបានកំណត់ ដែលជាហេតុបណ្តាលឲ្យមានផលប៉ះពាល់ដល់គម្របដី កូនឈើ អនុផលព្រៃឈើ និងជម្រកសម្រាប់ពពួកសត្វលើដី ក្នុងតំបន់គម្រោង។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនបានធ្វើការឈូសឆាយទៅតាមប្លង់មេ ដោយកំណត់ពីព្រំដីដែលត្រូវឈូសឆាយដើម្បីបញ្ចៀសឲ្យបានកម្រិតអតិប្បរមាលើផលប៉ះពាល់ធនធានព្រៃឈើ។
- ក្រុមហ៊ុន ធ្វើការជីករ៉ែដោយប្រុងប្រយ័ត្ន បើអាចជៀសវាងការប៉ះពាល់ដល់ព្រៃឈើបាន ក្រុមហ៊ុននឹងបញ្ចៀសរាល់ការប៉ះពាល់។
- មុននឹងធ្វើការឈូសឆាយ និងកាប់ឈើដើម្បីបើកអណ្តូងរ៉ែនៅក្នុងតំបន់គម្រោង ត្រូវសហការជាមួយក្រុមការងារអន្តរក្រសួង ធ្វើការវាយតម្លៃឈើឈរ ដើម្បីបង់ថវិការចូលរដ្ឋ។

ខ. ជីវចម្រុះក្នុងទឹក

ចំពោះជីវចម្រុះក្នុងទឹក អាចនឹងទទួលរងផលប៉ះពាល់នៅពេលប្រតិបត្តិគម្រោង ដោយសារការបង្ហូរសំណល់រាវ និងការទុកដាក់សំណល់រឹងខ្វះបច្ចេកទេសគ្រប់គ្រងចេញពីតាំងគម្រោង និងចម្រាញ់រ៉ែ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននឹងរក្សាទុកព្រៃចាំបាច់ដែលជាជម្រករបស់សត្វព្រៃ ដោយធ្វើការឈូសឆាយជីករ៉ែតាមប្លង់មេប៉ុណ្ណោះ។
- ក្រុមហ៊ុន ធ្វើការជីករ៉ែដោយប្រុងប្រយ័ត្ន បើអាចជៀសវាងការប៉ះពាល់ដល់ព្រៃឈើបាន ក្រុមហ៊ុននឹងបញ្ចៀសរាល់ការប៉ះពាល់។

- ក្រុមហ៊ុនសាងសង់អាងប្រព្រឹត្តកម្មសំណល់រាវ ហើយសំណល់ទឹកដែលចម្រោះរួចក្រុមហ៊ុន នឹងប្រើប្រាស់ឡើងវិញសម្រាប់ចម្រាញ់រ៉ែឲ្យអស់លទ្ធភាព ទៅតាមតម្រូវការរបស់ក្រុមហ៊ុន។
- ក្រុមហ៊ុនចូលរួមថែទាំនូវគុណភាពទឹកអូរ បឹង ព្រមទាំងការពារការហូរច្រោះដី ដោយធ្វើការវិភាគគុណភាពទឹក ដើម្បីការពារកុំឲ្យប៉ះពាល់ដល់មច្ឆាជាតិ។

៧.៤.៣.៣ ធនធានសេដ្ឋកិច្ច-សង្គម

ក. មុខរបរ និងប្រាក់ចំណូល

តាមរយៈការសម្ភាសន៍ជាមួយប្រជាជននៅជុំវិញតំបន់ធ្វើអាជីវកម្ម មានប្រជាជនប្រមាណតែ ៥.៨% នៃសំណាកសរុប៩២គ្រួសារ ដែលចេញទៅស្វែងរកអនុផលព្រៃឈើជាមុខរបរបន្ទាប់បន្សំរបស់ពួកគាត់។ ដូច្នេះ ប្រសិនបើមានព្រៃឈើមួយចំនួនត្រូវបានបាត់បង់ នោះអាចមានផលប៉ះពាល់តិចតួចដល់ប្រជាជននៅទីនោះ ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុន នៅតែបន្តអនុញ្ញាតឲ្យប្រជាពលរដ្ឋ ដែលធ្លាប់ទៅស្វែងរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោងចូលទៅស្វែងរកតាមធម្មតា ដោយមានការអនុញ្ញាតត្រឹមត្រូវពីក្រុមហ៊ុន ពីព្រោះខ្លាចមានមនុស្សខិលខូចមួយចំនួនតូចចូលកាប់ឈើ ឬបរបាញ់សត្វខុសច្បាប់ ឬក៏ទៅលួចយកសារធាតុរ៉ែ ដែលផលិតបានដោយក្រុមហ៊ុនវិនិយោគ។

ខ. សុខភាព និងសុវត្ថិភាពការងារ

ក្នុងដំណាក់កាលនេះនឹងមានការប៉ះពាល់ដល់សុខភាពរបស់ប្រជាជន ប្រសិនបើពុំមានការគ្រប់គ្រងការស្តុកទុកថ្មរ៉ែមុនចម្រាញ់ឲ្យបានត្រឹមត្រូវ ព្រោះវាអាចហូរច្រោះចូលក្នុងប្រភពទឹកជិតបំផុត។ ជាមួយគ្នានេះដែរ វាក៏អាចកើតមាននូវជំងឺផ្លូវដង្ហើម សើស្បែក គ្រុនចាញ់ រាគរូស គ្រុនពោះវៀន ចំពោះបុគ្គលិក-កម្មករខ្វះការប្រុងប្រយ័ត្នដោយប្រើទឹកមិនស្អាត មិនប្រើបង្គន់អនាម័យ និងការស្នាក់នៅមិនសមរម្យ។ ចំពោះការដ្ឋានយករ៉ែអាចកើតមានជំងឺផ្លូវដង្ហើម ក្នុងលក្ខខណ្ឌកង្វះឧបករណ៍ សម្ភារៈ និងបច្ចេកទេសការពារសុវត្ថិភាព (ស្រោមមុខ ស្រោមដៃ ស្បែកជើង ជាដើម)

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនបានរៀបចំផ្គត់ផ្គង់ទឹកស្អាត (អណ្តូងស្នប់) ដល់កម្មករ និងផ្តល់សេវាសុខភាពដល់កម្មករតាមរយៈពិនិត្យ និងព្យាបាលជំងឺ។

- ក្រុមហ៊ុននឹងរៀបចំសំអាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងកន្លែងស្នាក់នៅ ព្រមទាំងសាងសង់បង្គន់អនាម័យ។
- ក្រុមហ៊ុនធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីរបៀបអនុវត្តអនាម័យ និងគោលការណ៍ណែនាំក្នុងការទុកដាក់សំណល់គ្រប់ប្រភេទ ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។
- ក្រុមហ៊ុននឹងផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាព ដល់កម្មករដែលធ្វើការក្នុងការដ្ឋាន ដោយធ្វើការពន្យល់ណែនាំពីរបៀបប្រើប្រាស់ឧបករណ៍ និងណែនាំពីការការពារសុវត្ថិភាពពេលកំពុងធ្វើការ ដើម្បីជៀសវាងករណីយថាហេតុណាមួយ។
- អប់រំ និងណែនាំកម្មករ ឲ្យមានបំរុងប្រយ័ត្នរាល់ការគ្រោះថ្នាក់ផ្សេងៗ នៅពេលបំពេញការងារ ដោយប្រកាន់ខ្ជាប់សុវត្ថិភាពជាចំបង។
- ក្រុមហ៊ុនមានផែនការផ្តល់ជូន នូវការធានារ៉ាប់រងអាយុជីវិតរបស់បុគ្គលិក និងកម្មករ នៅពេលបំពេញការងារ។

គ. ការតាំងទីលំនៅ

តាមរយៈការចុះសិក្សាផ្ទាល់ពីស្ថានភាពសង្គមសេដ្ឋកិច្ច នៅក្នុងតំបន់អាជីវកម្មរបស់ក្រុមហ៊ុនបង្ហាញថា មិនមានផលប៉ះពាល់ដល់ដីធ្លី និងស្រែចំការរបស់ប្រជាពលរដ្ឋឡើយ ដោយសារក្រុមហ៊ុនអាជីវកម្មបានធ្វើការដោះស្រាយរួចរាល់។

វិធានការកាត់បន្ថយ (Mitigation Measures)

ក្រុមហ៊ុនត្រូវធ្វើការសិក្សាលើដីដែលប៉ះពាល់ ដើម្បីធ្វើសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធដី និងអាជ្ញាធរដែនដី ក្នុងគោលបំណងទូទាត់សំណងលើផលប៉ះពាល់៖

- ក្រុមហ៊ុនត្រូវធ្វើមានគោលនយោបាយដោះស្រាយណាមួយឲ្យបានសមស្របជាមួយម្ចាស់ដីដែលជាជនរងគ្រោះលើដំណាំ និងទិន្នផលដែលពួកគាត់ទទួលបានក្នុងមួយឆ្នាំៗសម្រាប់ស្រែចំការអចិន្ត្រៃយ៍ និងប៉ះប៉ូវជាថវិកាសម្រាប់កម្លាំងពលកម្មដែលបានកាប់ឆ្ការរួចចំពោះស្រែចំការពនេចរ ហើយថវិកានេះនឹងប្រគល់ដល់ប្រជាជនដោយផ្ទាល់ ដោយមានការដឹងលឺពីអាជ្ញាធរដែនដី។
- ចំពោះរណ្តៅដែលលុបដីរួច ក្រុមត្រូវផ្ទេរទៅឲ្យម្ចាស់ដើមវិញ ឬជាសាធារណៈវិញ។
- ចំពោះផលប៉ះពាល់លើដីដែលមានដើមឈើ ឬទីសក្ការៈបូជា (អារក្ស-អ្នកតា) ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីសុំយោបល់ និងសម្រេចចិត្តពីសំណាក់រដ្ឋាភិបាល។

ឃ. ផ្លូវគមនាគមន៍ (ហេដ្ឋារចនាសម្ព័ន្ធ)

ទាំងដំណាក់កាលមុនប្រតិបត្តិគម្រោង និងដំណាក់កាលប្រតិបត្តិគម្រោង ការដឹកជញ្ជូនសម្ភារៈចូលក្នុងតំបន់គម្រោង និងគ្រឿងចក្រអាចមានផលប៉ះពាល់ ខូចខាតដល់ផ្លូវសាធារណៈដែលបានសាងសង់ និងប្រើប្រាស់ដោយសហគមន៍ក្នុងតំបន់នោះ រួមទាំងអាចបណ្តាលឲ្យមានបញ្ហាចរាចរណ៍កកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនបានចូលរួមសាងសង់ និងជួសជុលផ្លូវលំក្នុងសហគមន៍ ដើម្បីសំរួលដល់ការធ្វើចរាចរណ៍ នៅក្នុងតំបន់
- ក្រុមហ៊ុនបានកំណត់ពីល្បឿនក្នុងការបើកបរ ៣០គ.ម/ម៉ោង រួមទាំងពង្រឹងការបើកបរដោយប្រុងប្រយ័ត្ន ជៀសវៀងការធ្វេសប្រហែស ឬការបើកបរដោយប្រើប្រាស់គ្រឿងស្រវឹងជាដើម។

ង. តំបន់ប្រវត្តិសាស្ត្រ

ក្នុងដំណាក់កាលប្រតិបត្តិគម្រោងនេះ អាចធ្វើឲ្យប៉ះពាល់ដល់ទីតាំងប្រវត្តិសាស្ត្រ ដែលមានដូចជាប្រាសាទបុរាណ ស្ថានបុរាណ និងទីតាំងផ្សេងៗទៀត ដែលអាជ្ញាធរអប្សរាមិនទាន់កំណត់ជាទីតាំងស្រាវជ្រាវ ឬទីតាំងអភិរក្សនៅឡើយ។

<u>វិធានការកាត់បន្ថយ (Mitigation Measures)</u>

- ទាក់ទងនឹងតំបន់ប្រវត្តិសាស្ត្រ ទោះបីជាពុំទាន់មានការស្រាវជ្រាវពីតំបន់ប្រវត្តិសាស្ត្រនៅក្នុងតំបន់គម្រោងក៏ដោយ ក្រុមហ៊ុនត្រូវមានវិធានការអប់រំណែនាំ ឲ្យយល់ពីអត្ថប្រយោជន៍អំពីតំបន់ប្រវត្តិសាស្ត្រ (ត្រូវរក្សាទុក) និងក្រែនរំលឹកជានិច្ចដល់អ្នកឈ្លូសឆាយរបស់ខ្លួន។ ជាក់ស្តែង ខណៈពេលឈ្លូសឆាយជួប និងមានការសង្ស័យលើតំបន់ណាមួយ ត្រូវធ្វើការរាយការណ៍ជូនស្ថាប័នពាក់ព័ន្ធជាពិសេសអាជ្ញាធរអប្សរា ដើម្បីចុះធ្វើការត្រួតពិនិត្យ និងកំណត់តំបន់អភិរក្ស។

ច. ការប្រើប្រាស់ទឹក

ការប្រតិបត្តិគម្រោងអាចធ្វើឲ្យប៉ះពាល់ដល់ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ របស់ប្រជាជនតិចតួចបំផុត ដោយសារសង្វាក់ផលិតកម្មត្រូវការទឹកសម្រាប់ប្រតិបត្តិការ រឺប្រើប្រាស់ផ្សេងៗ។ តាមរយៈក្រុមហ៊ុនអាជីវកម្មបានឲ្យដឹងថា ទឹកដែលត្រូវយកមកប្រើប្រាស់សម្រាប់តំបន់គម្រោងទាំងមូលបានមកពីអណ្តូង និងរណ្តៅរ៉ែ ដែលជាប្រភពទឹកដ៏ធំ។

គ. គុណភាពទឹក

នៅក្នុងដំណាក់កាលបញ្ចប់គម្រោងគម្រោងនេះ អាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពទឹក ដោយសារការហូរច្រោះដី។ ការលប់អណ្តូងរ៉ែវិញ អាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពទឹក និងអាចមានការជោរជន់លិច ហូរហៀរទឹកចេញពីអណ្តូងរ៉ែ និងអាចហូរចូលក្នុងប្រភពទឹកដែលនៅក្បែរ និងជុំវិញតំបន់គម្រោង។ ម៉្យាងទៀត សំណល់រឹង-រាវដែលចេញពីផ្ទះកម្មរ៉ែ ក៏អាចមានការប៉ះពាល់ដល់គុណភាពទឹកផងដែរ។

<u>វិធានការណ៍កាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុនមានជីកអាងស្តុកទឹកទុក ដាច់ដោយឡែកពីអណ្តូងរ៉ែ ដើម្បីរក្សាទឹកទុកសម្រាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្មក្នុងរោងចក្រផលិតរ៉ែពាក់កណ្តាលសម្រេច។
- គ្រប់អណ្តូងរ៉ែនីមួយៗ ក្រុមហ៊ុននឹងបំពាក់ប្រព័ន្ធបូម និងបង្ហូរទឹកឲ្យបានគ្រប់គ្រាន់ក្នុងអណ្តូងរ៉ែ ដើម្បីបូមទឹកទៅកាន់អាងស្តុកទឹក។
- នៅពេលបញ្ចប់អាជីវកម្មក្រុមហ៊ុន យកសំណាកទឹកតាមបឹង អូរសំខាន់ៗដែលនៅជុំវិញតំបន់គម្រោងដើម្បីវិភាគគុណភាពទឹក ដូចជាបឹងធ្នូ១ សំណាក អូរខ្វារ១សំណាក និងស្ទឹងដីក្រែង១សំណាក។
- ទឹកចេញពីរណ្តៅរ៉ែ ក្រុមហ៊ុនមិនបង្ហូរចេញពីក្រៅដាច់ខាត ទោះបីពេលលប់រណ្តៅវិញក៏ដោយ គឺក្រុមហ៊ុននឹងបូមទឹកនេះ ទៅកាន់អាងស្តុកទឹក បន្ទាប់មកទើបធ្វើការលប់។
- សំណល់រឹង-រាវដែលបញ្ចេញនៅតមផ្ទះកម្មករក្រុមហ៊ុនធ្វើការសំអាត ឲ្យបានត្រឹមត្រូវនៅពេលរុះរើការដ្ឋាន និងផ្ទះបុគ្គលិក-កម្មករ។

៧.៤.៤.២ ធនធានជីវសាស្ត្រ

ក. ព្រៃឈើ ជម្រកសត្វ និងសត្វព្រៃ

ក្នុងដំណាក់កាលនេះពុំមានការឈូសឆាយដីព្រៃបន្ថែមទៀតនោះទេ ប៉ុន្តែទីតាំងដែលបានកាយរួចនឹងក្លាយជារណ្តៅ និងតំបន់វាល ដែលជាឧបសគ្គមួយក្នុងការបំលាស់ទីរបស់សត្វ។ ម៉្យាងទៀតរណ្តៅដែលបើកហើយនេះ មានការបាត់បង់ព្រៃឈើនៅតាមអណ្តូងរ៉ែនីមួយៗចំនួន ៧រណ្តៅ។ ក្នុងករណីនេះក្រុមហ៊ុនបានបង្កើតមូលនិធិបរិស្ថាន សម្រាប់ដាំដើមឈើឡើងវិញ និងការស្តារព្រៃឈើឡើងវិញ។

<u>វិធានការណ៍កាត់បន្ថយ (Mitigation Measures)</u>

- ក្រុមហ៊ុននឹងធ្វើការដាំដើមឈើឡើងវិញនៅលើទីតាំងទាំងឡាយណា ដែលខូចខាតដោយសារការប្រតិបត្តិគម្រោងនេះ ។

Draft

- ជ្រើសរើសប្រភេទកូនឈើដែលល្អ និងសាកសមជាមួយប្រភេទដី និងស្ថានភាពភូមិសាស្ត្រក្នុងតំបន់។

៧.៤.៤.៣ ធនធានបរិស្ថានសង្គម

ក. ការប្រើប្រាស់ទឹក

ក្នុងដំណាក់កាលនេះ នឹងមានការប៉ះពាល់តិចតួចដល់គុណភាពទឹកអូរ-ស្ទឹងផ្ទៃកក្រោមដែលប្រជាជនប្រើប្រាស់សព្វថ្ងៃ ដោយសារមានការហូរសារធាតុគីមីចេញពីទីតាំងស្តុកសំណល់រឹង-រាវ ក្នុងករណីដែលទីតាំងគម្រោងមិនបានធ្វើការប្រព្រឹត្តិកម្មសំណល់រាវមុននឹងបញ្ចេញចោល។

<u>វិធានការណ៍កាត់បន្ថយ (Mitigation Measures)</u>

មុននឹងបញ្ចប់គម្រោង ក្រុមហ៊ុននឹងធ្វើការត្រួតពិនិត្យ និងសំអាតទីតាំងដាក់សំណល់រឹង-រាវឲ្យបានត្រឹមត្រូវ ដោយមានការចូលរួមពីស្ថាប័នជំនាញ និងពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន។

ខ. មុខរបរ និងប្រាក់ចំណូល

ដំណាក់កាលបញ្ចប់គម្រោងនេះ នឹងធ្វើឲ្យបាត់បង់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនក្នុងតំបន់ ដែលអាស្រ័យផលនៅក្នុងទីតាំងគម្រោង។

<u>វិធានការណ៍កាត់បន្ថយ (Mitigation Measures)</u>

តាមការពិតជាក់ស្តែងការបញ្ចប់គម្រោង គឺវាតែងតែធ្វើឲ្យប្រជាពលរដ្ឋគ្មានការងារធ្វើ។ ជាដំណោះស្រាយ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងឲ្យបានដឹងក្នុងរយៈពេល ០៣ខែមុនពេលគម្រោងត្រូវបិទ។ ស្របពេលជាមួយគ្នានេះដែរ ក្រុមហ៊ុននឹងផ្តល់ជាមូលនិធិសង្គមតាមសភាពជាក់ស្តែង ហើយក្រុមហ៊ុននឹងជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធឲ្យបានដឹងលឺផងដែរ។

គ. ផ្លូវគមនាគមន៍

ពេលបញ្ចប់គម្រោងអាចនឹងមានផលប៉ះពាល់តិចតួចដល់ប្រព័ន្ធគមនាគមន៍ និងផ្លូវធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារការដឹកជញ្ជូនសម្ភារៈ គ្រឿងចក្រ និងគ្រឿងយន្តចេញពីតំបន់គម្រោង។

<u>វិធានការណ៍កាត់បន្ថយ (Mitigation Measures)</u>

- ជាដំណោះស្រាយចំពោះផ្លូវធ្វើដំណើរនេះ ក្រុមហ៊ុននឹងរៀបចំផែនការដឹកជញ្ជូនសម្ភារៈ គ្រឿងចក្រ និងគ្រឿងយន្តឲ្យស្របតាមច្បាប់ចរាចរផ្លូវគោក ។
- ក្រុមហ៊ុនពិនិត្យលទ្ធភាព ដើម្បីធ្វើការជួសជុលផ្លូវ និងស្ពានក្នុងករណីដែលការដឹកជញ្ជូននេះធ្វើឲ្យខូចខាតផ្លូវ។

៧.៤.៥- បណ្តុំនៃហេតុប៉ះពាល់ដែលអាចកើតមានឡើង

តាមស្ថានភាពជាក់ស្តែង នៃទីតាំងគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ បានបង្ហាញថានៅជុំវិញតំបន់គម្រោងមានគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលអាចធ្វើឲ្យមានការប៉ះពាល់ដល់បរិស្ថានជុំវិញផងដែរ ក្នុងនោះមានក្រុមហ៊ុន **ខេន លីមីតធីត** (ដាំកៅស៊ូ) ក្រុមហ៊ុន **សោភណ្ឌ ធារី ពាណិជ្ជ ខូអិលធីឌី** (ដាំកៅស៊ូ) ក្រុមហ៊ុន **មាស ណារិទ្ធ** (អាជីវកម្មថ្មបាយក្រៀម) និងក្រុមហ៊ុន **ជា ណារី** (អាជីវកម្មថ្មបាយក្រៀម)។ ម៉្យាងទៀតប្រជាពលរដ្ឋក្នុងឃុំខ្វាវ ក៏រួមចំណែកក្នុងការបំផ្លាញបរិស្ថានក្នុងនិងជុំវិញតំបន់គម្រោងផងដែរ។ ការបង្ហាញនៃហេតុប៉ះពាល់ទាំងនេះមានដូចខាងក្រោម៖

ក. ក្រុមហ៊ុន ខេន លីមីតធីត

ក្រុមហ៊ុន **ខេន លីមីតធីត** ជាក្រុមហ៊ុន អភិវឌ្ឍន៍ **ដំណាំកសិ-ឧស្សាហកម្មដំណាំដំឡូងមី** ដែលមានផ្ទៃដីអភិវឌ្ឍន៍សរុបចំនួន **៤,៥៣៥ហិកតា** ស្ថិតនៅក្នុងឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ ដោយសារគម្រោងនេះស្ថិតនៅខ្សែទឹកខាងក្រោម ក៏អាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកខ្សែខាងក្រោមគឺស្ទឹងជីក្រែង គុណភាពខ្យល់ក្នុងឃុំខ្វាវ ការហូរច្រោះដី ការបាត់បង់គម្រមព្រៃឈើ និងសត្វព្រៃ ដែលនៅក្បែរតំបន់គម្រោង តាមរយៈសកម្មភាពនៃការប្រតិបត្តិគម្រោងដូចខាងក្រោម៖

- ការឈូសឆាយដីដើម្បីដាំដុះ មិនត្រឹមត្រូវតាមបច្ចេកទេស
- ការប្រើប្រាស់ជីគីមី ថ្នាំសំលាប់សត្វល្អិត និងសំលាប់ស្មៅមិនត្រឹមត្រូវតាមបច្ចេកទេស។
- ការគ្រប់គ្រងសំណល់រឹង និងរាវមិនបានត្រឹមត្រូវ
- ការហៀរកំពប់ប្រេងចេញពីម៉ាស៊ីន និងគ្រឿងចក្រ
- ការភាពអនាធិបតេយ្យរបស់បុគ្គលិក និងកម្មករ ក្នុងការកាប់បំផ្លាញព្រៃឈើ និងប្រមាញ់សត្វ។
- ការបាញ់ថ្នាំសំលាប់សត្វល្អិតក៏អាចសាយភាយ និងប៉ះពាល់ដល់គុណភាពខ្យល់ក្នុងតំបន់។

ខ. ក្រុមហ៊ុន សោភណ្ឌ ធារី ពាណិជ្ជ ខូអិលធីឌី

ក្រុមហ៊ុន **សោភណ្ឌ ធារី ពាណិជ្ជខូអិលធីឌី** ជាក្រុមហ៊ុន អភិវឌ្ឍន៍ **ដំណាំកសិ-ឧស្សាហកម្មដំណាំដំឡូងមី** ស្ថិតនៅក្នុងឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ គម្រោងនេះស្ថិតនៅខ្សែទឹកខាងក្រោម នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ហើយគម្រោងនេះ ក៏អាចធ្វើ

ឲ្យប៉ះពាល់ដល់គុណភាពទឹកគឺស្ទឹងជីក្រែង គុណភាពខ្យល់ក្នុងឃុំខ្វាវ ការហូរច្រោះដី ការបាត់បង់គម្របព្រៃឈើ និងសត្វព្រៃ ដែលនៅក្បែរតំបន់គម្រោង តាមរយៈសកម្មភាពនៃការប្រតិបត្តិគម្រោងដូចខាងក្រោម៖

- ការឈូសឆាយដីដើម្បីដាំដុះ មិនត្រឹមត្រូវតាមបច្ចេកទេស
- ការប្រើប្រាស់ជីគីមី ថ្នាំសំលាប់សត្វល្អិត និងសំលាប់ស្មៅមិនត្រឹមត្រូវតាមបច្ចេកទេស។
- ការគ្រប់គ្រងសំណល់រឹង និងរាវមិនបានត្រឹមត្រូវ
- ការហៀរកំពប់ប្រេងចេញពីម៉ាស៊ីន និងគ្រឿងចក្រ
- ភាពអនាធិបតេយ្យរបស់បុគ្គលិក និងកម្មករ ក្នុងការកាប់បំផ្លាញព្រៃឈើ និងប្រមាញ់សត្វ។
- ការបាញ់ថ្នាំសំលាប់សត្វល្អិតក៏អាចសាយភាយ និងប៉ះពាល់ដល់គុណភាពខ្យល់ក្នុងតំបន់។

គ. ក្រុមហ៊ុន មាស ណារិទ្ធ

ក្រុមហ៊ុន **មាស ណារិទ្ធ** ជាក្រុមហ៊ុនវិនិយោគលើគម្រោងធ្វើអាជីវកម្មថ្មបាយក្រៀម ដែលស្ថិតនៅក្នុងឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប។ គម្រោងនេះមានទីតាំងស្ថិតនៅភាគខាងកើតនៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ដែលគម្រោងនេះក៏ធ្វើឲ្យមានការប៉ះពាល់គុណភាពបរិស្ថានមួយចំនួនផងដែរ ដូចជាប៉ះពាល់ដល់គុណភាពទឹកអូរខ្វាវ និងបឹងឆ្នួន គុណភាពខ្យល់ សំឡេង និងរំញ័រ ធនធានព្រៃឈើ និងសត្វព្រៃ និងការហូរច្រោះដីជាដើម។ ការប៉ះពាល់នេះស្តែងឡើងតាមរយៈសកម្មភាពនៃការប្រតិបត្តគម្រោងមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់រឹង រាវរបស់បុគ្គលិក និងកម្មករមិនបានត្រឹមត្រូវ។
- ការគ្រប់គ្រងអាចម៍ដី ដែលបកចេញនៅស្រទាប់ផ្ទៃខាងលើមិនបានត្រឹមត្រូវ។
- ភាពអនាធិបតេយ្យរបស់បុគ្គលិក និងកម្មករ ក្នុងការកាប់បំផ្លាញព្រៃឈើ និងប្រមាញ់សត្វ។
- ការហុយធូលី និងសំលេងក្នុងពេលជីកថ្ម និងកាត់ថ្ម
- ការហូរច្រោះដីចូលទៅក្នុងប្រភពទឹកសំខាន់ៗមួយចំនួនដូចជាអូរខ្វាវ និងបឹងឆ្នួនជាដើម។

ឃ. ក្រុមហ៊ុន ជា ណារី

ក្រុមហ៊ុន **ជា ណារី** ក៏ជាក្រុមហ៊ុនធ្វើអាជីវកម្មថ្មបាយក្រៀមមួយដែរ ហើយមានទីតាំងស្ថិត នៅក្បែរតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ គម្រោងនេះក៏អាចធ្វើឲ្យមានការប៉ះពាល់

ដល់បរិស្ថាន ក្នុងនិងជុំវិញតំបន់គម្រោង។ គម្រោងនេះមានទីតាំងស្ថិតនៅខ្សែទឹកខាងលើនៃអូរខ្វាវ និងបឹងឆ្នូន និងភាគខាងជើងនៃភូមិខ្វាវ ហេតុដូចនេះ គម្រោងនេះអាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពទឹកអូរខ្វាវ បឹងឆ្នូន គុណភាពភាពខ្យល់ និងសំឡេង ធនធានព្រៃឈើ និងសត្វព្រៃ និងការហូរច្រោះដីជាដើម។ ការប៉ះពាល់នេះស្តែងឡើងតាមរយៈសកម្មភាពនៃការប្រតិបត្តគម្រោងមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់រឹង រាវរបស់បុគ្គលិក និងកម្មករមិនបានត្រឹមត្រូវ។
- ការគ្រប់គ្រងអាចម៍ដី ដែលបកចេញនៅស្រទាប់ផ្នែកខាងលើមិនបានត្រឹមត្រូវ។
- ភាពអនាធិបតេយ្យរបស់បុគ្គលិក និងកម្មករ ក្នុងការកាប់បំផ្លាញព្រៃឈើ និងប្រមាញ់សត្វ។
- ការហុយធូរលី និងសំលេងក្នុងពេលជីកថ្ម និងកាត់ថ្ម
- ការហូរច្រោះដីចូលទៅក្នុងប្រភពទឹកសំខាន់ៗមួយចំនួនដូចជាអូរខ្វាវ និងបឹងឆ្នូនជាដើម។

ង. ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំខ្វាវ

ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំខ្វាវ ក៏អាចរួមចំណែកក្នុងការធ្វើឲ្យខូចគុណភាពបរិស្ថានក្នុងនិងក្បែរតំបន់គម្រោងផងដែរ។ ការប៉ះពាល់នេះស្តែងឡើងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការប្រើប្រាស់ជីគីមី ថ្នាំសំលាប់សត្វល្អិត និងស្មៅ ទៅលើដំណាំកសិកម្ម។
- សត្វពាហនៈរបស់ប្រជាជនចុះផឹកទឹក និងជុះចូលក្នុងប្រភពទឹក។
- ការគ្រប់គ្រងសំណល់រឹង-រាវចេញពីលំនៅដ្ឋានមិនបានត្រឹមត្រូវ។
- ការដុតព្រៃចាប់សត្វ និងការបរបាញ់សត្វរបស់ប្រជាជន។
- ការកាប់បំផ្លាញព្រៃឈើយ៉ាងអាណាធិតេយ្យរបស់ប្រជាជន។
- ការកាប់ទន្រានព្រៃដើម្បីយកដីធ្វើកសិកម្មជាដើម។

Draft

ផែនទីបង្ហាញតំបន់គម្រោងអាជីវកម្មនានា ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប



រូបភាព៧.១៖ ផែនទីបង្ហាញពីបណ្តុំនៃហេតុប៉ះពាល់ដែលអាចកើតមាន

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង ៧.២៖ សង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយ

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ដំណាក់កាលរចនាគម្រោង					
ក. ការប៉ះពាល់ដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ៖ អាចមានការប៉ះពាល់ដីស្រែប្រជាពលរដ្ឋ ដែលរស់នៅឃុំខ្វាវ។				✓	• ក្រុមហ៊ុនដឹកអណ្តូងរ៉ែក្នុងទំហំ១គីឡូម៉ែត្រក្រឡា ក្នុងជំហានដំបូង ដែលមិនមានវត្តមានដីស្រែចំការប្រជាជនទេ។ • ក្រុមហ៊ុនអនុញ្ញាតឲ្យប្រជាជនធ្វើស្រែចំការបានធម្មតា។ • នៅពេលដែលក្រុមហ៊ុនដឹកដល់ទីតាំងដីស្រែប្រជាជនក្រុមហ៊ុននឹងផ្តល់ជូនសំណងជូនប្រជាជនតាមជាក់ស្តែង។
ខ. ការប៉ះពាល់ដល់ធនធានព្រៃឈើ៖ ការត្រួសត្រាយរៀបចំហេដ្ឋារចនាសម្ព័ន្ធអាចមានការប៉ះពាល់ដលការកាប់ដើមឈើ។			✓		• សាងសង់ហេដ្ឋារចនាសម្ព័ន្ធទៅតាមសណ្ឋានដីដើម្បីជៀសវាងការឈូសឆាយដី និងកាប់ព្រៃ។ • រៀបចំប្លង់សាងសង់អគាររដ្ឋបាល ផ្ទះកម្មករ ដោយជ្រើសរើសទីតាំងមិនសូវសំបូរដើមឈើ ឬទីវាលរាប។ • ក្រុមហ៊ុនមិនកាប់ដើមឈើ ដើម្បីសាងសង់អគារផ្សេងៗក្នុងតំបន់គម្រោងទេ។
គ.ការប៉ះពាល់ទីតាំងប្រាសាទបុរាណ៖ ក្នុងទីតាំងគម្រោងមានវត្តមានប្រាសាទមួយឈ្មោះថាប្រាសាទល្បើក	✓				• ធ្វើការអភិរក្ស ថែរក្សា និងទុកគម្លាត១៥០ជុំវិញ ប្រសាទដោយមិនធ្វើការឈូសឆាយ។ • អប់រំដល់បុគ្គលិក និងកម្មករមិនឲ្យប៉ះពាល់ ឬការបំផ្លាញដល់ប្រាសាទឡើយ។
ឃ.ការប៉ះពាល់ដល់ការធ្វើអាជីវកម្មថ្មបាយក្រៀម៖ នៅក្នុងតំបន់គម្រោងមានក្រុមហ៊ុនធ្វើអាជីវកម្ម២គឺ ក្រុមហ៊ុន		✓			• សហការជាមួយមន្ទីររ៉ែ និងថាមពល ដើម្បីកំណត់ព្រំរបស់ក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណ ជីកថ្មបាយក្រៀម។

Draft

2P, S Sk.Te Khan Keo, Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
មាសណារិទ្ធ និងជា ណារី។					• អនុញ្ញាតិឲ្យក្រុមហ៊ុនធ្វើអាជីវកម្ម ថ្មបាយក្រៀមបានធម្មតា ព្រោះថ្មបាយក្រៀមធ្វើអាជីវកម្មតែផ្នែកខាងលើ។
ង.អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ៖ ក្នុងតំបន់គម្រោងអាចមានអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលអាចមានការប៉ះពាល់ដល់បុគ្គលិក-កម្មករនៅពេលប្រតិបត្តិគម្រោង។					• ក្រុមហ៊ុនសហការជាមួយ មជ្ឈមណ្ឌលកំចាត់មីននៅកម្ពុជា ដើម្បីសិក្សាស្រាវជ្រាវរកទីតាំងពិតប្រាកដ និងធ្វើការសំអាតមីន។ • ដាក់ស្លាកសញ្ញាសំគាល់ទីតាំងមីន ឲ្យបានច្បាស់ និងដាក់បំរាមហាមបុគ្គលិក និងកម្មករចូលក្នុងតំបន់ហាមឃាត់។ • អប់រំដល់បុគ្គលិក និងកម្មករឲ្យយល់ដឹងពីការគ្រោះថ្នាក់ដោយសារមីន និងត្រូវមានបំរុងប្រយ័ត្នក្នុងពេលបំពេញការងារ។
ដំណាក់កាលសាងសង់					
១-ធនធានរូបសាស្ត្រ					
ក. សណ្ឋានដី និងឋានលេខា៖ មានការប្រែប្រួលសណ្ឋានដីតិចតួចពីការឈូសឆាយ និងពង្រាបដីធ្វើប្រព័ន្ធផ្លូវ ការដ្ឋាន ទីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ។			✓		• ក្រុមហ៊ុននឹងសហការណ៍ជាមួយអ្នកមៅការ ដើម្បីអនុវត្តការឈូសឆាយតាមប្លង់បច្ចេកទេស និងទៅតាមតំបន់ដែលបានកំណត់ មិនឲ្យមានការប៉ះពាល់ខ្លាំងដល់សណ្ឋានដីក្នុងតំបន់គម្រោង។ • ក្រុមហ៊ុនបានសិក្សាពីប្លង់មេលំអិតរួចហើយ មុននឹងធ្វើការឈូសឆាយដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។ • សម្រាប់ទីតាំងដែលមិនអាចធ្វើការអាជីវកម្មបាន ក្រុមហ៊ុនត្រូវរក្សាទុកនូវទ្រង់ទ្រាយដើម។
ខ. ការហូរច្រោះដី/ការខូចគុណភាពដី៖ អាចមានការហូរច្រោះដីបន្តិចបន្តួច ពិសេសរដូវវស្សាពេលមានភ្លៀងធ្លាក់នៅតំបន់		✓			• ត្រូវធ្វើការឈូសឆាយដីទៅតាមផែនការមេឲ្យបានហ្មត់ចត់ • ត្រូវធ្វើការបង្ហាប់ដី ដើម្បីកាត់បន្ថយការហូរច្រោះ និងសំណឹកដី នៅ

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ទើបឈូសឆាយថ្មីៗ។ តាមរយៈការប្រើប្រាស់គ្រឿងចក្រ ការស្តុកទុកប្រេង (បំរុងប្រើប្រាស់ និងប្រើប្រាស់រួច) ការអនុវត្តលើការទុកដាក់/ចោលសំណល់រឹង/រាវរបស់បុគ្គលិក-កម្មករនឹងអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពដី ប្រសិនបើមានការលេចជ្រាប កំពប់ និងបោះចោលគ្មានសណ្តាប់ធ្នាប់។ ដូច្នេះទាមទារឲ្យក្រុមហ៊ុនធ្វើការគ្រប់គ្រងឲ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស។					តាមរណ្តៅរ៉ែនីមួយៗ ដែលក្រុមហ៊ុនបានធ្វើការឈូសឆាយ • ត្រូវគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឲ្យបានល្អប្រសើរ។ • ធ្វើការណែនាំនិងអប់រំដល់បុគ្គលិក-កម្មករអំពីការទុកដាក់សំណល់រឹងរាវ និងឥទ្ធិពលរបស់វា។
គ. គុណភាពទឹក៖ ក្នុងដំណាក់កាលនេះ សកម្មភាពពីគម្រោងដូចជា ការឈូសឆាយដី និងការបោះចោលសំណល់រឹងរាវនឹងអាចនាំឲ្យមានការបំពុលខ្លះៗដល់ប្រព័ន្ធអូរ។		✓			• សំណាកទឹក ត្រូវបានជ្រើសរើសតាមបណ្តាអូរ ស្ទឹង រណ្តៅរ៉ែ និងអណ្តូងក្នុងតំបន់គម្រោងដើម្បីយកទៅវិភាគនៅមន្ទីរពិសោធន៍នៅក្រសួងបរិស្ថាន។ • ប្រើប្រាស់ម៉ាស៊ីន/គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលថ្មីៗ និងត្រួតពិនិត្យជាប្រចាំ និងហ្មត់ចត់មុននឹងប្រតិបត្តិ។ • អប់រំបុគ្គលិក-កម្មករឲ្យយល់ដឹងពីអនាម័យនៅក្នុងតំបន់សាងសង់ • រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋានសាងសង់។ • សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការប្រមូលសំរាមយកទៅចាក់ចោលនៅកន្លែងត្រឹមត្រូវ។ • បិទស្លាកបំរាមសម្រាប់សម្គាល់ចំពោះសម្ភារៈ ដែលមានជាតិពុល និងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន។ • សំណល់រាវទាំងអស់ដែលចេញមកពីការសាងសង់ និងប្រើប្រាស់ត្រូវ

..2P, St..., Sk.Te... Khan ... Keo, ... Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
					បង្ហូរចូលប្រព័ន្ធសំណល់រាវ។
ឃ. គុណភាពខ្យល់៖ ធ្វើឲ្យមានការបំពុលបរិយាកាសតិចតួចដោយសារធូលី និងកំទេចកំទីផ្សេងៗ ដែលអណ្តែតវិលវល់ផ្សែងបំពុលពីគ្រឿងចក្រ ម៉ាស៊ីនភ្លើង និងការដុតកំទេចកំទីឈើ និងសំណល់ផ្សេងៗក្រោយពីការឈូសឆាយឈើរួច។		✓			• អ្នកមៅការនឹងត្រូវតម្រូវអនុវត្តជាប្រចាំចំពោះការត្រួតពិនិត្យគ្រឿងម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍នានាឲ្យបានទៀងទាត់។ • សំណល់សម្ភារៈសាងសង់ក្នុងការដ្ឋានត្រូវប្រេកចូលទៅក្នុងបាវ ឬការ៉ុងរួចចងឲ្យជិត និងដាក់ចូលក្នុងបន្ទប់ដាក់សំណល់ មុននឹងធ្វើការដឹកជញ្ជូនទៅកាន់ទីតាំងកំណត់របស់អាជ្ញាធរមូលដ្ឋាន។ • ក្រុមហ៊ុនត្រូវបាញ់ និងស្រោចទឹកនៅក្នុងតំបន់សាងសង់ និងផ្លូវមេជុំវិញតំបន់គម្រោង។ • ប្រើប្រាស់រថយន្តដឹកជញ្ជូន និងគ្រឿងចក្រថ្មីៗព្រមទាំងធ្វើការត្រួតពិនិត្យនិងថែទាំជាទៀងទាត់នូវគុណភាពរបស់វា ដើម្បីកុំឲ្យមានការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស។ • ត្រួតពិនិត្យលើសារធាតុបំពុលខ្យល់សំខាន់ៗ ដូចជា NO_x, SO_x, និងTSP។
ង. ការរំខានដោយសំលេង និង រំញ័រ៖ អាចបង្កឡើងដោយឧបករណ៍ សម្ភារៈសាងសង់ ម៉ាស៊ីនភ្លើង និងគ្រឿងចក្រដែលប្រើប្រាស់សម្រាប់សកម្មភាពរបស់គម្រោងអាជីវកម្ម។		✓			• កំណត់ម៉ោងធ្វើការសាងសង់គឺចាប់ពីម៉ោង ៦:០០ព្រឹក ដល់ម៉ោង ៦:០០ល្ងាច។ • បំពាក់ឧបករណ៍ទប់សំលេងដល់បុគ្គលិក-កម្មករដែលនៅជាមួយគ្រឿងម៉ាស៊ីន ។ • ប្រើប្រាស់គ្រឿងចក្រ និងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចេញសំលេងតិច។

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
					• កម្រិតសំលេងចេញពីប្រភពគ្រឿងចក្រនៅក្នុងចំងាយ ១០០ម៉ែត្រទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី ៧៥ dB(A) នៅពេលថ្ងៃ។
២-ធនធានជីវសាស្ត្រ					
ក. ព្រៃឈើ ជម្រក និងសត្វព្រៃ៖ ធ្វើឲ្យបាត់បង់នូវព្រៃឈើ ជម្រកសត្វព្រៃ និងអាចធ្វើឲ្យសត្វព្រៃមួយចំនួនបំលាស់ទីទៅរកតំបន់ផ្សេងទៀត			✓		• ការឈូសឆាយដីសម្រាប់សាងសង់ ក្រុមហ៊ុនត្រូវធ្វើតាមប្លង់មេ ដើម្បីបញ្ចៀសផលប៉ះពាល់ធនធានព្រៃឈើ។ • ក្រុមហ៊ុននឹងធ្វើការហាមឃាត់ដាច់ខាតចំពោះបុគ្គលិកកម្មករ លើការលបលួចបរបាញ់ ដាក់អន្ទាក់ចាប់សត្វព្រៃធ្វើជាចំណីអាហារ។ • ក្រុមហ៊ុនមិនកាប់ឈើដើម្បីយកមកសាងសង់អគារផ្សេងៗក្នុងការដ្ឋានទេ។ • សាងសង់អគារ ផ្ទះបុគ្គលិក-កម្មករ អគារការិយា និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ទៅតាមសណ្ឋានដី ដោយជៀសវាងការកាប់ព្រៃឈើ។
ខ. ជីវៈចម្រុះក្នុងទឹក៖ គម្រោងអាជីវកម្មអាចធ្វើឲ្យជីវចម្រុះក្នុងទឹកមួយចំនួនធ្វើការបំលាស់ទី និងបាត់បង់ជីវិតផងដែរ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្ម និងរុករករបស់ក្រុមហ៊ុន។		✓			• ហាមឃាត់ដាច់ខាត មិនឲ្យកម្មករ បុគ្គលិក លបលួចប្រមាញ់សត្វព្រៃ ឬមច្ឆាជាតិក្នុងទឹក ធ្វើជាចំណីអាហារ ឬការជួញដូរឡើយ។ • ការឈូសឆាយដីសម្រាប់សាងសង់ធ្វើឡើងតែនៅរដូវប្រាំង កុំឲ្យមានការហូរច្រោះដី ដោយមិនមានការប៉ះពាល់ដល់មច្ឆាជាតិក្នុងទឹក។ • ចូលរួមថែទាំដល់គុណភាពទឹកស្ទឹង អូរ ព្រែក នៅក្បែរតំបន់គម្រោង ការពារការហូរច្រោះដី ជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិក-កម្មករ មិនឲ្យបោះចោល ឬបង្ហូរចូលទៅក្នុងប្រភពទឹកជាដាច់ខាត។

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
៣-ធនធានសេដ្ឋកិច្ច-សង្គម					
ក. ការរស់នៅរបស់ប្រជាសហគមន៍ (ការតាំងទីលំនៅ)៖ មានការប៉ះពាល់តិតួចជាមួយប្រជាសហគមន៍ដែលមានដីស្រែចំការនៅតំបន់គម្រោង តាមរយៈការឈូសឆាយផ្លូវ កំណត់ព្រំ និងសាងសង់លំនៅដ្ឋាន		✓			• ដូចវិធានការគ្រប់គ្រងសំលេង រំញ័រ និងការបំពុលខ្យល់ • មានការគ្រប់គ្រងសំណល់ឲ្យបានច្បាស់លាស់ • ក្រុមហ៊ុនត្រូវមានបទបញ្ជាផ្ទៃក្នុងសំរាប់អនុវត្ត ទៅលើបុគ្គលិក-កម្មករ ជៀសវាងការរំខានដល់ អ្នករស់នៅជិតទីតាំងគម្រោង។ • ក្រុមហ៊ុននឹងមានផែនការសំណងតាមស្ថានភាពជាក់ស្តែងជូនប្រជាសហគមន៍ដែលទទួលរងនូវការប៉ះពាល់ពីសកម្មភាពអាជីវកម្ម • ក្រុមហ៊ុននឹងធ្វើការចុះផ្ទាល់ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន។ សំណងប៉ះប៉ូវផ្អែកលើប្រភេទដំណាំ និងទិន្នផលដែលពួកគាត់ទទួលបានក្នុងមួយឆ្នាំៗ ចំពោះស្រែចំការអចិន្ត្រៃយ៍ និងប៉ះប៉ូវជាថវិកាសម្រាប់កម្លាំងពលកម្មដែលបានកាប់ឆ្ការរួច ចំពោះស្រែចំការពនេចរ។
ខ. សុខភាព និងសុខមាលភាពសាធារណៈ៖ - អាចបង្កឲ្យមានការប៉ះពាល់តិចតួចដល់សុខភាពរបស់ប្រជាពលរដ្ឋដែលនៅតាមដងផ្លូវ តាមរយៈការរំខានដោយសម្លេង និងធូលីហុយ រួមនឹងផ្សែងហុយចេញពីរថយន្ត គ្រឿងចក្រ រថយន្តដឹងសម្ភារៈចេញចូលតំបន់គម្រោង និងអាចមានការបំពុលប្រភពទឹកប្រើប្រាស់ ដោយសារការឈូសឆាយដីលុបលើប្រព័ន្ធទឹកនានាក្នុងតំបន់គម្រោង - ម្យ៉ាងវិញទៀត ចំពោះ បុគ្គលិក-កម្មករ អាចប៉ះពាល់ដល់សុខភាពតាមរយៈការប្រើប្រាស់ទឹកមិនស្អាត និងបញ្ហាជំងឺថ្មី		✓			• ប្រកាន់យកសុវត្ថិភាពជាចំបងនៅការដ្ឋានសាងសង់ • ផ្តល់កន្លែងស្នាក់នៅសមរម្យដល់កម្មករ-បុគ្គលិក • សង់បង្គន់ ផ្តល់ទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ • ធ្វើការអប់រំសុខភាពដល់កម្មករអំពីអនាម័យទូទៅ និងការបង្ការឆ្លងរោគផ្សេងៗ ជាពិសេសជំងឺកាមរោគ (មេរោគអេដស៍/ជំងឺអេដស៍) • ជ្រើសរើសគ្រូពេទ្យប្រចាំការនៅការដ្ឋានសំរាប់ពិគ្រោះព្យាបាល និងសង្គ្រោះបន្ទាន់។

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
គ. មុខរបរ និងប្រាក់ចំណូល៖ ប្រជាពលរដ្ឋអាចបាត់បង់ដីស្រែ និងព្រៃ ដែលជាទីតាំងរកអនុផលព្រៃឈើ និងជាប្រភពបន្ទាប់បន្សំសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។			✓		• ចំពោះការប៉ះពាល់លើដីស្រែចំការ ក្រុមហ៊ុនត្រូវអនុវត្តតាមគោលការណ៍សំណងតាមរូបភាពជាក់ស្តែង ដូចមានបង្ហាញលើចំណុចការរស់នៅរបស់ប្រជាសហគមន៍ (ការតាំងទិលំនៅ)។ • ចំពោះការរុករកអនុផលព្រៃឈើរបស់ប្រជាពលរដ្ឋ ក្រុមហ៊ុនអនុញ្ញាតិឲ្យចូលស្វែងរកធម្មតា ប៉ុន្តែត្រូវសុំការអនុញ្ញាតិពីក្រុមហ៊ុនមុនធ្វើការចេញចូល។
ឃ. ផ្លូវគមនាគមន៍ (ហេដ្ឋារចនាសម្ព័ន្ធ)៖ ការដឹកជញ្ជូនសម្ភារៈចូលក្នុងតំបន់គម្រោង និងគ្រឿងចក្រអាចមានផលប៉ះពាល់ និងខូចខាតដល់ផ្លូវសាធារណៈដែលបានសាងសង់ និងប្រើប្រាស់ដោយសហគមន៍ក្នុងតំបន់នោះ រួមទាំងអាចបណ្តាលឲ្យមានបញ្ហាចរាចរកកស្ទះ និងគ្រោះថ្នាក់ចរាចរជាដើម។		✓			• ចូលរួមសាងសង់ និងជួសជុលផ្លូវលំក្នុងសហគមន៍ ដើម្បីសំរួលដល់ការធ្វើចរាចរក្នុងតំបន់សហគមន៍។ • កំណត់ល្បឿនបើកបរ រួមទាំងពង្រឹងការបើកបរដោយប្រុងប្រយ័ត្ន។
ង. តំបន់ប្រវត្តិសាស្ត្រ៖ អាចធ្វើឲ្យប៉ះពាល់ដល់ទីតាំងប្រវត្តិសាស្ត្រ ដែលមានដូចជាប្រាសាទបុរាណ ស្ពានបុរាណ និងទីតាំងផ្សេងៗទៀតដែលមិនទាន់បានស្រាវជ្រាវរកឃើញដោយអាជ្ញាធរអប្សរា ឬស្ថាប័នពាក់ព័ន្ធ។		✓			• ក្រុមហ៊ុនមានការឈូសឆាយទៅតាមផែនការមេ ដោយកំណត់ពីបរិវេណនៃការឈូសឆាយ ដោយមិនឲ្យមានផលប៉ះពាល់សំណង់ប្រវត្តិសាស្ត្រ ហើយប្រសិនបើការឈូសឆាយបើបប្រទះឃើញវត្ថុបុរាណត្រូវរាយការណ៍ជូនដល់អាជ្ញាធរក្នុងតំបន់។ • ក្រុមហ៊ុននឹងអប់រំដល់បុគ្គលិក កម្មករ ក្នុងទីតាំងអាជីវកម្ម ឲ្យបានយល់កាន់តែច្បាស់ពីសំណង់ និងទីតាំងប្រវត្តិសាស្ត្រ។ • សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីកំណត់នូវទីតាំងប្រាសាទបុរាណ ដែលមានវត្តមាននៅក្នុងតំបន់គម្រោង។

Draft

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ដំណាក់កាលប្រតិបត្តិគម្រោង					
១-ធនធានរូបសាស្ត្រ					
ក. សណ្ឋានដី និងឋានលេខា៖ មានការប្រែប្រួលដី ដោយប្រែក្លាយជារណ្តៅធំៗ។ ជាក់ស្តែងមានរណ្តៅ ០៣ត្រូវគេជីករួចរាល់ និងមានផែកការជីករណ្តៅចំនួន៨កន្លែងទៀត។			✓		• ក្រុមហ៊ុនធ្វើការឈូសឆាយ និងជីករណ្តៅរ៉ែទៅតាមលក្ខណៈបច្ចេកទេស និងពិនិត្យតាមស្ថានភាពជាក់ស្តែងនៃខ្សែរ៉ែ ទៅតាមស្ថានភាពសណ្ឋានដីក្នុងតំបន់។ • ក្រុមហ៊ុនកំណត់ទីតាំងច្បាស់លាស់សម្រាប់ការស្តុកទុកអាចម៍ដីមុននឹងយកមកចាក់បំពេញក្នុងរណ្តៅ ដែលបានបញ្ឈប់ការជីក កាយយករ៉ែ។ • បច្ចេកទេសនៃការចាក់បំពេញគឺការយកអាចម៍ដីចាក់នៅស្រទាប់ក្រោមមុន បន្ទាប់មកយកសំណល់អាចម៍រ៉ែចាក់បន្ថែម រួចចាក់ស្រទាប់ដីចុងក្រោយ។ • ដាំដើមឈើឡើងវិញបន្ទាប់ពី បានលប់រណ្តៅរ៉ែរួច។
ខ. ការច្រោះដី និងធនធានរ៉ែ៖ អាចបង្កឲ្យមានការហូរច្រោះនៅតាមតំបន់ឈូសសឆាយបកយកដីស្រទាប់លើ មុននឹងការជីកយករ៉ែ។ ការហូរច្រោះនេះអាចចាក់ចូលទៅតាមប្រភពទឹក អូរ បឹងដែលនៅជិតបំផុត ប្រសិនបើការស្តុកទុកថ្មរ៉ែ និងអាចម៍រ៉ែមិនបានត្រឹមត្រូវ។			✓		• ក្រុមហ៊ុនធ្វើការឈូសឆាយទៅតាមប្លង់មេ ដោយបញ្ចៀសនូវការឈូសឆាយខុសបច្ចេកទេស និងលុបរណ្តៅ បន្ទាប់ពីធ្វើការជីកយករួចរាល់។ • ក្រុមហ៊ុនរៀបចំទុកដាក់ថ្មរ៉ែ និងអាចម៍រ៉ែឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យមានការហូរជ្រាបចូលទៅក្នុងប្រព័ន្ធផ្លូវទឹក។ • ក្រុមហ៊ុនរៀបចំបង្ហាប់ដីនៅទីតាំងដែលបានឈូសឆាយ និងដាំស្មៅរុក្ខជាតិក្នុងតំបន់ ដើម្បីការពារការហូរច្រោះ។

Draft

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
គ. ការបំពុលខ្យល់៖ នឹងមានការបំពុលខ្យល់ចេញពីកន្លែងឈូសឆាយបកយកស្រទាប់អាចម៍ដីផ្នែកខាងលើ ការជីកយកថ្មរ៉ែ សំណល់អាចម៍រ៉ែ ប្រព្រឹត្តិកម្មសំណល់រឹងរាវ និងការដឹកជញ្ជូន និងការប្រើប្រាស់ម៉ាស៊ីនភ្លើង។			✓		• បង្កើតកន្លែងស្តុកសំណល់រឹងឲ្យបានត្រឹមត្រូវ ព្រមទាំងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីយកទៅចោលនៅទីតាំងដែលបានកំណត់។ • ប្រើប្រាស់បច្ចេកទេសទំនើបដើម្បីទាញយកដុំរ៉ែ ដើម្បីកាត់បន្ថយការបំពុលខ្យល់។ • កំណត់ល្បឿនក្នុងការដឹកជញ្ជូន ដើម្បីកាត់បន្ថយការហុយ។ • រៀបចំកន្លែងទុកដាក់ម៉ាស៊ីនភ្លើងនៅក្នុងបន្ទប់បិទជិត និងបំពាក់ម៉ាស៊ីនចម្រោះនៅនឹងចុងបំពុងផ្សែងរបស់ម៉ាស៊ីន។ • រៀបចំទីតាំងស្តុកទុកថ្មរ៉ែមុននឹងចម្រាញ់ឲ្យបានត្រឹមត្រូវ។ • សាងសង់អាងប្រព្រឹត្តិកម្មសំណល់រាវ ដើម្បីចម្រោះសារធាតុគីមី។ • ក្រុមហ៊ុននឹងគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់គម្រោងឲ្យបានល្អ មិនឲ្យមានការកាប់ខុសច្បាប់ ក្នុងគោលបំណងរក្សាព្រៃ ដើម្បីបន្សុទ្ធខ្យល់ក្នុងតំបន់គម្រោង។
ឃ. ការរំខានដោយសំលេង និងរំញ័រ៖ នឹងបង្កឲ្យមានសំលេងនិងរំញ័រដែលបណ្តាលមកពីការដឹកជញ្ជូនថ្មរ៉ែ ដំណើរការបំបែកថ្មរ៉ែ ដំណើរការចម្រាញ់ និងដំណើរការម៉ាស៊ីនភ្លើង ជាដើម។			✓		• ក្រុមហ៊ុនកំណត់ពេលវេលាធ្វើការយ៉ាងច្បាស់លាស់ (ម៉ោងចេញ-ចូល)។ • រៀបចំបន្ទប់ម៉ាស៊ីនភ្លើង ម៉ាស៊ីនប្រព្រឹត្តិកម្មសំណល់រាវ និងម៉ាស៊ីនចម្រាញ់រ៉ែ ព្រមទាំងបំពាក់ឧបករណ៍កាត់បន្ថយសំលេងប្រកបដោយប្រសិទ្ធិភាព។

2P, St ... Sk.Te... Khan ... Keo, ... Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
					• បំពាក់ឧបករណ៍កាត់បន្ថយសំលេង និងកម្រិតរំញ័រ ដែលអនុឡោមទៅតាមស្តង់ដារថ្នាក់ជាតិ។
ង. គុណភាពទឹក៖ អាចនឹងធ្វើឲ្យគោករាក់ និងស្ទះចរន្តទឹករបស់អូរ និងបឹងនានានៅក្បែរតំបន់កាយយករ៉ែ ជាពិសេសពេលមានភ្លៀងធ្លាក់។ ម្យ៉ាងវិញទៀត វាអាចធ្វើឲ្យមានការបំពុលទឹក (ទឹកសំបូរនូវកករ និងសារធាតុរ៉ែ) ដល់ប្រព័ន្ធទឹក និងបឹងទាំងនោះផងដែរ។			✓		• ត្រូវរកទីតាំងស្តុករ៉ែ និងចម្រាញ់រ៉ែ ឲ្យឆ្ងាយពីតំបន់ខ្សែទឹកហូរ និងជាពិសេសស្ថានភាពទីតាំងមានលក្ខណៈសុវត្ថិភាពដល់ដំណើរការចម្រាញ់។ • បង្កើតទីតាំងស្តុកសំរាម ដោយមានការបែងចែកត្រឹមត្រូវ និងដឹកជញ្ជូនទៅកាន់ទីតាំងច្បាស់លាស់។ • ជីកស្រះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីផ្គត់ផ្គង់សង្វាក់ផលិតកម្ម និងការប្រើប្រាស់ក្នុងអាជីវកម្ម។ • មិនប្រើប្រាស់សរធាតុគីមីគ្រោះថ្នាក់ក្នុងដំណើរការអាជីវកម្ម។ • សាងសង់អាងប្រព្រឹត្តិកម្មសំណល់រាវ ដែលត្រឹមត្រូវតាមបច្ចេកទេស។ • អនុវត្តទៅតាមបទដ្ឋានស្តង់ដារទឹកថ្នាក់ជាតិ មុននឹងបង្ហូរចូលក្នុងប្រភពទឹកធម្មជាតិ។ • សំណល់ភក់ពីអាងប្រព្រឹត្តិកម្មសំណល់រាវ នឹងបញ្ជូនទៅកាន់អាងស្តុកបិទជិត ដែលបានបំពាក់បច្ចេកទេសត្រឹមត្រូវ។
២-ធនធានជីវសាស្ត្រ					
ក. ព្រៃឈើ ជម្រក និងសត្វព្រៃ៖ នឹងធ្វើឲ្យបាត់បង់ព្រៃឈើទៅតាមទីតាំងនីមួយៗពីការឈូសឆាយបកដីព្រៃចេញ ដែលជា				✓	• ធ្វើការឈូសឆាយទៅតាមប្លង់មេ ដោយកំណត់ពីព្រំដីដែលត្រូវឈូសឆាយ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ហេតុបណ្តាលឲ្យមានផលប៉ះពាល់ដល់គម្របដី កូនឈើ អនុផលព្រៃឈើ និងជម្រកសម្រាប់ពពួកសត្វលើដីក្នុងតំបន់គម្រោង។					• ក្រុមហ៊ុនធ្វើការជីករ៉ែដោយប្រុងប្រយ័ត្ន បើអាចជៀសវាងការប៉ះពាល់ដល់ព្រៃឈើបាន ក្រុមហ៊ុននឹងបញ្ចៀសរាល់ការប៉ះពាល់។ • មុននឹងធ្វើការឈូសឆាយ និងកាប់ឈើដើម្បីបើកអណ្តូងរ៉ែនៅក្នុងតំបន់គម្រោង ត្រូវសហការជាមួយក្រុមការងារអន្តរក្រសួង ធ្វើការវាយតម្លៃឈើឈរ ដើម្បីបង់ថវិកាចូលរដ្ឋ។
ខ. ជីវចម្រុះក្នុងទឹក៖ អាចធ្វើឲ្យពពួកជីវចម្រុះក្នុងទឹកមួយចំនួនធ្វើបំលាស់ទី និងបាត់បង់ជីវិត ដែលបណ្តាលមកពីការបំពុលទឹក តាមរយៈសកម្មភាពឈូសឆាយ និងការហូរសំណល់អាចម៍ដីចូលក្នុងប្រព័ន្ធទឹក			✓		• នឹងរក្សាទុកព្រៃចាំបាច់ដែលជាជម្រករបស់សត្វព្រៃ ដោយធ្វើការឈូសឆាយ និងជីកយករ៉ែតាមប្លង់មេប៉ុណ្ណោះ។ • កំណត់ពេលវេលាក្នុងការធ្វើការឲ្យបានច្បាស់លាស់មិនរំខានធ្ងន់ធ្ងរដល់សត្វព្រៃដែលនៅក្បែរទីតាំងអាជីវកម្ម។ • សាងសង់ប្រព័ន្ធលូឲ្យបានត្រឹមត្រូវ ដើម្បីជៀសវាងការហូរសំណល់រាវចូលក្នុងទឹក។ • ចូលរួមថែទាំនូវគុណភាពទឹកអូរ បឹង ព្រមទាំងការពារការហូរច្រោះដី។ • បង្កើតទីតាំងស្តុកសំណល់រឹងបណ្តោះអាសន្ន និងគ្រប់គ្រងត្រឹមត្រូវ។
៣-ធនធានសេដ្ឋកិច្ច-សង្គម					
ក. មុខរបរ និងប្រាក់ចំណូល៖ អាចធ្វើឲ្យបាត់បង់ប្រាក់ចំណូល និងមុខរបរបន្ទាប់បន្សំ ដោយសារព្រៃដែលទីកន្លែងរកអនុផលព្រៃឈើត្រូវបានឈូសឆាយ		✓			• បន្តអនុញ្ញាតិឲ្យប្រជាពលរដ្ឋ ដែលធ្លាប់ទៅស្វែងរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោងចូលទៅជាធម្មតា ដោយមានការអនុញ្ញាតិពីក្រុមហ៊ុនជៀសវាងជនខិលខូចបន្លំចូលកាប់ឈើ

2P, St ... Sk.Tel ... Khan ... Keo, ... Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ខ.សុខភាព និងសុខមាលភាពសាធារណៈ ៖ អាចកើតមាននូវជំងឺផ្លូវដង្ហើម សើស្បែក គ្រុនចាញ់ រាគរូស គ្រុនពោះវៀន ចំពោះបុគ្គលិក-កម្មករខ្វះការប្រុងប្រយ័ត្នដោយប្រើទឹកមិនស្អាត មិនប្រើបង្គន់អនាម័យ និងការស្នាក់នៅមិនសរម្យ។ ចំពោះការដ្ឋានយករ៉ែអាចកើតមានជំងឺផ្លូវដង្ហើម ដោយសារខ្វះសម្ភារៈការពារសុវត្ថិភាព			✓		• រៀបចំផ្គត់ផ្គង់ទឹកស្អាត (អណ្តូងស្នប់) ដល់កម្មករ និងផ្តល់សេវាសុខភាព ដល់កម្មករតាមរយៈពិនិត្យ និងព្យាបាលជំងឺ។ • រៀបចំសំអាតបរិស្ថានក្នុងបរិវេណទីស្នាក់ការ និងកន្លែងស្នាក់នៅ ព្រមទាំងសាងសង់បង្គន់អនាម័យ។ • ធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីរបៀបអនុវត្តអនាម័យ។ • នឹងផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពដល់កម្មករដែលធ្វើការក្នុងការដ្ឋាន និងពន្យល់ពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះ។ • អប់រំ ណែនាំកម្មករឲ្យមានបំរុងប្រយ័ត្នពល់ការគ្រោះថ្នាក់ផ្សេងៗ នៅពេលបំពេញការងារ ដោយប្រកាន់ខ្ជាប់សុវត្ថិភាពជាចំបង។ • ក្រុមហ៊ុនមានផែនការផ្តល់ជូន នូវការធានារ៉ាប់រងអាយុជីវិតរបស់បុគ្គលិក និងកម្មករនៅពេលបំពេញការងារ។
គ. ការតាំងទីលំនៅ៖ តាមរយៈការចុះសិក្សាផ្ទាល់ពីស្ថានភាពសង្គមសេដ្ឋកិច្ច នៅក្នុងតំបន់អាជីវកម្មរបស់ក្រុមហ៊ុនបង្ហាញថា មិនមានផលប៉ះពាល់ដល់ដីធ្លី និងស្រែចំការរបស់ប្រជាពលរដ្ឋឡើយ ដោយសារក្រុមហ៊ុនអាជីវកម្មបានធ្វើការដោះស្រាយរួចរាល់។		✓			• ក្រុមហ៊ុននឹងបង់ថវិកាទូរដេងជូនប្រជាពលរដ្ឋរងគ្រោះលើដំណាំ និងទិន្នផលដែលពួកគាត់ទទួលបានក្នុងមួយឆ្នាំៗ សម្រាប់ស្រែចំការអចិន្ត្រៃយ៍ និងប៉ះប៉ូវសងជាថវិកាសម្រាប់កម្លាំងពលកម្មដែលបានកាប់ឆ្ការរួចចំពោះស្រែចំការពនេចរ ហើយថវិកានេះនឹងប្រគល់ដល់ប្រជាពលរដ្ឋដោយផ្ទាល់ ដោយមានការដឹងលឺពីអាជ្ញាធរដែនដី។ • ចំពោះរណ្តៅដែលលុបដីរួច ក្រុមត្រូវផ្ទេរទៅឲ្យម្ចាស់ដើមវិញ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
					• ចំពោះផលប៉ះពាល់លើដីដែលមានដើមឈើ ឬទីសក្ការៈបូជា (អារក្ស-អ្នកតា) ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីសុំយោបល់ និងសម្រេចចិត្តពីសំណាក់រដ្ឋាភិបាល
ឃ. ហេដ្ឋារចនាសម្ព័ន្ធៈ ទាំងដំណាក់កាលមុនប្រតិបត្តិគម្រោង និងដំណាក់កាលប្រតិបត្តិគម្រោង ការដឹកជញ្ជូនសម្ភារៈចូលក្នុងតំបន់គម្រោង និងគ្រឿងចក្រអាចមានផលប៉ះពាល់ ខូចខាតដល់ផ្លូវសាធារណៈដែលបានសាងសង់ និងប្រើប្រាស់ដោយសហគមន៍ក្នុងតំបន់នោះ រួមទាំងអាចបណ្តាលឲ្យមានបញ្ហាចរាចរណ៍កកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។			✓		• ក្រុមហ៊ុនបានចូលរួមសាងសង់ និងជួសជុលផ្លូវលំក្នុងសហគមន៍ ដើម្បីសំរួលដល់ការធ្វើចរាចរណ៍ នៅក្នុងតំបន់។ • ក្រុមហ៊ុនបានកំណត់ពីល្បឿនក្នុងការបើកបរ ៣០គ.ម/ម៉ោង រួមទាំងពង្រឹងការបើកបរដោយប្រុងប្រយ័ត្ន ជៀសវៀងការធ្វេសប្រហែស ឬការបើកបរដោយប្រើប្រាស់គ្រឿងស្រវឹងជាដើម។
ង. តំបន់ប្រវត្តិសាស្ត្រៈ អាចធ្វើឲ្យប៉ះពាល់ដល់ទីតាំងប្រវត្តិសាស្ត្រ ដែលមានដូចជាប្រាសាទបុរាណ ស្ពានបុរាណ និងទីតាំងផ្សេងៗទៀត ដែលអាជ្ញាធរអប្សរាមិនទាន់បានកំណត់ជាទីតាំងស្រាវជ្រាវ ឬទីតាំងអភិរក្ស។			✓		• ទាក់ទងនឹងតំបន់ប្រវត្តិសាស្ត្រ ទោះបីជាពុំទាន់មានការស្រាវជ្រាវពីតំបន់ប្រវត្តិសាស្ត្រក្នុងតំបន់គម្រោងក៏ដោយ ក្រុមហ៊ុនត្រូវមានវិធានការអប់រំណែនាំ ឲ្យយល់ពីអត្ថប្រយោជន៍អំពីតំបន់ប្រវត្តិសាស្ត្រ (ត្រូវរក្សាទុក) និងក្រើនរំលឹកជានិច្ចដល់អ្នកឈូសឆាយរបស់ខ្លួន។ ជាក់ស្តែង ខណៈពេលឈូសឆាយជួប និងមានការសង្ស័យលើតំបន់ណាមួយ ត្រូវធ្វើការរាយការណ៍ជូនស្ថាប័នពាក់ព័ន្ធជាពិសេសអាជ្ញាធរអប្សរា ដើម្បីចុះធ្វើការត្រួតពិនិត្យ និងកំណត់ជាតំបន់អភិរក្ស។

Draft

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ច. ការប្រើប្រាស់ទឹកៈ អាចធ្វើឲ្យប៉ះពាល់ដល់ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ របស់ប្រជាជនតិចតួចបំផុត ដោយសារសង្វាក់ផលិតកម្មត្រូវការទឹកសម្រាប់ប្រតិបត្តិការ ឬប្រើប្រាស់ផ្សេងៗ។			✓		• ត្រូវប្រើប្រាស់ប្រភពពីទឹកភ្លៀង និងស្រះមួយចំនួនដែលក្រុមហ៊ុនបានធ្វើទំបន់ទប់សម្រាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្ម។ • ត្រូវជីកអណ្តូង ដើម្បីយកទឹកមកប្រើប្រាស់ សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់បុគ្គលិក-កម្មករ ដើម្បីកាត់បន្ថយការទាញយកទឹកអូរមកប្រើប្រាស់។ ក្នុងករណីជៀសវាងមិនបានក្រុមហ៊ុនត្រូវប្រើប្រាស់ទឹកតិចបំផុតតាមលទ្ធភាពអាចធ្វើបាន។
ឆ. គ្រោះធម្មជាតិ និងបំរែបំរួលអាកាសធាតុៈ គ្រោះធម្មជាតិ និងគ្រោះអាសន្នផ្សេងៗដូចជា រញ្ជួយដី រន្ទះបាញ់ ខ្យល់ព្យុះ គ្រោះទឹកជំនន់ និងគ្រោះអគ្គីភ័យអាចកើតមានឡើងជាយថាហេតុ។ គ្រោះធម្មជាតិ និងគ្រោះអាសន្នទាំងអស់សុទ្ធតែអាចបង្កឲ្យមានការខូចខាត និងបាក់ស្រុតរណ្តៅជីកយករ៉ែ ឬការដ្ឋាន ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់កម្មករ ឬប្រជាជនដែលធ្វើការ និងស្នាក់នៅក្បែរៗនោះ។ កត្តានៃការប្រែប្រួលអាកាសធាតុនឹងចូលរួមចំណែក ធ្វើឲ្យមានការប៉ះពាល់ដល់ការងាររុករករ៉ែផងដែរ ដូចជាកំដៅកើនឡើង ឬភ្លៀងធ្លាក់មិនទៀងទាត់ជាដើម ដែលជាកត្តារាំងស្ទះដល់ដំណើរការអាជីវកម្ម។		✓			• ត្រូវធ្វើអាជីវកម្មរ៉ែដោយប្រុងប្រយ័ត្នអំពីបញ្ហាអគ្គិភ័យ ដែលអាចកើតឡើងជាយថាហេតុ ដោយត្រូវបំពាក់នូវបំពង់ពន្លត់អគ្គិភ័យ និងឧបករណ៍សុវត្ថិភាពផ្សេងៗនៅគ្រប់ទីតាំងធ្វើអាជីវកម្ម និងការដ្ឋាន។ • ត្រូវបំពាក់ឧបករណ៍ ឬតាមដានកម្រិតរញ្ជួយដីនៅតាមរណ្តៅនីមួយៗ ដើម្បីបញ្ចៀសការបាក់ស្រុតដីដោយប្រការថៃជន្យណាមួយ។ • ត្រូវធ្វើការណែនាំដល់បុគ្គលិក-កម្មករឲ្យយល់អំពីបញ្ហាភ្លើងឆេះព្រៃ និងគ្រោះអាសន្ននានា ព្រមទាំងបង្កើតសលាកសញ្ញាប្រាប់ដំណឹង និងហាមឃាត់។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ដំណាក់កាលបញ្ចប់គម្រោង					
១-ធនធានរូបសាស្ត្រ					
ក. សណ្ឋានដី និងឋានលេខា៖ សកម្មភាពគម្រោងដែលធ្វើអាជីវកម្មយករ៉ែទង់ដែងនឹងបន្សល់ទុកនូវរណ្ដៅធំ តូចជាច្រើន។ ជាក់ស្ដែងនៅពេលបញ្ចប់ដំណើរការគម្រោង ក្រុមហ៊ុនបានបន្សល់ទុកនូវអណ្ដូងរ៉ែចំនួន ៧កន្លែង។			✓		• ក្រុមហ៊ុននឹងធ្វើការលុបបំពេញរណ្ដៅ ដែលបានបកជីរួច ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធមកពិនិត្យ និងវាយតំលៃ។ • បច្ចេកទេសនៃការលប់រណ្ដៅគឺ ស្រទាប់ទី១ ដាក់អាចម៍ដីធម្មតា ស្រទាប់ទី២ដាក់អាចម៍រ៉ែ និងស្រទាប់ទី៣ ដាក់ស្រទាប់ដីដែលបកពីផ្ទៃកខាងលើ។ • ក្រុមហ៊ុនជីកបើករណ្ដៅម្ដងមួយៗ ដើម្បីងាយស្រួលគ្រប់គ្រងអាចម៍ដី និងងាយស្រួលលប់បំពេញវិញ។ • បន្ទាប់ពីចាក់ដីលប់បំពេញរណ្ដៅរ៉ែវិញ ក្រុមហ៊ុននឹងធ្វើការដាំដើមឈើឡើងវិញ ដើម្បីរក្សាគ្របព្រៃឈើក្នុងតំបន់ឡើងវិញ។
ខ. គុណភាពដី៖ ការបកយកស្រទាប់ដីចេញ នៅតាមអណ្ដូងរ៉ែនីមួយៗ អាចធ្វើឲ្យខូចដល់គុណភាពដី ដោយសារការទុកដីចោល ដែលធ្វើឲ្យមានការហូរច្រោះដី និងខ្សោះអស់ជីវជាតិដី។ ម៉្យាងទៀតនៅពេលលប់រណ្ដៅរ៉ែវិញ ប្រសិនបើមិនអនុវត្តតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ ក៏អាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពដីផងដែរ។			✓		• ក្រុមហ៊ុនធ្វើការជីករណ្ដៅរ៉ែម្ដង១ ម្ដង១ ទៅតាមគម្រោងប្លង់មេ រួចរក្សាទុកអាចម៍ដីឲ្យបានត្រឹមត្រូវតាមបច្ចេកទេស។ • រក្សាទុកអាចម៍ដី ឲ្យបានត្រឹមត្រូវដើម្បីកុំឲ្យមានការហូរច្រោះដី ម៉្យាងទៀតរាល់ទីតាំងទុកអាចម៍ដី ត្រូវបានទីតាំងក្បែរ និងរណ្ដៅរ៉ែ ដើម្បីងាយស្រួលលប់នៅពេលជីកចប់។ • អណ្ដូងរ៉ែនីមួយៗ ក្រុមហ៊ុននឹងដាំដើមឈើឡើងវិញ ដើម្បីរក្សាសណ្ឋានដី ការពារការហូរច្រោះដី និងបង្កើនគុណភាពដីឡើងវិញ។

22P, St ... Sk.Te ... Khan ... Keo, ... Penh
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
គ. គុណភាពទឹក៖ នៅក្នុងដំណាក់កាលបញ្ចប់គម្រោងគម្រោងនេះ អាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពទឹក ដោយសារការហូរច្រោះដី។ ការលប់អណ្តូងរ៉ែវិញ អាចធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពទឹក និងអាចមានការជោរជន់លិច ហូរហោរទឹកចេញពីអណ្តូងរ៉ែ និងអាចហូរចូលក្នុងប្រភពទឹកដែលនៅក្បែរ និងជុំវិញតំបន់គម្រោង។ ម៉្យាងទៀត សំណល់រឹង-រាវដែលចេញពីផ្ទះកម្មកររ៉ែ ក៏អាចមានការប៉ះពាល់ដល់គុណភាពទឹកផងដែរ។					• ក្រុមហ៊ុនមានជីកអាងស្តុកទឹកទុក ដាច់ដោយឡែកពីអណ្តូងរ៉ែ ដើម្បីរក្សាទឹកទុកសម្រាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្មក្នុងរោងចក្រផលិតរ៉ែពាក់កណ្តាលសម្រេច។ • គ្រប់អណ្តូងរ៉ែនីមួយៗ ក្រុមហ៊ុននឹងបំពាក់ប្រព័ន្ធបូម និងបង្ហូរទឹកឲ្យបានគ្រប់គ្រាន់ក្នុងអណ្តូងរ៉ែ ដើម្បីបូមទឹកទៅកាន់អាងស្តុកទឹក។ • នៅពេលបញ្ចប់អាជីវកម្មក្រុមហ៊ុន យកសំណាកទឹកតាមបឹង អូរសំខាន់ៗដែលនៅជុំវិញតំបន់គម្រោងដើម្បីវិភាគគុណភាពទឹក ដូចជា បឹងធ្នូ១ សំណាក អូរខ្វារ១សំណាក និងស្ទឹងជីក្រែង១សំណាក។ • ទឹកចេញពីរណ្តៅរ៉ែ ក្រុមហ៊ុនមិនបង្ហូរចេញពីក្រៅដាច់ខាត ទោះបីពេលលប់រណ្តៅវិញក៏ដោយ គឺក្រុមហ៊ុននឹងបូមទឹកនេះ ទៅកាន់អាងស្តុកទឹកបន្ទាប់មកទើបធ្វើការលប់។ • សំណល់រឹង-រាវដែលបញ្ចេញនៅតាមផ្ទះកម្មករក្រុមហ៊ុនធ្វើការសំអាតឲ្យបានត្រឹមត្រូវនៅពេលរុះរើការដ្ឋាន និងផ្ទះបុគ្គលិក-កម្មករ។
២-ធនធានជីវសាស្ត្រ					
ក. ព្រៃឈើ ជម្រកសត្វ និងសត្វព្រៃ៖ ទីតាំងដែលបានកាយរួចនឹងក្លាយជារណ្តៅ និងតំបន់វាល ដែលជាឧបសគ្គមួយក្នុងការបំលាស់ទីរបស់សត្វ។ ក្នុងករណីយនេះក្រុមហ៊ុនបានបង្កើតមូលនិធិបរិស្ថាន សម្រាប់ដាំដើមឈើឡើងវិញ និងការស្តារព្រៃឈើឡើងវិញ។			✓		• ក្រុមហ៊ុននឹងធ្វើការដាំដើមឈើឡើងវិញនៅលើទីតាំងទាំងឡាយណា ដែលខូចខាតដោយសារការប្រតិបត្តិគម្រោងនេះ។ • ជ្រើសរើសប្រភេទកូនឈើដែលល្អ និងសាកសមជាមួយប្រភេទដីនិងស្ថានភាពភូមិសាស្ត្រក្នុងតំបន់។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
៣-ធនធានបរិស្ថាន-សង្គម					
ក. ការប្រើប្រាស់ទឹក៖ នឹងមានការប៉ះពាល់តិចតួចដល់គុណភាពទឹកអូរ-ស្ទឹងផ្នែកក្រោម ដែលប្រជាជនប្រើប្រាស់សព្វថ្ងៃ ដោយសារមានការហូរសារធាតុគីមីចេញពីទីតាំងស្តុកសំណល់រឹង-រាវ ក្នុងករណីដែលទីតាំងគម្រោងមិនបានធ្វើការប្រព្រឹត្តិកម្មសំណល់រាវមុននឹងបញ្ចេញចោល។		✓			• មុននឹងបញ្ចប់គម្រោង ក្រុមហ៊ុននឹងធ្វើការត្រួតពិនិត្យ និងសំអាតទីតាំងដាក់សំណល់រឹង-រាវឲ្យបានត្រឹមត្រូវមុននឹងចាកចេញ។
ខ. មុខរបរ និងប្រាក់ចំណូល៖ នឹងធ្វើឲ្យបាត់បង់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនក្នុងតំបន់ ដែលអាស្រ័យផលនៅក្នុងទីតាំងគម្រោង។		✓			• តាមការពិតជាក់ស្តែងការបញ្ចប់គម្រោង គឺវាតែងតែធ្វើឲ្យប្រជាពលរដ្ឋគ្មានការងារធ្វើ។ ជាដំណោះស្រាយ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងឲ្យបានដឹងក្នុងរយៈពេល ០៣ខែមុនពេលគម្រោងត្រូវបិទ។ ស្របពេលជាមួយគ្នានេះដែរ ក្រុមហ៊ុននឹងផ្តល់នូវមូលនិធិសង្គមតាមសភាពជាក់ស្តែង ហើយក្រុមហ៊ុននឹងជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធឲ្យបានដឹងលឺផងដែរ។
គ. ផ្លូវគមនាគមន៍៖ នឹងមានផលប៉ះពាល់តិចតួចដល់ប្រព័ន្ធគមនាគមន៍ និងផ្លូវធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារការដឹកជញ្ជូនសម្ភារៈ គ្រឿងចក្រ និងគ្រឿងយន្តចេញពីតំបន់គម្រោង។		✓			• ជាដំណោះស្រាយចំពោះផ្លូវធ្វើដំណើរនេះ ក្រុមហ៊ុននឹងរៀបចំផែនការដឹកជញ្ជូនសម្ភារៈ គ្រឿងចក្រ និងគ្រឿងយន្តឲ្យស្របតាមច្បាប់ចរាចរផ្លូវគោក។ • ក្រុមហ៊ុនពិនិត្យលទ្ធភាព ដើម្បីធ្វើការជួសជុលផ្លូវ និងស្ពានក្នុងករណីដែលការដឹកជញ្ជូននេះធ្វើឲ្យខូចខាតផ្លូវ។

Draft

៧.៥- ពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមវិជ្ជមាន

ដោយផ្អែកទៅលើទំហំនៃសកម្មភាពរបស់គម្រោងជាទូទៅ នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងនេះ ហេតុប៉ះពាល់បរិស្ថានចំពោះសេដ្ឋកិច្ច-សង្គម គឺមានភាពវិជ្ជមានដោយសារតែគម្រោងអាជីវកម្មរ៉ែទង់ដែងនេះ បានចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច ដូចជាប្រាក់ចំណូលបានមកពីភាពមានការងារធ្វើចំពោះប្រជាជននៅតំបន់គម្រោង ជាពិសេសហេដ្ឋារចនាសម្ព័ន្ធថ្មី ដែលប្រជាជននៅក្នុងតំបន់គម្រោង និងនៅជុំវិញតំបន់គម្រោងអាចទទួលបានដូចជា៖ ប្រព័ន្ធផ្លូវថ្នល់ និងការពង្រីកផ្លូវថ្នល់ ដែលបានផ្តល់នូវភាពងាយស្រួលក្នុងការធ្វើដំណើរ។

៧.៥.១- សាលារៀន និងមណ្ឌលសុខភាព

- ក្រុមហ៊ុនបានជួយចាក់បេតុងក្នុងទីធ្លាសាលារៀននៅតំបន់គម្រោង។
- ជួយសាងសង់បង្គន់អនាម័យដល់មណ្ឌលសុខភាពឃុំខ្វារ

៧.៥.២- ហេដ្ឋារចនាសម្ព័ន្ធ

- ក្រុមហ៊ុនបានជួយពង្រីកផ្លូវ និងក្រាលគ្រួសក្រហមផ្លូវពីទីរួមស្រុកកំពង់ក្តីទៅឃុំខ្វារចំនួន ២ដង ដែលចំណាយទឹកប្រាក់អស់ ៣៨៥,០០០ដុល្លារអាមេរិក។
- ក្រុមហ៊ុនបានជួយជួសជុលស្ពានចំនួន ៥ ដែលចំណាយទឹកប្រាក់អស់ ៣០,០០០ដុល្លារអាមេរិក។

៧.៥.៣- មុខរបរ និងប្រាក់ចំណូល

- បង្កើនមុខរបរ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋក្នុងតំបន់ ពិសេសប្រជាពលរដ្ឋនៅក្នុងឃុំខ្វារ តាមរយៈ ការជ្រើសរើសឲ្យចូលបំរើការងារនៅក្នុងតំបន់គម្រោង និងទទួលបាននូវមុខរបរបន្ថែម ដូចជាការលក់ដូរទំនិញ ម្ហូបអាហារសម្រាប់ការហូបចុករបស់បុគ្គលិក-កម្មករ និងការផ្តល់ជូននូវសេវាកម្មផ្សេងៗ ជាច្រើនទៀត។

៧.៥.៤- ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

- គម្រោងនឹងជួយបង្កើនប្រាក់ចំណូលជាតិ តាមរយៈការបង់ពន្ធផ្សេងៗដល់រដ្ឋាភិបាល នៅកំឡុងពេលធ្វើអាជីវកម្មរបស់ក្រុមហ៊ុន ដែលជាការរួមចំណែកមួយ ក្នុងការទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ។ តាមរយៈរបាយការណ៍របស់ក្រុមហ៊ុន បានបង្ហាញថា ក្រោយរយៈពេល ១០ឆ្នាំ នៃការបញ្ចប់កិច្ចសន្យាជាមួយរដ្ឋាភិបាល ក្រុមហ៊ុននឹងបង់ពន្ធជូនរដ្ឋ។ ប្រហែល **៨៩,៥៧លានដុល្លារ**។

Draft

ជំពូកទី៨៖
ផែនការគ្រប់គ្រងបរិស្ថាន

Draft

ជំពូកទី៨៖ ផែនការគ្រប់គ្រងបរិស្ថាន

៨.១- សេចក្តីផ្តើម

ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) គឺជាផែនការមួយដែលត្រូវរៀបចំឡើងដោយម្ចាស់គម្រោងស្ថិតក្រោមកិច្ចសហការចុះត្រួតពិនិត្យពីស្ថាប័នជំនាញចម្រុះដែលពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោងក្នុងគោលដៅកាត់បន្ថយហេតុប៉ះពាល់ដែលអាចនឹងកើតមាន។ ផែនការគ្រប់គ្រងបរិស្ថានធ្វើឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលបានលើកឡើងនៅក្នុងជំពូកស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីឲ្យប្រាកដថារាល់វិធានការទាំងអស់ដែលបានលើកឡើងត្រូវបានអនុវត្ត ដោយម្ចាស់គម្រោងនៅរាល់ដំណាក់កាលដែលគេរកឃើញថាមានហេតុប៉ះពាល់។ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវកំណត់ឱ្យបានច្បាស់លាស់ទៅលើហេតុប៉ះពាល់ទីតាំងដែលត្រូវត្រួតពិនិត្យ រយៈកាលតាមដាន និងសមាសភាពអ្នកចូលរួមត្រួតពិនិត្យ។

ផែនការនេះត្រូវគូសបញ្ជាក់អំពីកិច្ចការពារបរិស្ថាន និងវិធានការនានាដែលត្រូវអនុវត្តនៅពេលកំពុងធ្វើការសាងសង់ ពេលប្រតិបត្តិគម្រោង និងពេលបញ្ចប់គម្រោងដោយគោរពទៅតាមច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងគោលបំណងកាត់បន្ថយ ឬក៏លុបបំបាត់ចោលនូវហេតុប៉ះពាល់អាក្រក់ដែលអាចកើតមាន (Adverse impacts)។

ក្នុងលក្ខខណ្ឌដែលវិធានការគ្រប់គ្រងបរិស្ថាន និងសង្គមមិនបានបញ្ចូលទៅក្នុងការរៀបចំគម្រោងលំអិត និងកិច្ចសន្យាផ្សេងៗ ដែលទាក់ទងនឹងការងារដែលបានស្នើសុំនោះទេ ការប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមាន នឹងកើតឡើងដោយប្រការណាមួយជាពុំខាន។ ការអនុវត្តនេះមានប្រសិទ្ធិភាព ទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គម។ ការងារនេះអាចសម្រេចបានដោយការរៀបចំ និងគោរពតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គមលំអិត ក្នុងកម្មវិធីបណ្តុះបណ្តាល និងអង្កេតតាមដាននៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង។

៨.២- ការគ្រប់គ្រងបរិស្ថាន

ការអនុវត្ត ផ.គ.ប នេះជាកាតព្វកិច្ចរបស់ក្រុម ឬផ្នែក ឬការិយាល័យបរិស្ថានដែលបានបង្កើតឡើងដោយក្រុមហ៊ុន និងស្ថិតនៅក្រោមការត្រួតពិនិត្យពីម្ចាស់ក្រុមហ៊ុនដោយមានការចូលរួមសហការជាមួយក្រសួងបរិស្ថាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៨.២.១- ការទទួលខុសត្រូវរបស់គណៈកម្មការអន្តរក្រសួង

សមាសភាពគណៈកម្មការអន្តរក្រសួងមានដូចខាងក្រោម៖

១. ក្រសួង ឬ មន្ទីរបរិស្ថានខេត្តសៀមរាប

២. ក្រសួង ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប

៣. ក្រសួង ឬ មន្ទីរទេសចរណ៍ខេត្តសៀមរាប

៤. ក្រសួង ឬមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប

៥. ក្រសួង ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប

៦. ក្រសួង ឬមន្ទីរវប្បធម៌ វិចិត្រ និងសិល្បៈខេត្តសៀមរាប

៧. ក្រសួង ឬមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប

៨. សាលាខេត្តសៀមរាប

៩. រដ្ឋបាលព្រៃឈើ ឬនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តសៀមរាប

១០. សាលាស្រុកជីក្រែង

សមាជិកនៃគណៈកម្មការខាងលើនេះ គឺស្ថិតនៅក្រោមការចង្អុលបង្ហាញ និងណែនាំពីក្រសួងបរិស្ថាន។ គណៈកម្មការនេះត្រូវចុះពិនិត្យទីតាំងជាក់ស្តែងជាបន្ទាន់ ករណីមានការប្រែប្រួលបរិស្ថានខ្លាំងក្នុងតំបន់គម្រោង ដើម្បីជួយរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងទប់ស្កាត់ហានិភ័យដែលនឹងកើតមានឡើង។

ជាទូទៅ ក្រសួងបរិស្ថានដែលមាននាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានតែងតែចុះអង្កេតតាមដានពីសកម្មភាពគម្រោងរៀងរាល់ ៣ខែ ៦ខែ ឬ០១ឆ្នាំម្តង។

ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចទទួលខុសត្រូវសម្របសម្រួល និងដោះស្រាយរាល់បញ្ហាដែលនឹងកើតមានឡើងនៅក្នុងតំបន់គម្រោង។

៨.២.២- ការទទួលខុសត្រូវរបស់ម្ចាស់គម្រោង

ដើម្បីកំណត់ និងធ្វើការកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន ដែលអាចកើតមានដោយសារសកម្មភាពគម្រោងអាជីវកម្ម **រ៉ែទង់ដែង** ម្ចាស់ក្រុមហ៊ុន ត្រូវទទួលខុសត្រូវទាំងស្រុងលើគ្រប់សកម្មភាពសាងសង់ និងប្រតិបត្តិគម្រោង ដែលនឹងបង្កគ្រោះថ្នាក់ដល់ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គម។ ការត្រួតពិនិត្យ និងតាមដានប្រចាំសប្តាហ៍ ឬប្រចាំខែក្នុងតំបន់គម្រោងនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោង។

៨.២.៣- ការធ្វើរបាយការណ៍

អ្នកត្រួតពិនិត្យបរិស្ថានចូលរួម នៅកន្លែងសាងសង់ជាមួយនឹងបុគ្គលិក ហើយនឹងផ្តល់ព័ត៌មានអ្វីដែលកើតឡើងនៅរយៈពេលខ្លីខាងមុខនៅទីនោះ។ អ្នកត្រួតពិនិត្យបរិស្ថានរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាសសម្រាប់ដាក់ជូនទៅភ្នាក់ងារពាក់ព័ន្ធដូចជា ក្រសួងបរិស្ថានជាដើម។

តារាង ៨.១៖ ផែនការគ្រប់គ្រងបរិស្ថាន និងការទទួលខុសត្រូវ

សកម្មភាព	ការអនុវត្ត និង ការទទួលខុសត្រូវ
ការប្រមូលទិន្នន័យ	ម្ចាស់គម្រោង និង ទីប្រឹក្សាគម្រោង
ការវិភាគទិន្នន័យ	ម្ចាស់គម្រោង និង ទីប្រឹក្សាគម្រោង
ការធ្វើរបាយការណ៍: -ប្រចាំខែ -ប្រចាំត្រីមាស និង -ប្រចាំឆ្នាំ	ការិយាល័យគ្រប់គ្រងគម្រោង និង ទីប្រឹក្សាគម្រោង
ការទទួលរបាយការណ៍: -ប្រចាំឆមាស	– ក្រសួង ឬ មន្ទីរបរិស្ថានខេត្តសៀមរាប – ក្រសួង ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប – ក្រសួង ឬ មន្ទីរទេសចរណ៍ខេត្តសៀមរាប – ក្រសួង ឬមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប – ក្រសួង ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប – ក្រសួង ឬមន្ទីរវប្បធម៌ និងវិចិត្រ សិល្បៈខេត្តសៀមរាប – ក្រសួង ឬមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប – សាលាខេត្តសៀមរាប – អាជ្ញាធរអប្សរាខេត្តសៀមរាប – រដ្ឋបាលព្រៃឈើ ឬនាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តសៀមរាប – សាលាស្រុកជីក្រែង
ការផ្តល់យោបល់/ប្រឹក្សា	– ទីប្រឹក្សាគម្រោង

៨.៣ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននេះ ក្រុមហ៊ុនលើកយកនូវចំណុចហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងវិធានការកាត់បន្ថយជាលក្ខណៈសង្ខេបបំផុត។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនត្រូវតែអនុវត្តឱ្យបានរាល់ការលើកឡើងពីហេតុប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយដែលមានរៀបរាប់នៅក្នុងជំពូកស្តីពីហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ ដោយធ្វើយ៉ាងណាអាចធានាបាននូវដំណើរការអភិវឌ្ឍគម្រោងនេះឱ្យមាន និរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ច-សង្គម។ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយមានបញ្ជាក់ដូចខាងក្រោមៈ

៨.៣.១- ហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ

ក. ដំណាក់កាលរុករក

ការត្រួតពិនិត្យក្នុងកំឡុងពេលរុករករ៉ែទង់ដែងក្រុមហ៊ុនអាជីវកម្ម ត្រូវអនុវត្តចំពោះហេតុប៉ះពាល់បរិស្ថានសំខាន់ៗទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមនៅក្នុងតំបន់នោះ ដែលអាចបង្កឡើងដោយសារសកម្មភាពនានានៅក្នុងដំណាក់កាលនេះ ដូចជាហេតុប៉ះពាល់ដល់សណ្ឋានដី ការហូរច្រោះដី គុណភាពទឹក គុណភាពដី គុណភាពខ្យល់ ការរំខានដោយសំលេង និងរំញ័រ ព្រៃឈើ ជម្រកនិងសត្វព្រៃ ជីវៈចម្រុះក្នុងទឹក ការប្រើប្រាស់ដីនិងការតាំងទីលំនៅ មុខរបរ ផ្លូវគមនាគមន៍ តំបន់ប្រវត្តិសាស្ត្រ និងសុខភាពសាធារណៈ។

ខ. ដំណាក់កាលអាជីវកម្ម (ប្រតិបត្តិគម្រោង)

ការងារសម្រាប់ការត្រួតពិនិត្យបរិស្ថាននៅក្នុងដំណាក់កាលនេះ ជាការងារសំខាន់ជាងដំណាក់កាលផ្សេងៗទៀត ដែលអាចបង្កអោយមានហេតុប៉ះពាល់ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមសំខាន់ៗក្នុងតំបន់នោះក្នុងរយៈពេលវែង ដោយសារសកម្មភាពនានារបស់ក្រុមហ៊ុនមានដូចជា សណ្ឋានដី ការហូរច្រោះដី ការបំពុលខ្យល់ ការរំខានដោយសំលេង និងរំញ័រ ព្រៃឈើ ជម្រកនិងសត្វព្រៃ ជីវៈចម្រុះក្នុងទឹក មុខរបរនិងប្រាក់ចំណូល ការប្រើប្រាស់ដីនិងការតាំងទីលំនៅ ផ្លូវគមនាគមន៍ តំបន់ប្រវត្តិសាស្ត្រ ការប្រើប្រាស់ទឹក ការប្រើប្រាស់ថាមពល សុខភាពសាធារណៈ និងគ្រោះធម្មជាតិ។ល។

Draft

គ. ដំណាក់កាលបញ្ចប់គម្រោង

ការងារសម្រាប់ដំណាក់កាលនេះ ជាដំណាក់កាលប្រគល់ទីតាំងអាជីវកម្មនេះទៅឲ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋមូលដ្ឋានវិញ ព្រមទាំងស្តារបរិស្ថាន និងសង្គមដែលខូចខាតឲ្យមានលក្ខណៈល្អប្រសើរឡើងវិញ។

៨.៣.២- វិធានការការពារបរិស្ថាន

យោងលើអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គម្រោង បានរៀបចំ និងកំណត់នូវវិធានការសំខាន់ៗមួយចំនួន សម្រាប់ការធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់បណ្តាលហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះប្រកបដោយប្រសិទ្ធិភាព ស្របតាមបច្ចេកទេស និងបទដ្ឋានបរិស្ថាន។

នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ម្ចាស់គម្រោងត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចមានក្នុងតារាងខាងក្រោម៖

តារាង៨.២៖ វិធានការការពារបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន	ផែនការសម្រាប់អនុវត្តការការពារបរិស្ថាន
ការដោះស្រាយលើផលប៉ះពាល់ដីធ្លីរបស់ប្រជាជន	• កំណត់ទីតាំង និងទំហំដីរបស់ប្រជាជនដែលរងការប៉ះពាល់ក្នុងតំបន់គម្រោង។ • ដោះស្រាយ និងជូនសំណងជូនប្រជាជនដោយសន្តិវិធី និងតំលាភាព។
ការចូលរួមការពារប្រសាទបុរាណ	• វិធានការច្បាប់យ៉ាងតឹងរឹងចំពោះបុគ្គលិក និងកម្មករមិនឲ្យប៉ះពាល់ប្រាសាទ។ • កំណត់ព្រំយ៉ាងច្បាស់លាស់ និងរក្សាទុកចំងាយ១៥០ម៉ែត្រជុំវិញប្រាសាទ។
ការគ្រប់គ្រងអាចម៍ដីរ៉ែ	• រៀបចំកន្លែងស្តុកអាចម៍ដីរ៉ែ ដោយជ្រើសរើសទីតាំងដែលស្ថិតនៅក្បែរអណ្តូងរ៉ែបំផុត ដើម្បីងាយស្រួលចាក់ដីលប់បំពេញ។ • ទីតាំងស្តុកអាចម៍ដី គឺស្ថិតនៅតំបន់ទំនាប ដែលកាត់បន្ថយការហូរច្រោះដីទៅតំបន់ជិតខាង។
ការគ្រប់គ្រងសំណល់រាវចេញពីរណ្តៅរ៉ែ	• សាងសង់អាងស្តុកទឹកចេញពីរណ្តៅរ៉ែ ដែលមានទីតាំងស្ថិតនៅក្បែររោងចក្រចំរាញ់ និងទាញយកទឹកនេះមកប្រើប្រាស់ក្នុង

	ដំណើរការរោងចក្រ។ • បំពាក់ប្រព័ន្ធទុយោ នៅក្នុងអណ្តូងរ៉ែឲ្យបានគ្រប់គ្រាន់ ដើម្បីបូមទឹកចេញទៅអាងស្តុកទឹកទុករបស់រោងចក្រចំរាញ់រ៉ែ។
ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ	• ក្រុមហ៊ុនធ្វើការឈូសឆាយ និងជីកយករ៉ែទៅតាមគម្រោងប្លង់មេ។ • អប់រំ និងណែនាំកម្មករមិនឲ្យកាប់បំផ្លាញព្រៃឈើ បរបាញ់សត្វ និងដាក់អន្ទាក់សត្វព្រៃ។
ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពរបស់បុគ្គលិក និងកម្មករ និងសុខមាលភាពសាធារណៈ	• រៀបចំឧបករណ៍សុវត្ថិភាពដូចជាៈ ស្បែកជើង កវែង មួកការពារក្នុងការដ្ឋាន វ៉ែនតាសុវត្ថិភាព ម៉ាស់ការពារមុខ ប្រដាប់ការពារត្រចៀក និងស្រោមដៃជាដើម។ • ក្នុងការដ្ឋានត្រូវមានការយាមកាមតឹងរ៉ឹង ដោយក្រុមសន្តិសុខរបស់ក្រុមហ៊ុន ដើម្បីការពារនូវការបាត់បង់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងបុគ្គលិក-កម្មករ ដោយអំពើចោរកម្ម។ • កំណត់ពេលវេលាច្បាស់លាស់សម្រាប់បុគ្គលិក និងកម្មករក្នុងការបំពេញការងារ។ • អប់រំបុគ្គលិក និងកម្មករឲ្យប្រកាន់ខ្ជាប់សុវត្ថិភាពជាបំបង និងការដ្ឋាន។ • ផ្តល់ជូនការធានារ៉ាប់រងអាយុជីវិតដល់បុគ្គលិក និងកម្មករអចិន្ត្រៃ។ • រៀបចំបន្ទប់ពេទ្យ ដើម្បីព្យាបាល និងសង្គ្រោះបន្ទាប់ក្នុងករណីបុគ្គលិក និងកម្មករឈឺ ឬគ្រោះថ្នាក់ដោយប្រការណាមួយ។
ការគ្រប់គ្រងហានិភ័យពីការធ្វើអាជីវកម្មរ៉ែទង់ដែង និងការលុបរណ្តៅរ៉ែ	• ការជីកយករ៉ែអនុវត្តតាមបច្ចេកទេស និងប្រើប្រាស់ឧបករណ៍ទំនើប អាចជឿទុកចិត្ត ដែលបច្ចុប្បន្នកំពុងពេញនិយមទៅទូទាំងពិភពលោក។ • រដូវវស្សាមានភ្លៀងច្រើនក្នុងតំបន់ជីករ៉ែ អាចបង្កឲ្យមានការដក់ទឹកជាច្រើននៅក្នុងរណ្តៅជីករ៉ែ។ ហេតុដូចនេះ ដើម្បីធានាដល់ភាពប្រក្រតីនៃការប្រតិបត្តិការជីករ៉ែ ក្រុមហ៊ុនបំពាក់ប្រព័ន្ធបូមឲ្យបានគ្រប់គ្រាន់នៅក្នុងរណ្តៅរ៉ែ។ • ការជីករ៉ែ ក្រុមហ៊ុននឹងបង្កើនការសិក្សាស្រាវជ្រាវបន្ថែមទៀតយ៉ាងហោចណាស់ឈានដល់កម្រិតស្វែងរុករកបឋម ដើម្បី

Draft

	ទទួលបានទិន្នន័យភូគព្ភសាស្ត្រមួយដែលអាចជឿទុកចិត្ត និងធានាដល់ភាពប្រក្រតីនៃផលិតកម្ម។ • ក្រោយពេលជីកដល់ជម្រៅជ្រៅគួរសមមួយ ត្រូវយកចិត្តទុកដាក់ចំពោះស្ថិរភាពនៃដីនៅជុំវិញរណ្តៅជីក ស្របគ្នានេះក៏ត្រូវពិចារណាការចាក់ដីលុបវិញនៅរណ្តៅជីក ដើម្បីធានាដល់សុវត្ថិភាព។

ក្រុមហ៊ុនត្រៀមថវិកាមួយផ្នែកតូច ដែលបានមកពីប្រាក់ចំណេញសម្រាប់មូលនិធិបរិស្ថាន និងសង្គម។ មូលនិធិបរិស្ថានត្រូវចំណាយ **៣០.០០០(បីម៉ឺន)** ដុល្លារសហរដ្ឋអាមេរិក ក្នុងរយៈពេល ១ឆ្នាំដើម្បីប្រើប្រាស់សម្រាប់ការស្តារបរិស្ថានឡើងវិញ ដូចជាការដាំដើមឈើ និងការការពារគុណភាពបរិស្ថាន។ ចំណែក មូលនិធិសង្គម ក្រុមហ៊ុនត្រៀមថវិកាចំនួន **៣០.០០០(បីម៉ឺន)** ដុល្លាសហរដ្ឋអាមេរិកសម្រាប់រយៈពេល ១ឆ្នាំ ដើម្បីប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជំនាញដាំដើមម្រុំ (ក្រុមហ៊ុននឹងបណ្តុះបណ្តាលប្រជាជន ឬបុគ្គលិកឲ្យចេះពីរបៀបបង្កបង្កើនផលរបស់ម្រុំ និងបន្ទាប់ក្រុមហ៊ុននឹងបញ្ជាទិញផលម្រុំពីប្រជាជន ដើម្បីចរាចរលើទីផ្សារ)។ ម្យ៉ាងទៀត ក្រុមហ៊ុនក៏មានផែនការបណ្តុះបណ្តាលជំនាញដល់មន្ត្រីនៃមន្ទីរបរិស្ថាន អ្នកពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនផងដែរ។ ក្រុមហ៊ុនក៏ត្រៀមថវិកាសម្រាប់ ការទ្រទ្រង់សាសនាតាមរយៈវិស័យទេសចរណ៍ និងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់។ ថវិកាលំអិតសម្រាប់មូលនិធិបរិស្ថាន និងសង្គមមានបញ្ជាក់ក្នុងតារាងខាងក្រោម។

រូបភាព៨.១៖ កិច្ចការពារបរិស្ថាន

Draft

22P, , Sk. , Kha y Ke om P
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាងទី៨.៣៖ ផែនការចំណាយសម្រាប់មូលនិធិបរិស្ថាន និងសង្គមរយៈ ពេល១០ឆ្នាំ

ល.រ	សកម្មភាព	ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	ឆ្នាំទី៦	ឆ្នាំទី៧	ឆ្នាំទី៨	ឆ្នាំទី៩	ឆ្នាំទី១០	សរុប (USD)
ក.	**មូលនិធិបរិស្ថាន**											**៣០០.០០០**
១	ចូលរួមដាំដើមឈើ និងការពារគុណភាពបរិស្ថាន	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០០.០០០
ខ.	**មូលនិធិសង្គម**											**៣០០.០០០**
១	បណ្តុះបណ្តាលជំនាញផ្សេងៗដល់មន្ត្រីនៃមន្ទីរបរិស្ថាន អ្នកពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុន	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១.០០០០	១០.០០០០
២	កសាងហេដ្ឋារចនាសម្ព័ន្ធនានា	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០.០០០	២០០.០០០
	សរុប	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	៦០.០០០	**៦០០.០០០**



៨.៤ កម្មវិធីបណ្តុះបណ្តាល និងអប់រំបរិស្ថាន

៨.៤.១- កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាល ផ្តោតសំខាន់លើការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឲ្យយល់ដឹងពីបញ្ហាបរិស្ថានជាផ្នែកមួយ ក្នុងការគ្រប់គ្រងបរិស្ថាន និងដើម្បីឲ្យប្រជាពលរដ្ឋចូលរួមចំណែកក្នុងការការពារបរិស្ថាន និងការបំពុលបរិស្ថាន នៅពេលគម្រោងចាប់ផ្តើមអនុវត្ត ពិសេសការឈូសឆាយដី ការបញ្ចេញសំណល់រឹងរាវ និងសុវត្ថិភាពការងារ ជាដើម។

ដូច្នេះ ម្ចាស់គម្រោងត្រូវមានកម្មវិធីបំពាក់បំប៉នចំពោះ បុគ្គលិក-កម្មកររបស់ខ្លួនឲ្យបានយល់ដឹងពីបញ្ហាបំពុលបរិស្ថាន និងការថែរក្សាសោភ័ណ្ឌភាពបរិស្ថាន។ រាល់ការបំពាក់បំប៉នទាំងអស់ ក្រុមហ៊ុនជាអ្នកចំណាយទាំងស្រុង។

ការបណ្តុះបណ្តាលទាំងនោះមានដូចជា៖

- ផ្តល់ចំណេះដឹងបច្ចេកទេសសម្រាប់ប្រើ ឬបញ្ហាគ្រឿងយន្តពេលដំណើរការគម្រោង
- ផ្តល់ចំណេះដឹងសម្រាប់បើកបររថយន្តធុនធំ និងគ្រឿងចក្រគ្រប់ប្រភេទប្រកបដោយការទទួលខុសត្រូវ
- ផ្តល់ចំណេះដឹងពីការការពារសុវត្ថិភាពការងារ និងវិធីសាស្ត្រការពារសុខភាពផ្ទាល់ខ្លួនពីជំងឺនានា ជាពិសេសជំងឺអេដស៍
- អប់រំឲ្យចេះពីការបំពាក់ឧបករណ៍ការពារខ្លួនក្នុងពេលធ្វើការ
- អប់រំចំពោះការគ្រប់គ្រងសំណល់រឹង-រាវ ឲ្យមានការយកចិត្តទុកដាក់លើការបង្គរកាកសំណល់ ការបោះចោលកាកសំណល់អាហារ ថង់ប្លាស្ទិច សម្ភារៈខូចខាត ឬរបស់របរមិនប្រើប្រាស់ កុំឲ្យបោះចោលទៅក្នុងទឹក
- អប់រំឲ្យយល់ដឹងពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់គម្រោងសម្រាប់តម្រូវការរបស់សង្គម និងជីវភាពប្រចាំថ្ងៃ ដូចជាទឹក ព្រៃឈើ និងសត្វព្រៃ។ ស្របពេលជាមួយគ្នានេះដែរ ម្ចាស់គម្រោងត្រូវរៀបចំ និងផ្សព្វផ្សាយអំពីបទបញ្ញា និងការដាកពិន័យនានា ដែលពាក់ព័ន្ធនឹងការបរបាញ់សត្វ និងការកាប់ព្រៃឈើ។
- បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ

ការបណ្តុះបណ្តាលនេះ ក្រុមហ៊ុនអាចមានលទ្ធភាពជ្រើសរើសបុគ្គលិក-កម្មករ ដែលមានសមត្ថភាពខ្ពស់ឲ្យទៅសិក្សានៅក្រៅប្រទេស ដើម្បីដកស្រង់បទពិសោធន៍ពីអន្តរជាតិ។ ជាមួយគ្នានេះដែរ ប្រសិនបើក្រុមហ៊ុនមិនអាចបញ្ជូនបុគ្គលិក-កម្មករទៅបណ្តុះបណ្តាលនៅក្រៅ

ប្រទេសបានទេ ក្រុមហ៊ុននឹងជួលគ្រូឲ្យមកបណ្តុះបណ្តាលនៅក្នុងក្រុមហ៊ុនទៅតាមជំនាញជាក់ស្តែង។ រាល់ការបណ្តុះបណ្តាលដែលមានរយៈពេលមធ្យម ឬវែង ក្រុមហ៊ុនត្រូវតែធ្វើកិច្ចសន្យាជាមួយបុគ្គលិក-កម្មករថា បុគ្គលិក-កម្មករនឹងបំរើការងារឱ្យក្រុមហ៊ុនវិញយ៉ាងតិច ០២ឆ្នាំ។

៨.៤.២- ការអប់រំបរិស្ថាន

ការអប់រំបរិស្ថានគឺជាដំណើរការមួយ ដែលផ្តល់ឲ្យសិក្ខាកាមនូវស្មារតី និងចំណេះដឹងអំពីបរិស្ថាន (ដែលជាធម្មតារួមបញ្ចូលនូវទំនាក់ទំនងរវាងមនុស្ស និងបរិស្ថានធម្មជាតិ) ហើយលើកកម្ពស់នូវជំនាញ អាកប្បកិរិយា និងលើកទឹកចិត្តដល់ពួកគាត់ ដែលអាចឲ្យពួកគាត់ធ្វើសេចក្តីសម្រេចចិត្ត និងមានសកម្មភាពទំនួលខុសត្រូវលើការពិចារណាអំពីបរិស្ថាន។

ការអប់រំបរិស្ថាន គឺជាវិធីសាស្ត្រយ៉ាងសំខាន់មួយ ដែលផ្តោតសំខាន់លើកុមារ និងយុវជន ដោយសារតែនេះជាឱកាសមួយ ដើម្បីបង្កើតបានជាគន្លឹះនៃដំណាក់កាលអភិវឌ្ឍន៍។ ជាមួយគ្នានេះដែរ កុមារ និងយុវជនអាចជាបណ្តាញដ៏សំខាន់មួយក្នុងការផ្តល់ព័ត៌មានស្តីពីអកប្បកិរិយាបរិស្ថានទៅកាន់ឪពុកម្តាយរបស់ពួកគេ។

ដូច្នេះម្ចាស់គម្រោងត្រូវមានកម្មវិធីអប់រំបរិស្ថាន ដើម្បីបំពាក់បំប៉នដល់កុមារ យុវជន និងប្រជាពលរដ្ឋដែលជាអាណាព្យាបាលឲ្យបានយល់ពីអ្វីដែលហៅថាការអប់រំបរិស្ថាន។ រាល់ការបំពាក់បំប៉នទាំងអស់ ក្រុមហ៊ុនជាអ្នកចំណាយទាំងស្រុង។

កម្មវិធីអប់រំបរិស្ថានទាំងនោះមានដូចជា៖

- បំពាក់បំប៉នផ្នែកស្មារតីទៅលើបរិស្ថាន និងបញ្ហាប្រឈមរបស់វា
- បណ្តុះបណ្តាលចំណេះដឹង និងការយល់ដឹងជាមូលដ្ឋានពីបរិស្ថាន និងអន្តរទំនាក់ទំនងរបស់វាជាមួយនឹងមនុស្ស
- បំពាក់បំប៉នអំពីតំលៃសង្គម និងអាកប្បកិរិយា ដែលផ្តោតលើគុណភាពបរិស្ថាន
- បំពាក់បំប៉នលើជំនាញ ដើម្បីដោះស្រាយបញ្ហាបរិស្ថាន
- បំពាក់បំប៉នសមត្ថភាព ដើម្បីវាយតំលៃលើការវាស់វែងបរិស្ថាន និងកម្មវិធីបរិស្ថាន
- បំពាក់បំប៉នស្មារតីទំនួលខុសត្រូវលើសកម្មភាពបរិស្ថាន ដើម្បីធានាដល់និរន្តភាពបរិស្ថាន និងដើម្បីដោះស្រាយបញ្ហារបស់បរិស្ថាន។

៨.៥ កម្មវិធីអង្កេតតាមដានបរិស្ថាន (Environmental Monitoring Program)

កម្មវិធីអង្កេតតាមដានគម្រោង គឺជាកម្មវិធីមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងតាមដាននូវរាល់ហេតុប៉ះពាល់បរិស្ថានទាំងឡាយ ដែលអាចនឹងកើតមានឡើងដោយសារសកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ដើម្បីផ្តល់ភាពងាយស្រួលឱ្យម្ចាស់គម្រោងរិះរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះ ដោយសហការជាមួយ

ស្ថាប័នពាក់ព័ន្ធ ពោលគឺជួយតំរង់ទិសដៅដល់កិច្ចដំណើរការគម្រោងឱ្យមានស្ថេរភាព និងជាចំណែកមួយជួយថែរក្សា និងការពារធនធានបរិស្ថាន។ ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនត្រៀមថវិកាយ៉ាងតិច **៦ម៉ឺន** ដុល្លាអាមេរិកក្នុង០១ឆ្នាំ ដើម្បីអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមសកម្មភាពនីមួយៗរបស់គម្រោង ដូចជាការរៀបចំរបាយការណ៍ត្រួតពិនិត្យបរិស្ថានជាដើម។

ការត្រួតពិនិត្យបញ្ហាបរិស្ថាន នឹងត្រូវអនុវត្តដោយម្ចាស់គម្រោងនៅគ្រប់ដំណាក់កាល នៃគម្រោង។ លទ្ធផលនៃការត្រួតពិនិត្យនេះ ក្រុមហ៊ុននឹងធ្វើរបាយការណ៍ត្រួតពិនិត្យបរិស្ថានផ្ញើជូនក្រសួងបរិស្ថានរៀងរាល់ ០៣ខែម្តង ដើម្បីចុះពិនិត្យ និងអង្កេតតាមដានសម្រាប់កែលំអរក្នុងកិច្ចដំណើរការរបស់គម្រោង ស្របតាមបទពិសោធន៍ និងបច្ចេកទេស និងបញ្ចៀសបាននូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឱ្យដល់កម្រិតអប្បបរមា។ ចំណែកហេតុប៉ះពាល់វិជ្ជមាន ក្រុមហ៊ុននឹងខិតខំធ្វើឱ្យប្រសើរឡើងដល់កម្រិតអតិបរមា។ ក្នុងករណីពិសេសណាមួយដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមដោយសារសកម្មភាពគម្រោង ក្រុមហ៊ុននឹងសហការជាមួយមន្ត្រីជំនាញនៃក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ដើម្បីចុះពិនិត្យ និងកែលំអរ។

កម្មវិធីត្រួតពិនិត្យបរិស្ថាននេះបំណងសំខាន់គឺដើម្បីកំណត់ និងប្រៀបធៀបអោយដឹងថារវាងហេតុប៉ះពាល់បរិស្ថាន "ហ.ប.ស" និងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន "វ.ក.ប" ដែលបានសិក្សាហើយ ធៀបទៅនឹងលទ្ធផលនៃការងារត្រួតពិនិត្យបរិស្ថានជាក់ស្តែងនៅគ្រប់ដំណាក់កាលនៃគម្រោង។

ក្នុងករណីលទ្ធផលពិនិត្យរបស់គម្រោងមានភាពមិនច្បាស់លាស់ ពេលនោះក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធចុះពិនិត្យធនធានបរិស្ថាននេះបន្ថែមទៀត ដើម្បីផ្ទៀងផ្ទាត់ជាមួយលទ្ធផលដែលក្រុមហ៊ុនបានពិនិត្យ។

ដោយឡែក កម្មវិធីត្រួតពិនិត្យបរិស្ថានសំខាន់ៗ នៅគ្រប់ដំណាក់កាលរបស់គម្រោងនេះ ម្ចាស់គម្រោងនឹងសហការជាមួយក្រសួងបរិស្ថាន ដើម្បីធ្វើការត្រួតពិនិត្យលើធនធានបរិស្ថានសំខាន់ៗមួយចំនួនរួមមាន ៖

តារាង៨.៤៖ កម្មវិធីត្រួតពិនិត្យបរិស្ថាន

ធនធានបរិស្ថាន	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួត ពិនិត្យ	ការប៉ាន់ប្រមាណតំលៃជាដុល្លា
ដំណាក់កាលរចនាគម្រោង						
ការប៉ះពាល់ដីស្រែចំការរបស់ប្រជាពលរដ្ឋ	• តាមដាន និងសំណងប៉ះប៉ូវនូវការបាត់បង់លំនៅដ្ឋាន និងស្ថានភាពសេដ្ឋកិច្ចក្បែរតំបន់គម្រោង	• ទីតាំងតំបន់ផ្ទះប្រជាពលរដ្ឋ ចំការ និងដីស្រែដែលមានក្នុងតំបន់គម្រោង • ដំណោះស្រាយលើការប៉ះប៉ូវ ឬសំណងនានាឲ្យប្រជាពលរដ្ឋដែលទទួលរងនូវការប៉ះពាល់	មុនពេលឈូសឆាយសាងសង់គម្រោង	- ម្ចាស់គំរោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
ព្រៃឈើ ជម្រក និងសត្វព្រៃ	• តាមដាន និងកាត់បន្ថយនូវបម្រែបម្រួលព្រៃឈើ សត្វព្រៃ ជម្រកសត្វ	• ពិនិត្យមើលទីតាំងព្រៃឈើដែលត្រូវឈូសឆាយសាងសង់ហេដ្ឋារចនាសម្ព័ន្ធ • ពិនិត្យមើលផែនការការពារ និងថែរក្សាព្រៃឈើក្នុងតំបន់គម្រោង	មុនពេលឈូសឆាយសាងសង់គម្រោង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • រដ្ឋបាលព្រៃឈើ	តាមការជាក់ស្តែង
ទីតាំងប្រសាទបុរាណ	• តាមដានពិនិត្យលើតំបន់ដែលពុំទាន់បានស្រាវជ្រាវដូចជាប្រាសាទបុរាណ	• តាមទីតាំងដែលបម្រុងឈូសឆាយ	មុនពេលឈូសឆាយសាងសង់គម្រោង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរអប្សរា	តាមការជាក់ស្តែង

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ការធ្វើអាជីវកម្មថ្មបាយក្រៀម	• តាមដានពិនិត្យទីតាំងថ្មបាយក្រៀមរបស់ក្រុមហ៊ុន មាស ណារិទ្ធិ និងជា ណារី	• ចំណុចទីតាំងក្រុមហ៊ុនទាំង២ ធ្វើអាជីវកម្ម • ផែនការជីករបស់ក្រុមហ៊ុនទាំង២	មុនពេលឈូសឆាយសាងសង់គម្រោង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រុមធ្វើអាជីវកម្មថ្មបាយក្រៀមទាំង២ • ក្រសួងរ៉ែ និងថាមពល	តាមការជាក់ស្តែង
អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ	• តាមដានពិនិត្យមើលទីតាំងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ	• ផែនការដោះមីនរបស់ក្រុមហ៊ុន • ពិនិត្យមើលទីតាំងមីន	មុនពេលឈូសឆាយសាងសង់គម្រោង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរកំចាត់មីន	តាមការជាក់ស្តែង
ដំណាក់កាលសាងសង់						
ក.ធនធានរូបសាស្ត្រ						
- សណ្ឋានដី និងឋានលេខា - ការហូរច្រោះដី	• តាមដានឥទ្ធិពលគម្រោងដែលធ្វើឲ្យសណ្ឋានដីមានការប្រែប្រួលខ្លាំង និងការហូរច្រោះដីពីតំបន់ដីបានឈូសឆាយ • តាមដានការឈូសឆាយថាតើអនុវត្តតាមប្លង់មេរបស់គម្រោង	• ពិនិត្យចំណុចនិយាមតំបន់ត្រូវឈូសឆាយនៅទីតាំងព្រំគម្រោង • ពិនិត្យមើលសណ្ឋានដី ឋានលេខា និងទីជម្រាលនៅទីតាំងដែលត្រូវឈូសឆាយ (ផ្លូវ ផ្ទះស្នាក់នៅ ការិយាល័យ) • ពិនិត្យមើលកំណកកំទេចល្បាប់នៅតាមអូរតូចៗ និងតាមត្រពាំង • ពិនិត្យមើលការបាត់បង់ព្រៃឈើក្នុងតំបន់គម្រោង	ពេលឈូសឆាយ	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងរ៉ែ និងថាមពល • ក្រសួងធនធានទឹកនិងឧត្តុនិយម	តាមការជាក់ស្តែង

	ដែររឺទេ • តាមដានមើលការប្រើប្រាស់គ្រឿងម៉ាស៊ីន និងគ្រឿងចក្រ					
គុណភាពទឹក	• តាមដានហេតុ ប៉ះពាល់ដែលធ្វើឲ្យការកកស្ទះប្រព័ន្ធជលសាស្ត្រ និងតាមដានគុណភាពទឹកលើដី និងក្រោមដី	• ពិនិត្យលើបរិមាណទឹក និងគុណភាពទឹកអូរ និងទឹកបឹង (សមាសធាតុទឹកដែលត្រូវពិនិត្យមានចែងក្នុងអនុក្រឹត្យស្តីពីការពិនិត្យការបំពុលទឹក) • ពិនិត្យគុណភាពទឹកអណ្តូងរបស់ប្រជាជន និងទឹកអណ្តូងដែលកម្មករប្រើប្រាស់ • ពិនិត្យមើលការរៀបចំ និងការគ្រប់គ្រងសំណល់រឹង/រាវតាមលក្ខណៈបច្ចេកទេស នៅក្នុងតំបន់ស្នាក់នៅកម្មករ និងការិយាល័យធ្វើការ	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងធនធានទឹក និងឧតុនិយម	តាមការជាក់ស្តែង
គុណភាពខ្យល់	• តាមដានការប្រែប្រួលប៉ារ៉ាម៉ែត្រនៃគុណភាពខ្យល់សំខាន់ៗមួយចំនួន NO_x, SO_x និងTSP	• វាស់កម្រិតធូលីដែលហុយចេញពីសកម្មភាពដឹកជញ្ជូន និងការបំបែកថ្មដោយប្រើគ្រឿងផ្ទុះ (តាមផ្លូវ)។ • ពិនិត្យ និងសហការណ៍ ដើម្បីតាមដានសុខភាពបុគ្គលិក-កម្មករ និង	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន	តាមការជាក់ស្តែង

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

		ប្រជាពលរដ្ឋ។				
ការរំខានដោយសំលេង និងរំញ័រ	• តាមដានការរំខានដោយសំលេង និងរំញ័រ គ្រប់ពេលប្រតិបត្តិការអាជីវកម្ម	• ពិនិត្យមើលគ្រឿងចក្រ និងរថយន្តសម្រាប់ប្រើប្រាស់ក្នុងការដ្ឋាន • ពិនិត្យមើលល្បឿនបើកបររថយន្តក្នុងនិងក្បែរតំបន់គម្រោង (អនុញ្ញាតឲ្យបើកបររថយន្តគោរពតាមច្បាប់ចរាចរណ៍ដែលបានអនុម័ត)	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងសាធារណៈការ និងដឹកជញ្ជូន	តាមការជាក់ស្តែង
ខ.ធនធានជីវសាស្ត្រ						
- ព្រៃឈើ ជម្រក និងសត្វព្រៃ - ជីវចម្រុះក្នុងទឹក	• តាមដាន និងកាត់បន្ថយនូវបម្រែបម្រួលព្រៃឈើ សត្វព្រៃ ជម្រកសត្វ និងជីវចម្រុះក្នុងទឹក	• ពិនិត្យមើលទីតាំងព្រៃឈើដែលត្រូវឈូសឆាយតាមផែនការមេរបស់គម្រោងអាជីវកម្ម • ពិនិត្យមើលផែនការការពារ និងថែរក្សាព្រៃឈើនៅតាមមាត់អូរ បឹង និងត្រពាំង	រៀងរាល់ ០៣ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	តាមការជាក់ស្តែង
គ.ធនធានសេដ្ឋកិច្ច-សង្គម						
ការរស់នៅរបស់ប្រជាជន (ការតាំងលំនៅដ្ឋាន និងការប្រើប្រាស់ដី)	• តាមដាន និងសំណងប៉ះប៉ូវនូវការបាត់បង់លំនៅដ្ឋាន និងស្ថានភាពសេដ្ឋកិច្ចក្បែរតំបន់គម្រោង	• ទីតាំងតំបន់ផ្ទះប្រជាពលរដ្ឋ ចំការ និងដីស្រែដែលមានក្នុងតំបន់គម្រោង • ដំណោះស្រាយលើការប៉ះប៉ូវ ឬសំណងនានាឲ្យប្រជាពលរដ្ឋដែលទទួលរងនូវការប៉ះពាល់	មុនពេលឈូសឆាយ និងពេលប្រតិបត្តិគម្រោង	- ម្ចាស់គំរោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ផ្លូវគមនាគមន៍ (ហេដ្ឋារចនាសម្ព័ន្ធ)	• តាមដាន និងជួសជុលនូវប្រព័ន្ធគមនាគមន៍ដែលខូចខាតដោយសារគម្រោង	• ពិនិត្យលើទីតាំងនៃប្រព័ន្ធផ្លូវឆ្លងកាត់ និងស្ពាន • ពិនិត្យលើល្បឿនក្នុងការបើកបរ	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងសាធារណការ និងដឹកជញ្ជូន	តាមការជាក់ស្តែង
សុខភាព និងសុខាមាលភាពសាធារណៈ	• ពិនិត្យ អង្កេត លើបញ្ហាសុខភាព និងសុខាមាលភាពសាធារណៈ: ប្រសិនបើមានកើតជំងឺណាមួយដោយចៃដន្យ	• ពិនិត្យមើលជំងឺដែលកើតជាញឹកញាប់នៅក្នុងតំបន់គម្រោង • ពិនិត្យមើលការប្រើប្រាស់ទឹក គុណភាពទឹក គុណភាពខ្យល់ និងការរំខានដោយសំលេងដូចមានបង្ហាញខាងលើ • មើលទីតាំងទុកដាក់ និងគ្រប់គ្រងសំណល់រឹងរាវរបស់គម្រោង • ការរស់នៅ សុខភាព និងសុវត្ថិភាពរបស់បុគ្គលិក-កម្មករ • សាកសួរព័ត៌មានពីប្រជាពលរដ្ឋក្នុងតំបន់អំពីការប៉ះពាល់ផ្សេងៗ	រៀងរាល់ ០៦ខែ/ម្តង	- ម្ចាស់គំរោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • មណ្ឌលសុខភាព • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
មុខរបរ និងប្រាក់ចំណូល	• ពិនិត្យលើប្រភពចំណូលចំបង និងបន្ទាប់បន្សំ ដែលផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន	• ពិនិត្យលើដីស្រែចំការដែលប៉ះពាល់ • ពិនិត្យមើលលើទីតាំងស្វែងរកអនុផលព្រៃឈើរបស់ប្រជាជន និងសាកសួរពីព័ត៌មានប៉ះពាល់ផ្សេងៗ	រៀងរាល់ ០៦ខែ/ម្តង	- ម្ចាស់គំរោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ទីតាំងប្រសាទ	• តាមដានពិនិត្យលើតំបន់ដែលពុំទាន់បានស្រាវជ្រាវដូចជាប្រាសាទបុរាណ	• តាមទីតាំងដែលបម្រុងឈូសឆាយ	១ដងពេលធ្វើការឈូសឆាយដី	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរអប្សរា	តាមការជាក់ស្តែង
ដំណាក់កាលប្រតិបត្តិគម្រោង						
ក. ធនធានរូបសាស្ត្រ						
- សណ្ឋានដី និងឋានលេខា **- ការហូរច្រោះដី និងធនធានរ៉ែ**	• តាមដាន និងពិនិត្យការប្រែប្រួលសណ្ឋានដី និងឋានលេខា • តាមដាន ពិនិត្យការប្រែប្រួលស្រទាប់ដី និងរបកគំហើញថ្មីនៃរ៉ែផ្សេងៗទៀត	• ពិនិត្យនៅតាមទីតាំងកាយយករ៉ែនីមួយៗ ពិសេសជម្រៅរ៉ែ ដែលបានកំណត់តាមទីតាំងក្នុងផែនការមេ។ • ពិនិត្យនៅកន្លែងរែងរ៉ែមុនពេលចម្រាញ់ និងគំនរគរទុកអាចម៍រ៉ែដែលបម្រុងយកចាកបំពេញនៅទីតាំងដែលបានកាយរួច។	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងរ៉ែ និងថាមពល	តាមការជាក់ស្តែង
គុណភាពទឹក	• តាមដានពិនិត្យលើការបំពុលទឹកលើដី និងក្រោមដី	• ទីតាំងពិនិត្យសំណាកទឹកតាមប្រព័ន្ធខ្វារ ស្ទឹងជីក្រែង បឹងឈ្នួន និងទឹកអណ្តូងក្នុងការដ្ឋាន និងក្នុងភូមិ • ពិនិត្យទីតាំងទុកដាក់សំណល់អាចម៍ដី សំណល់អាចម៍រ៉ែ ដែលបានស្តុកទុក • ប៉ារ៉ាម៉ែត្រដែលត្រូវពិនិត្យ ដូចមាន	រៀងរាល់ ០៣ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងធនធានទឹក និងឧត្តុនិយម	តាមការជាក់ស្តែង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

		ចែងក្នុងអនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក និងរំខានដោយសំលេង (ឆ្នាំ២០០០)				
ការបំពុលខ្យល់ និងការរំខានដោយសំលេង និងរំញ័រ	• តាមដាន និង ពិនិត្យមើលគុណភាពខ្យល់ បញ្ហាសំលេង និងរំញ័រដែលកើតឡើង	• ពិនិត្យមើលធូលីដែលហុយចេញពីសកម្មភាពដឹកជញ្ជូន និងទីតាំងកាយយករ៉ែ • ពិនិត្យទីតាំងស្តុកអាចម៍ដី អាចម៍រ៉ែ និងថ្មរ៉ែ • ប៉ារ៉ាម៉ែត្រដែលត្រូវពិនិត្យ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំលេងរំខាន	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន	តាមការជាក់ស្តែង
ខ.ធនធានជីវសាស្ត្រ						
ព្រៃឈើ ជម្រក និងសត្វព្រៃ	• តាមដានហេតុប៉ះពាល់ដោយផ្ទាល់លើធនធានព្រៃឈើ និងដោយប្រយោលលើជម្រក និងសត្វព្រៃ	• ពិនិត្យលើផែនការការពារ និងថែរក្សាព្រៃឈើ និងដាំដើមឈើ • ពិនិត្យលើផែនការដាំដើមឈើលើទីតាំងដែលលប់រួច	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • រដ្ឋបាលព្រៃឈើ	តាមការជាក់ស្តែង

Draft

ជីវចម្រុះក្នុងទឹក	• ពិនិត្យ និងតាមដានលើការប្រែប្រួលនៃពពួកជីវចម្រុះក្នុងទឹក	• ពិនិត្យមើលផែនការការពារ និងថែរក្សាព្រៃឈើនៅតាមមាត់អូរ បឹង និងត្រពាំង	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	តាមការជាក់ស្តែង
គ. ធនធានសេដ្ឋកិច្ច-សង្គម						
មុខរបរ និងប្រាក់ចំណូល	• ពិនិត្យលើប្រភពចំណូលចំបង និងបន្ទាប់បន្សំ ដែលផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន	• ពិនិត្យលើដីស្រែចំការដែលប៉ះពាល់ • ពិនិត្យមើលលើទីតាំងស្វែងរកអនុផលព្រៃឈើរបស់ប្រជាជន និងសាកសួរពីព័ត៌មានប៉ះពាល់ផ្សេងៗ	រៀងរាល់ ០៦ខែ/ម្តង	- ម្ចាស់គំរោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
សុខភាព និងសុខុមាលភាពសាធារណៈ	• តាមដាននូវប្រភេទជំងឺដែលកើតឡើងថ្មី និងសុវត្ថិភាពបុគ្គលិក-កម្មករ និងប្រជាពលរដ្ឋដែលនៅក្បែរតំបន់គម្រោង	• នៅក្នុងការដ្ឋានរ៉ែ និងក្នុងភូមិក្បែរតំបន់គម្រោង • តាមដានសុខភាព និងសុវត្ថិភាពកម្មករជាប្រចាំ • ពិនិត្យមើលការរៀបចំការដ្ឋានឲ្យមានអនាម័យល្អ • សាកសួរព័ត៌មានពីប្រជាពលរដ្ឋអំពីការប៉ះពាល់នានា ដោយសារការប្រើប្រាស់ទឹក	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • មណ្ឌលសុខភាព • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
ការរស់នៅរបស់ប្រជាសហគមន៍	• តាមដាន និងសំណងប៉ះប៉ូវនូវការបាត់បង់	• ទីតាំងតំបន់ផ្ទះប្រជាពលរដ្ឋ ចំការ និងដីស្រែដែលមានក្នុងតំបន់គម្រោង	មុនពេលឈូសឆាយ	- ម្ចាស់គំរោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង

(ការតាំងលំនៅដ្ឋាន និងការប្រើប្រាស់ដី)	លំនៅដ្ឋាន និងស្ថានភាពសេដ្ឋកិច្ចក្បែរតំបន់គម្រោង	• ដំណោះស្រាយលើការប៉ះប៉ូវ ឬសំណងនានាឲ្យប្រជាពលរដ្ឋដែលទទួលរងនូវការប៉ះពាល់	និងពេលប្រតិបត្តិគម្រោង			
ផ្លូវគមនាគមន៍	• តាមដាននូវការខូចខាត ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវរងការខូចខាតពេលដឹកជញ្ជូន សម្ភារ: និងផលិតផលចេញ	• ផ្លូវក្នុងភូមិ ដែលក្រុមហ៊ុនបើកបរឆ្លងកាត់	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងសាធារណការ និងដឹកជញ្ជូន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
តំបន់ប្រវត្តិសាស្ត្រ	• តាមដានពិនិត្យតំបន់ប្រវត្តិសាស្ត្រដែលបានជួបដោយចៃដន្យ	• ទីតាំងដែលបានកាយយករ៉ែ	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរអប្សរា	តាមការជាក់ស្តែង
ការប្រើប្រាស់ទឹក	• ពិនិត្យលើប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់គម្រោងអាជីវកម្ម និងប្រជាជន	• អណ្តូងជីក អាងស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ក្នុងទីតាំងគម្រោង • អូរ បឹង និងអណ្តូងរបស់ប្រជាជន	រៀងរាល់ ០៦ខែ/ម្តង	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
ដំណាក់កាលបញ្ចប់គម្រោង						
ក. ធនធានរូបសាស្ត្រ						
សណ្ឋានដី និងឋានលេខា	• តាមដានឥទ្ធិពលគម្រោងដែលធ្វើឲ្យសណ្ឋានដីមានការ	• ពិនិត្យចំណុចនិយាមតំបន់ត្រូវឈូសឆាយនៅទីតាំងព្រំគម្រោង • ពិនិត្យមើលសណ្ឋានដី និងទី	ពេលបញ្ចប់ការជីក	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងរ៉ែ និងថាមពល	តាមការជាក់ស្តែង

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

	ប្រែប្រួលខ្លាំង និងការហូរច្រោះដីពីតំបន់ដីបានឈូសឆាយ • តាមដានការឈូសឆាយថាតើអនុវត្តតាមប្លង់មេរបស់គម្រោងដែរឺទេ	ជម្រាលនៅទីតាំងដែលបានបកដីថាតើបានលប់តាមលក្ខណៈបច្ចេកទេសរឺទេ • ពិនិត្យមើលកំណកកំទេចល្បាប់នៅតាមអូរតូចៗ និងតាមត្រពាំង • ពិនិត្យមើលការបាត់បង់ព្រៃឈើតាមអូរតូចៗ និងតាមត្រពាំង			• ក្រសួងធនធានទឹក និងឧត្តុនិយម	
គុណភាពដី	• តាមដានឥទ្ធិពលគម្រោងដែលធ្វើឲ្យសណ្ឋានដីមានការប្រែប្រួលខ្លាំង និងការហូរច្រោះដីពីតំបន់ដីបានឈូសឆាយ	• ពិនិត្យមើលសណ្ឋានដី និងទីជម្រាលនៅទីតាំងដែលបានលប់បំពេញត្រឹមត្រូវតាមបច្ចេកទេសឬទេ • ពិនិត្យមើលបច្ចេកទេសនៃការដាំដើមឈើឡើងវិញ	ពេលបញ្ចប់ការជីក	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងរ៉ែ និងថាមពល	តាមការជាក់ស្តែង
គុណភាពទឹក	• តាមដានពិនិត្យលើការបំពុលទឹកលើដី និងក្រោមដី	• ទីតាំងពិនិត្យសំណាកទឹកតាមប្រព័ន្ធខ្វារ ស្ទឹងដីក្រែង បឹងឈ្នួន និងទឹកអណ្តូងក្នុងការដ្ឋាន និងក្នុងភូមិ • ប៉ារ៉ាម៉ែត្រដែលត្រូវពិនិត្យ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក និងរំខានដោយសំលេង (ឆ្នាំ២០០០)	ពេលបញ្ចប់ការជីក	-ម្ចាស់គម្រោង - អ្នកម៉ៅការ	• ក្រសួងបរិស្ថាន • ក្រសួងធនធានទឹក និងឧត្តុនិយម	តាមការជាក់ស្តែង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ខ. ធនធានជីវសាស្ត្រ						
ព្រៃឈើ ជម្រក និងសត្វព្រៃ	• តាមដានហេតុប៉ះពាល់ដោយផ្ទាល់លើធនធានព្រៃឈើ និងដោយប្រយោលលើជម្រក និងសត្វព្រៃ	• ពិនិត្យលើផែនការការពារ និងថែរក្សាព្រៃឈើ • ពិនិត្យលើផែនការដាំដើមឈើលើទីតាំងដែលកាយរួច និងលប់វិញ	ពេលបញ្ចប់ការជីក	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • រដ្ឋបាលព្រៃឈើ	តាមការជាក់ស្តែង
គ. ធនធានសេដ្ឋកិច្ច សង្គម						
ការប្រើប្រាស់ទឹក	• ពិនិត្យលើប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់គម្រោងអាជីវកម្ម និងប្រជាជន	• អណ្តូងជីក អាងស្តុកទឹក សម្រាប់ប្រើប្រាស់ក្នុងទីតាំងគម្រោង • អូរ បឹង និងអណ្តូងរបស់ប្រជាពលរដ្ឋ	ពេលបញ្ចប់ការជីក	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
មុខរបរ និងប្រាក់ចំណូល	• ពិនិត្យលើប្រភពចំណូលចំបង និងបន្ទាប់បន្សំ ដែលផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជណ	• ពិនិត្យលើដីស្រែចំការដែលប៉ះពាល់ • ពិនិត្យមើលលើទីតាំងស្វែងរកអនុផលព្រៃឈើរបស់ប្រជាជន និងសាកសួរពីព័ត៌មានប៉ះពាល់ផ្សេងៗ	ពេលបញ្ចប់ការឈូសឆាយ	- ម្ចាស់គំរោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង
ផ្លូវគមនាគមន៍	• ពិនិត្យនូវការខូចខាតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលត្រូវរងការខូចខាតពេលដឹកជញ្ជូនឧបករណ៍	• ផ្លូវក្នុងភូមិ ដែលក្រុមហ៊ុនបើកបរឆ្លងកាត់	ពេលបញ្ចប់ការឈូសឆាយ	-ម្ចាស់គម្រោង - អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងសាធារណការ និងដឹកជញ្ជូន • អាជ្ញាធរមូលដ្ឋាន	តាមការជាក់ស្តែង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

	សម្ភារៈចេញ					

កំណត់សំគាល់ ៖

ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុននឹងធ្វើការត្រៀមបំរុងប្រមាណ **១០.000ដុល្លារអាមេរិក** សម្រាប់ចំណាយប្រចាំឆ្នាំទៅលើការអនុវត្តសកម្មភាពនីមួយៗនៃផែនការគ្រប់គ្រងបរិស្ថាននេះ។

Draft